# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ប្រាក់ យុត ភេទស្រី អាយុ៦៨ឆ្នាំ**

**ស្រុកកំណើតនៅភូមិក្បាលអូរ, ឃុំបារាំងធ្លាក់, ស្រុកត្រាំកក់, ខេត្តតាកែវ**

**រស់នៅភូមិទួល ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង**

**មុខងារសម័យខ្មែរក្រហមៈ គណៈស្រុកកំពង់សៀម**

**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០២:០៣:៣៩**

**៦៥ទំព័រ**

ដានីៈ អ៊ំដឹងប្អូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ ។

យុតៈ ខ្ញុំឈ្មោះអីចឹង ឈ្មោះប្រាក់ យុត ។

ដានីៈ ប្រាក់ យុត សរសេរម៉េចទៅ? "យ" "ុ" និង"ត" ឬ"ទ" ។

យុតៈ នឹង"ត" ។

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

យុតៈ ៦៨ឆ្នាំ ។

ដានីៈ អ៊ំកើតឆ្នាំអីដែរ ឆ្នាំខ្មែរ?

យុតៈ អត់ដឹងដែរ ។

ដានីៈ ឆ្នាំសត្វអីទៅ?

យុតៈ យូរពេក ។

ដានីៈ ឆ្នាំឆ្លូវ "គោ", ឆ្នាំខាល "ខ្លា"?

យុតៈ នេះឆ្នាំច "ឆ្កែ" ។

ដានីៈ ឆ្នាំចនេះ?

យុតៈ យកទាំងអាយុទៀត ។

ដានីៈ ខ្មែរយើងភាគច្រើនយើងកើតមកថាឆ្នាំ"ច", ឆ្នាំ"ឆ្លូវ" យើងចាំ ។ អ៊ំស្រុកកំណើតកើតជានៅភូមិ-ឃុំអីដែរ?

យុតៈ ខ្ញុំនៅភូមិក្បាលអូរ ។

ដានីៈ កំណើតនៅភូមិក្បាលអូរ?

យុតៈ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានី:	ស្រុកត្រាំកក់ ខេត្តតាកែវ ។ អីចឹងស្រុកកំណើតជាមួយអ៊ំចែម ដែរ! ព្រោះខ្ញុំធ្លាប់ទៅជួបគាត់ដែរ ខ្ញុំធ្លាប់សម្ភាសន៍គាត់ គាត់ថាស្រុកកំណើតគាត់នៅក្បាលអូរ ទទឹងថ្ងៃហ្នឹង ភូមិទទឹងថ្ងៃ ក្បាលអូរ ហើយនៅស្រុកភូមិហ្នឹងអ្នកតស៊ូច្រើនណាស់អ៊ំ ឃើញអ្នកតស៊ូ ឃើញអ៊ំ ។

យុត:	អ្នកតស៊ូច្រើន ស្លាប់ក៏ច្រើន ។

ដានី:	ស្លាប់អស់ច្រើនដែរ?

យុត:	អស់ហើយតាំ ក្មេងៗជំនាន់ក្រោយ ចាស់ៗរាប់អស់ហើយ ។

ដានី:	សព្វថ្ងៃអ៊ំនេះអ៊ំនៅភូមិអីដែរ? សព្វថ្ងៃនេះ?

យុត:	ភូមិទួល ឃុំចក្រី ឥឡូវឃុំបារាំងធ្លាក់ ។

ដានី:	ភូមិបារាំងធ្លាក់?

វណ្ណៈ :	ភូមិទួល ។

ដានី:	អតីតភូមិទួល?

យុត:	អត់ទេ ភូមិទួល តែឃុំចក្រី ឥឡូវដាក់ឃុំបារាំងធ្លាក់ ។

វណ្ណៈ :	ដូរឃុំ ។

ដានី:	ឥឡូវហ្នឹងភូមិទួលដដែល ។

យុត:	តែឃុំបារាំងធ្លាក់ ខេត្តបាត់ដំបង ។

ដានី:	ហ្នឹងស្រុកអីវិញទៅ?

យុត:	ស្រុកភ្នំព្រឹក ។

ដានី:	កាលមុនភូមិទួលនេះនៅក្នុងឃុំចក្រីទេ ស្រុកសំពៅលូនទេកាលពីមុន?

យុត:	អត់ទេ ស្រុកភ្នំព្រឹក ។

ដានី:	ខេត្តបាត់ដំបង ។ អ៊ំឪពុកម្ដាយអ៊ំឈ្មោះអីទៅ?

យុត:	ម៉ែឪខ្ញុំស្លាប់តាំងពីឆ្នាំ ឪខ្ញុំមកខូច ។

ដានី:	ឪពុកឈ្មោះ ហ៊ុន ។

យុត:	ហឿន ។

ដានី:	ម្ដាយឈ្មោះ ហឿន?

យុត:	ចាំ ស្លាប់អស់ហើយ ។

ដានី:	គាត់ស្លាប់តាំងពីអន្តាល់ទៅ?

យុគៈ ម៉ែខ្ញុំស្លាប់ឆ្នាំ៩០ ។

ដានីៈ ឪពុកគាត់?

យុគៈ ខ្ញុំចគាំងពីអត្តាល់ខ្ញុំមិនបានចាំ យូរហើយគាំងពីខ្ញុំនៅតូចៗ ។

ដានីៈ ម៉េចបានអ៊ំដាក់ឈ្មោះ ប្រាក់ យុគ?

យុគៈ តាខ្ញុំ តាខាងឪខ្ញុំ ។

ដានីៈ ឪពុករបស់ ត្រូវជាតារបស់អ៊ំឈ្មោះ ប្រាក់ អីចឹងឪពុករបស់អ៊ំគាត់ឈ្មោះអីត្រកូល?

យុគៈ ឈ្មោះ សោម ។

ដានីៈ សោម វិញ?

យុគៈ ចា៎ ។

ដានីៈ សោម ហ៊ុន?

យុគៈ សោម ហឿន ។

វណ្ណៈ : ហ្នឹងម្តាយ?

យុគៈ នេះ "ប្រាក់ ហ៊ុន" ឪខ្ញុំ ។

ដានីៈ ឪពុកឈ្មោះ ប្រាក់ ហ៊ុន?

យុគៈ ម៉ែខ្ញុំឈ្មោះ សោម ហឿន ។

ដានីៈ អ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

យុគៈ បងប្អូនបង្កើតខ្ញុំ៣នាក់ ។

ដានីៈ បងប្អូនបង្កើតទាំងអស់តែ៣នាក់ទេ?

យុគៈ បងប្អូន៤នាក់ ស្លាប់១ នៅសល់៣ ។

ដានីៈ បងប្អូនទាំងអស់៤នាក់?

យុគៈ ចា៎ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

យុគៈ ស្រី២ ប្រុស២ ។

ដានីៈ ទី១?

យុគៈ បងខ្ញុំនៅស្រុក?

ដានីៈ ស្រី ឬប្រុស?

យុគៈ ប្រុស ។

ដានី៖ គាត់ឈ្មោះអីដែរ?

យុត៖ ប្រាក់ តុប ។

ដានី៖ គាត់នៅស្រុកឥឡូវ?

យុត៖ ចាស់ហើយ មិនដឹងស្លាប់នៅ ។

ដានី៖ បាទ?

យុត៖ គាត់ប៉ែតសិប ។

ដានី៖ អាយុ៨០ គាត់អាយុច្រើន គាត់នៅស្រុកកំណើតនៅក្បាលអូរហ្នឹង?

យុត៖ ចា៎ ។

ដានី៖ ទី២អ៊ំ?

យុត៖ ទី២ស្រុកកំណើតនៅកំពត នៅឃុំណាចេះ?

ដានី៖ បង?

យុត៖ ប្អូនពៅខ្ញុំ ទី២ខ្ញុំ ទីពៅប្អូនពៅ "ប្រាក់ សោមងិន" ។

ដានី៖ ដាក់ឈ្មោះ សោម ងិន ឈប់ដាក់"ប្រាក់"ហើយ?

យុត៖ ដាក់ខាងម៉ែមួយ ។

ដានី៖ គាត់នៅណាឥឡូវ?

យុត៖ នៅកំពតតែមិនដឹងឃុំអីទេខ្ញុំមិនបានចាំ ។

ដានី៖ ស្រុកអីគេ?

យុត៖ មិនដឹងស្រុកអីទេ ខ្ញុំភ្លេចអស់ហើយ ។

ដានី៖ ចុះអ៊ំថា៤នាក់ នេះទើបតែបាន៣នាក់?

យុត៖ ស្លាប់មួយ ។

ដានី៖ ស្លាប់ទីប៉ុន្មាន?

យុត៖ តាំងពីយូរ ។

ដានី៖ តាំងពីតូច?

យុត៖ តាំងពីតូច ។

ដានី៖ ហ្នឹងទីប៉ុន្មានដែលស្លាប់?

យុត៖ ហ្នឹងទី៤ ។

ដានី៖ ទី៤ ពៅគេ? កើតក្រោយគេ?

យុត៖ ពៅគេ តែវាស្លាប់នោះ ដាក់អានេះពៅប្រុស ។

ដានី៖ សោម និន ហ្នឹងស្រី ឬប្រុស?

យុត៖ ប្រុស ។

ដានី៖ អីចឹងស្លាប់ទី៤ហ្នឹងស្រី?

យុត៖ ស្រី ស្លាប់តាំងពីយូរ ។

ដានី៖ ឈ្មោះអីដែរស្លាប់តាំងពីយូរហ្នឹង?

យុត៖ មិនដឹងឈ្មោះអីទៀត ។

ដានី៖ ស្លាប់តាំងពីតូច?

យុត៖ ហ្នឹងហើយមិនបានចាំឈ្មោះទេវាតូច ។

ដានី៖ តាំងពីតូចអត់ចាំឈ្មោះទេ ។ អាយុប៉ុន្មានបានអត់ចាំឈ្មោះស្លាប់?

យុត៖ មិនដឹងអាយុប៉ុន្មានទេ កាលហ្នឹងខ្ញុំនៅតូចដែរ ។

ដានី៖ អ៊ំកាលពីក្មេងៗអ៊ំបានរៀនសូត្រអីដល់ណាដែរ?

យុត៖ ខ្ញុំ?

ដានី៖ បាទ ។

យុត៖ កាលជំនាន់ហ្នឹងថ្នាក់ទី១១ ថ្នាក់តិច?

វណ្ណៈ ៖ ថ្នាក់ទី១១ "ចាស់" ។

យុត៖ កុមារដ្ឋានតិច ។

ដានី៖ ថ្នាក់ទី១១? រៀនសាលាណាទៅ?

យុត៖ សាលាអនុវត្តជិតភូមិហ្នឹង ។

ដានី៖ ជិតភូមិក្បាលអូរហ្នឹង ។

យុត៖ ភូមិក្បាលអូរ ។

ដានី៖ កាលអ៊ំនៅក្មេងៗ អ៊ំថែមគាត់តំណាលៗអ៊ំដែរ ឬគាត់អាយុច្រើនជាង?

យុត៖ យាយថែម គាត់បងខ្ញុំ គាត់ចិតជាង ។

ដានី៖ ជាងចិតជាង?

យុត៖ ចាំ ។

ដានី៖ កាលអ៊ំរៀនថ្នាក់ទី១ អ៊ំថែម មានឃើញទៅរៀនដំណាលអ៊ំដែរ?

យុត៖ គាត់នៅភូមិខុសគ្នា គាត់ទៅរៀន បើកាលហ្នឹងភូមិក្បាលអូរមែនតែខ្ញុំនៅឆ្ងាយពីគាត់ ហើយគាត់នៅលិចនេះ ខ្ញុំនៅកើតនោះ ហើយមិនដឹងជាគាត់រៀនដល់ថ្នាក់ទីប៉ុន្មានខ្ញុំមិនបានដឹងដែរ ។ គាត់នៅភូមិក្បាលអូរ ខ្ញុំនៅភូមិត្រពាំងចំបក់ ដាក់ភូមិត្រពាំងចំបក់ ។

ដានី៖ ភូមិត្រពាំងចំបក់?

យុត៖ ហ្នឹងហើយត្រពាំងចំបក់ ។

ដានី៖ ប៉ុន្តែគេហៅក្បាលអូរៗដែរ?

យុត៖ ដាក់ជ្រៃគ្រួលក៏បានដែរភូមិខ្ញុំ ភូមិយាយថែម ភូមិក្បាលអូរ ។

ដានី៖ តែកាលពីក្មេងៗអ៊ំស្គាល់គាត់ដែរ?

យុត៖ ស្គាល់ដែរ តែឆ្ងាយពីគ្នាម្តងមួយយាម មិនបានទៅញឹកញាប់ ។

ដានី៖ ព្រោះឃើញអ៊ំអាយុ៦៨ដែរ ប្រហែលខុសគ្នា២-៣ឆ្នាំ ។

យុត៖ អត់ទេ យាយថែម គាត់បងខ្ញុំឡើងជិតដប់ឆ្នាំ គាត់ឆ្នាំរោង ។

ដានី៖ កាលហ្នឹងអ៊ំរៀនបានត្រឹមថ្នាក់ទី១១ទេ?

យុត៖ ចា៎ ។

ដានី៖ ចេះអាន ចេះសរសេរទេកាលហ្នឹង?

យុត៖ កាលហ្នឹងចេះដែរ ដល់ពេលខ្ញុំក្រពេក ម៉ែខ្ញុំឲ្យឈប់ ។

ដានី៖ រៀនបានប៉ុន្មានឆ្នាំដល់ថ្នាក់ទី១១?

យុត៖ រៀនតាំងពីអាយុប៉ុន្មានដប់ទេ ខ្ញុំអាយុ១៣-១៤ ម៉ែខ្ញុំឲ្យឈប់រៀនដោយសារអត់ពេក ។

ដានី៖ គាត់ថាយើងជីវភាពខ្វះខាត?

យុត៖ អត់មានអីដោះស្រាយជីវភាព ដល់ហើយទៅខ្ញុំបំរើគេស៊ីឈ្នួលស្ទូង ធ្វើខ្ញុំគេរហូត ។

ដានី៖ ប៉ុន្តែអ៊ំអាចអាន អាចសរសេរអីដោយខ្លួនឯងបាន?

យុត៖ ដល់ជំនាន់បដិវត្តន៍បានចេះ ។

ដានី៖ ដល់ជំនាន់បដិវត្តន៍បានចេះវិញ?

យុត៖ ចេះ ។

ដានី៖ គេបង្រៀនថែមទៀតឬយ៉ាងម៉េច?

យុត៖ បង្រៀនអី ដូចថាយើងធ្វើ យើងនៅកន្លែងកុមារខ្លះទៅ ហើយដល់អីចឹងគេមានគ្រូអក្ខរកម្មអីហ្នឹង កាលហ្នឹងយើងបង្កើត ដល់ហើយខ្ញុំចេះតែរៀនចូលនឹងគេខ្លះទៅ ។ កាលហ្នឹងយើង

អត់ចេះ ចេះអី និយាយរួមអារម្មណ៍យើងគិតតែរកស៊ី គិតយើងអត់ និយាយតែមួយម៉ាត់ឲ្យខ្ញុំអីចេះទៅ បើយើងអត់យើងគិតអានេះជាង អានេះយើងគិតរៀនអីអត់ទេ ។

ដានីៈ អ៊ំកាលហ្នឹងស្ថានភាពស្រុកភូមិយ៉ាងម៉េចបានយើងខ្វះខាត? ដោយសារយើងយ៉ាងម៉េចទៅ អ៊ំអាចរៀបរាប់ពេលហ្នឹង ជីវិតគ្រួសារអ៊ំ អ្នកស្រុក អ្នកភូមិ ម៉េចបានគាត់ខ្វះខាត?

យុតៈ ខ្វះខាតឥឡូវយើងនិយាយកេរ្តិ៍មរតក ។

ដានីៈ បាទ ។

យុតៈ ដូចថាកេរ្តិ៍មរតកម៉ែឪគេខាងអ្នកណាគេមានស្រែច្រើនគេម៉េចអត់ យើងអត់ស្រែ ស្រែតិចធ្វើម៉េចបានហូប បានតិចតួច ឧទាហរណ៍ដូចថាយើងធ្វើឆ្នាំ គេធ្វើមួយឆ្នាំគេហូបដល់ខែកក្តិក គេគ្រប់គ្រាន់ យើងហូបដល់ខែ៩អស់ហើយ យើងមានស្រែណាធ្វើស្រែតែតិចតួចអីចឹងវាក្រ ។

ដានីៈ ដល់ពេលក្រអីចឹងអ៊ំរៀនដល់ថ្នាក់ទី១១ ម្តាយអ៊ំគាត់?

យុតៈ ដល់ខ្ញុំក្រអីចឹង ខ្ញុំទៅរៀនម៉ែខ្ញុំថា មិនបាច់រៀនទេកូនអើយ ទៅស៊ីឈ្នួលគេទៅ យកស្រូវមកហូបដើម្បីចិញ្ចឹមគ្រួសារ បើកូនឯងទៅរៀនម៉ែធ្វើម៉េច បើកូនដល់៣នាក់ ម៉ែចិញ្ចឹមមិនរស់ទេ ខ្ញុំក៏ឈប់ ឈប់ទៅ ។

ដានីៈ កាលហ្នឹងឪពុករបស់អ៊ំគាត់នៅដែលតា៎?

យុតៈ អត់ទេ ស្លាប់តាំងពីយូរ ។

ដានីៈ ស្លាប់តាំងពីអ៊ំនៅតូចៗ?

យុតៈ ស្លាប់តាំងពីខ្ញុំនៅតូចៗ ម៉ែខ្ញុំគាត់ចិញ្ចឹមតា៎ កូន៣នាក់ ។

ដានីៈ មេម៉ាយគ្រួសារអ៊ំ?

យុតៈ ម៉ែខ្ញុំមេម៉ាយហ្នឹង ។

ដានីៈ ហើយដល់ពេលអីចឹងអ៊ំទៅស៊ីឈ្នួលអ្នកនៅស្រុកភូមិហ្នឹង ឬអ្នក?

យុតៈ ស្រុកភូមិហ្នឹង ។

ដានីៈ អ្នកណាដែលគេគ្រាន់?

យុតៈ អ្នកណាគេមានស្រូវច្រើន គេជួលយើងទៅ មួយថ្ងៃគិតមើលស្រូវគេមួយថាំងប៉ុន្មាន ដូចថាពីរថាំងហ្នឹង៥ថ្ងៃ ។

ដានីៈ ដូចថាយើងស៊ីឈ្នួលអីចឹង យើងយកជាស្រូវទេ មិនមែនយកលុយទេ?

យុតៈ យើងរកស្រូវមកបុកអង្ករហូប ចិញ្ចឹមជីវិត ។

ដានី៖	មិនមែនទៅស៊ីឈ្នួលដូចឥឡូវហ្នឹង  យើងទៅស៊ីឈ្នួលគេ  គេឲ្យលុយមកយើងទៅទិញអង្ករ ប៉ុន្តែជំនាន់ហ្នឹងអត់ទេ គេឲ្យជាអង្ករ ជាថាំង ជាគោ ។

យុគៈ	ជំនាន់កាលហ្នឹងអង្ករវាថោកទេ ដល់ស្រូវគេលក់ថ្លៃ  អង្ករកំប៉ុកវែងប្រវែងនេះ  មួយកំប៉ុង តែ៨បាត កាលហ្នឹងថ្លៃ ។

ដានី៖	នៅហ្នឹងគេហៅ៨បាត ឬ៨រៀល?

យុគៈ	៨រៀល កាលហ្នឹងលុយសម្តេច មិនដឹងប៉ុន្មាន ។

ដានី៖	រៀល គេអត់ហៅបាតទេ អ៊ំនៅនេះច្រើន ។

យុគៈ	ច្រលំ ។

ដានី៖	ដល់អីចឹងអ៊ំទៅស៊ីឈ្នួលតាំងពីឈប់រៀនតាំងពីអាយុ?

យុគៈ	១៣-១៤ ។

ដានី៖	១៣-១៤ហ្នឹងយើងចាប់ផ្តើមស៊ីឈ្នួលគេ?

យុគៈ	ស៊ីឈ្នួលរហូត ។

ដានី៖	ស៊ីឈ្នួលដល់ពេលណាទៅ?

យុគៈ	ដល់ពេលឆ្នាំ៦៧-៦៨ បងខ្ញុំគាត់នៅស្រុក គេហៅត្រពាំងគង ដល់ហើយគាត់ថាគាត់មាន ស្រែ  ឥឡូវទៅគាត់គាក់ជាមួយខ្ញុំទៅក្រែងល៎បាន២-៣អំពកអីគ្រាន់ចិញ្ចឹមជីវិត ។  ខ្ញុំនឹក ឃើញថាអាយុ១៥-១៦  ខ្ញុំទៅកាស់ដី  ស្រុកនៅត្រពាំងគង  ស្រុកលិចគេហៅព្រៃកក្កូច ដល់ហើយខ្ញុំក៏ទៅហ្នឹងទៅ  ខ្ញុំឈប់ដើរស៊ីឈ្នួលគេ  ខ្ញុំនឹកឃើញថាបើទៅកាស់ដីវាបានស្រែ ហូបព្រោះស្រែយើងនេះវាតិច ខ្ញុំក៏ទៅកាស់ដីហ្នឹងទៅ បងខ្ញុំគាត់មានដីគាត់ឲ្យ២ហិចតា ។

ដានី៖	បងអ៊ំ បងតុប ហ្នឹង?

យុគៈ	អត់ទេ បងជីដូនមួយ បងខ្ញុំគាត់អត់មានទេ ។

ដានី៖	គាត់ឈ្មោះអីទៅបងជីដូនមួយ?

យុគៈ	មិនដឹងឈ្មោះអី  កាលហ្នឹងគាត់ស្លាប់ហើយ ។  ដល់ហើយខ្ញុំទៅកាត់ដីបានធ្វើស្រែហ្នឹងបាន ១-២វស្សា ម៉ែខ្ញុំទៅហ្នឹងទាំងអស់គ្នា ធ្វើហ្នឹង ។

ដានី៖	នៅខាងត្រពាំងគង ព្រៃក្កូច នៅណា?

យុគៈ	ហ្នឹងហើយត្រពាំងគង ព្រៃក្កូចហ្នឹង ។

ដានី៖	នៅខាងតាកែវដដែល ឬនៅខាងកំពង់ស្ពឺហ្នឹង?

យុគៈ	កំពង់ស្ពឺ ព្រៃក្កូច-កំពង់ស្ពឺ ហើយត្រពាំងគងហ្នឹងកំពង់ស្ពឺ ។

ដានី៖ ស្រុកអីគេនៅហ្នឹង?

យុត៖ មិនដឹងស្រុកអីទេ ។

ដានី៖ ស្រុកបសេដ្ឋ, គងពិសី?

យុត៖ មិនដឹងគងពិសី ឬបសេដ្ឋ ខ្ញុំមិនបានសួរដែរ កាលហ្នឹងខ្ញុំចេះតែកាស់ មិនបាននឹកនារឿងស្រុកទេ ។

ដានី៖ មានភ្នំគេដែរ?

យុត៖ មានតាំ ។

ដានី៖ អ៊ំថែម គាត់ថាគាត់ធ្លាប់ទៅកាស់ព្រៃនៅភ្នំអីមួយ ។

យុត៖ នៅភ្នំដាច់ ។

ដានី៖ ហ្នឹងនៅជិតហ្នឹងដែរឬអត់ទេ?

យុត៖ ខ្ញុំនៅខាងត្បូងគាត់ ។

ដានី៖ នៅជិតៗគ្នាដែរ?

យុត៖ ជិតដែរ តែយើងមិនបានទាក់ទងគ្នាដែរទេ វាឆ្ងាយ កាលហ្នឹងយើងគ្មានឡាន គ្មានម៉ូតូទេ ដើរតែជើងហ្នឹង ។

ដានី៖ ប៉ុន្តែកាលយើងកាស់នៅត្រពាំងគង ព្រៃក្តួចហ្នឹងអត់សូវមានមនុស្សនៅទេ?

យុត៖ អត់ទេ អត់មានមនុស្សទេ កាលហ្នឹងសុទ្ធតែដីវាលធ្លឹង ។

ដានី៖ ទៅកាស់បានប៉ុន្មានហិចតាដែរគ្រួសារអ៊ំ?

យុត៖ យី! អូនអើយអូន កាស់មិនមែនចេះតែកាស់ណាំ សុទ្ធតែព្រៃដើមធ្លិត ឈើក្រំ ។

ដានី៖ ធំៗ?

យុត៖ ធំៗណាស់ កាស់មួយថ្ងៃគ្រាន់តែគល់ព្រិចមួយ កាស់ក្រឡឹងមិនចង់ដាច់ផង ។

ដានី៖ ហើយយើងស្រី?

យុត៖ ហើយយើងស្រី អាយុ១៥-១៦ ប្រវាស់ដៃគ្នា ។

ដានី៖ ហើយកាលហ្នឹងកាស់បានប៉ុន្មានទៅ?

យុត៖ ខ្ញុំកាស់បានប្រហែល១ហិចតាដែរ ធ្វើស្រែបានមុនដំបូងមិនទាន់ល្អទៀត ។

ដានី៖ អត់ទាន់ល្អទេ?

យុត៖ ដីល្អពេក ដូចថាវាអត់ផ្លែ ផ្លែតិចតួច ។

ដានី៖ ព្រៃល្អតែដើម?

យុត៖ ដូចថាវាផ្ទៃដែរ តែដីអត់ទាន់ចុះដីយើង បាន៤-៥បាវ ១០បាវ ។

ដានី៖ តែកាលហ្នឹងយើងហូបចុកគ្រប់គ្រាន់នៅ?

យុត៖ អត់គ្រប់ទេ បងប្អូនខ្ញុំគាត់នៅមុន គាត់ឲ្យស្រូវ ។

ដានី៖ គាត់ចែករំលែកឲ្យ?

យុត៖ គាត់ជួយ ក្មួយទៅអត់ ។

ដានី៖ ដល់ឆ្នាំ៦៧-៦៨ អ៊ំ, ម្ដាយអ៊ំ, បងប្អូនទៅនៅព្រែក្អួចទាំងអស់គ្នា? ផ្លាស់ផ្ទះទៅនៅ?

យុត៖ ចាំ នៅព្រែក្អួច ។

ដានី៖ ផ្ទះនៅស្រុកកំណើតបោះបង់ចោល?

យុត៖ ផ្ទះនៅស្រុកកំណើតបោះបង់ឲ្យបងប្អូននៅ ។

ដានី៖ ដល់នៅព្រែក្អួចធ្វើស្រែបានរយៈប៉ុន្មានទៅ?

យុត៖ ខ្ញុំធ្វើរយៈកាលយូរដែរ ២-៣ឆ្នាំដែរហ្នឹង ដល់ឆ្នាំ៧០ ។

ដានី៖ បាទ ដល់ពេលឆ្នាំ៧០យ៉ាងម៉េចទៀតទៅ?

យុត៖ ៧០ខ្ញុំមកតាមគេធ្វើបដិវត្តន៍ហ្នឹង ។

ដានី៖ ចូលធ្វើបដិវត្តន៍ហើយនេះ?

យុត៖ ចាំ ។

ដានី៖ អ៊ំអាចរៀបរាប់ពីមូលហេតុដែលអ៊ំចូលធ្វើបដិវត្តន៍? មូលហេតុអីបានយើងចូលធ្វើបដិវត្តន៍ ព្រោះអ៊ំផ្លាស់ទៅនៅព្រែក្អួច អ៊ំទៅកាប់ដីធ្វើស្រែចំការ ដល់ពេលឆ្នាំ៧០អ៊ំមានមូលហេតុអី បានអ៊ំទៅចូលបដិវត្តន៍?

យុត៖ កាលហ្នឹងមិនមែនទៅរកមូលហេតុទេ និយាយទៅតាមគ្នា គេចូលទៅយើងទៅនឹងគេ ។

ដានី៖ បានន័យថាអ្នកស្រុក អ្នកភូមិចូលទាំងអស់គ្នា ក៏យ៉ាងម៉េច?

យុត៖ អត់ទេ អ្នកណាគេចង់ទៅៗ អ្នកណាមិនចង់ទៅគេនៅផ្ទះ ។ ដូចថាសម័យនេះអីចឹង ដូចថា អ្នកណាគេចង់ទៅកាត់ដេរគេទៅ អ្នកណាអត់ចង់គេនៅផ្ទះ ដូចសម័យនេះអីចឹង ហើយខ្ញុំ ទៅដល់ឆ្នាំ៧០ខ្ញុំនៅកុមារ នៅមើលកន្លែងគេចិញ្ចឹមកុមារ ។

ដានី៖ នៅកន្លែងណាចិញ្ចឹមកុមារ?

យុត៖ ចិញ្ចឹមកុមារតូចៗ យើងទៅនៅជាមួយគេ ទៅមើលកូនក្មេង ឬក៏យើងនៅថែរក្សាកូនក្មេង អីជាមួយគេ ដូចថាគេបើកអក្ខរកម្មយើងរៀនជាមួយគេទៅ ខ្ញុំចេះអក្សរត្រឹមហ្នឹងដែរតាំ ។

ដានី៖ ដល់ពេលចេះអក្សរពីឆ្នាំ៧០ ពេលដែលយើងចូលបដិវត្តន៍ហ្នឹង?

យុត៖	ចាំ ។

ដានី៖	អ៊ំពេលដែលយើងចូលបដិវត្តន៍ អ៊ំចេញពីព្រែក្តួចមកចូលបដិវត្តន៍នៅណាទៅ?

យុត៖	ចូលនៅណាទេកាលហ្នឹង នៅកន្លែងដីកំពង់ស្ពឺទេខ្ញុំ មិនមែននៅតាកែវទេ ។

ដានី៖	នៅដីកំពង់ស្ពឺនៅឡើយទេ?

យុត៖	ចុះគេនៅហ្នឹងគេអ្នកដឹកនាំនៅហ្នឹង គេហៅឲ្យយើងចូល ។

ដានី៖	ពីណាគេ កាលហ្នឹងហៅ?

យុត៖	ឈ្មោះអីទេខ្ញុំមិនបានស្គាល់ វាយូរពេកហើយ មិនដឹងពីណាខ្លះ ។

ដានី៖	ចុះកាលហ្នឹងតាម៉ុកអីគាត់ដើរធ្វើការ?

យុត៖	តាម៉ុក ដល់ឆ្នាំ៧១-៧២ខ្ញុំជួបគាត់ ។

ដានី៖	ជួបគាត់នៅកំពង់ស្ពឺហ្នឹងដែរ?

យុត៖	ហ្នឹងហើយ គាត់មកនៅកន្លែងកងទ័ព យើងនៅកុមារមកជួបគាត់ដែរហ្នឹង ។

ដានី៖	ដល់ពេលអ៊ំយើងចូលបដិវត្តន៍ហើយ ម្តាយ បងប្អូនអ៊ំគាត់នៅព្រែក្តួច?

យុត៖	នៅជាមួយបងប្អូនខ្ញុំ ។

ដានី៖	គាត់នៅព្រែក្តួចដដែល ឬផ្លាស់មកនៅស្រុកកំណើតវិញ?

យុត៖	គាត់នៅហ្នឹង នៅធ្វើស្រែ ។

ដានី៖	គាត់នៅធ្វើស្រែនៅព្រែក្តួចហ្នឹងដដែល?

យុត៖	នៅជាមួយបងប្អូនខ្ញុំ គេអ្នកធ្វើហើយមុន ។

ដានី៖	ឆ្នាំ៧០ដែលអ៊ំចូលបដិវត្តន៍ហ្នឹង មានរដ្ឋប្រហារហើយ ឬចូលធ្វើតាំងពីមុនរដ្ឋប្រហារហ្នឹងទៀត?

យុត៖	រដ្ឋប្រហារអគ្គតាសោមហ្នឹង?

ដានី៖	អត់ទេ រដ្ឋប្រហារ បានន័យថាគេធ្វើរដ្ឋប្រហារទម្លាក់សម្តេច?

យុត៖	ទម្លាក់សម្តេច ខ្ញុំមិនដឹងធ្វើក្រោយ ឬធ្វើមុនទេនេះ កាលហ្នឹងខ្ញុំមិនបានចាំទៀត និយាយរួមវាមិនបានយល់ ។

ដានី៖	អត់សួរយកចិត្តទុកដាក់?

យុត៖	អត់យកចិត្តទុកដាក់ ដល់អីចឹងអត់មានចាំ ។

ដានី៖	ខែណាដែលអ៊ំចូលទៅ?

យុត៖	វាមិនចាំខែទៀត ។

ដានី៖ មានខែធ្លាក់ភ្លៀងហើយ ឬក៏នៅខែក្តៅហែង មុនចូលឆ្នាំខ្មែរ ក្រោយចូលឆ្នាំខ្មែរ?

យុត៖ អត់មានចាប់អារម្មណ៍ ។

ដានី៖ អត់ចាប់អារម្មណ៍ទេ?

យុត៖ និយាយរួមចេះតែទៅហែរគេ ហែរឯង យើងមិនទាន់អ្នកភ្ញាក់រលឹកណា ។

ដានី៖ កាលហ្នឹងចូលគ្នាច្រើនទេអ៊ំ?

យុត៖ ទៅគ្នាច្រើន កូនក្មេងទៅ ។

ដានី៖ នៅចាំទេថាកូនក្មេងៗដំណាលគ្នា យើងទៅតាមគ្នា?

យុត៖ ទៅតាមគ្នា ។

ដានី៖ ពីណាគេខ្លះអ៊ំនៅចាំ?

យុត៖ មិនដឹងពីណាខ្លះទេ កូនក្មេងៗទៅនៅកន្លែងកុមារ ។

ដានី៖ អ៊ំអាចនឹកបន្តិចមើលថា?

យុត៖ នឹកមិនឃើញទេ ។

ដានី៖ ចាំទេគ្នាប៉ុន្មាននាក់ដែរ? ដល់ពេលអ៊ំទៅនៅកន្លែងកងកុមារហ្នឹង កងកុមារនៅម្តុំណាទៅ?

យុត៖ កាលហ្នឹងមិនដឹងនៅភូមិអីទេ គេហៅទៅនៅគេប្រាប់ភូមិដែរ តែយើងមិនបានចាប់អារម្មណ៍ទុក ។

ដានី៖ ម្តុំអីគេ?

យុត៖ នៅម្តុំគេហៅស្អីទេ ភ្លេចអស់ហើយច្រើនពេក ។

អ្នកជិតខាង៖ បសេដ្ឋ?

យុត៖ មិនមែនទេ ម្តុំណាទេខ្ញុំមិនបានចាំទេអូន មិនដឹងកន្លែងណា ។

ដានី៖ កាលហ្នឹងកុមារច្រើនទេ កាលពេលអ៊ំទៅនៅ?

យុត៖ ច្រើនដែលតា តែកាលហ្នឹងមិនទាន់ធ្វើអីទេ គ្រាន់តែយកកុមារទៅគេបណ្តុះបណ្តាលឲ្យនៅមន្ទីរអប់រំកូនក្មេង យើងអត់មានទាន់ធ្វើអីទេ គ្រាន់តែអប់រំគ្នា ដូចថាកូនក្មេងច្រើនអីចឹងយើងចូលទៅមួយ អានេះមកពីនេះ អានោះមកពីនោះ យើងជុំគ្នា ប៉ុន្តែថាឲ្យធ្វើអីអត់ទាន់ធ្វើអីទេ ព្រោះវាក្មេងៗ ។

ដានី៖ ក្មេងៗបានមកពីណាទៅ?

យុត៖ ក្មេងៗឧទាហរណ៍ថានៅភូមិក, ភូមិខ, ភូមិគ អីគេចូលចិត្តចង់ចេញៗទៅ ១៥-១៦អីចេះតែនាំគ្នាចេញទៅ ។

ដានី៖ កាលហ្នឹងអ៊ំអាយុប៉ុន្មានហើយ?

យុត៖ ខ្ញុំអាយុប៉ុន្មានដប់ទេ ដូច១៥អីប៉ុន្មានទេ ។

ដានី៖ អ៊ំថាឈប់រៀន ៦៧-៦៨ អ៊ំអាយុ១២-១៣?

យុត៖ ១៦-១៧ហើយ ។

ដានី៖ នៅក្មេងៗដែរ?

យុត៖ នៅក្មេង ។

ដានី៖ អ៊ំទៅមើលគេ ឬអ៊ំទៅចូលរៀនជាមួយគេ?

យុត៖ ខ្ញុំទៅមើលគេ គេបង្រៀន ខ្ញុំមិនមែនអ្នកបង្រៀនទេ ។

ដានី៖ បានន័យថាយើងទៅមើលក្មេងកុមារហ្នឹង ជួយមើលគេទៅ?

យុត៖ ជួយមើលគ្នា ដូចថានៅកន្លែងក្មេងកុមារ ។

ដានី៖ ហើយគេបង្រៀនក្មេងៗបង្រៀនអក្សរ ឬបង្រៀន?

យុត៖ បង្រៀនអក្សរ ។

ដានី៖ ហើយគេមានអប់រំយើងឲ្យយល់ដឹងពីបដិវត្តន៍យ៉ាងម៉េចខ្លះទៅ?

យុត៖ គេពន្យល់តាំ យើងចូលបដិវត្តន៍ហើយយើងមិនយល់ ។

ដានី៖ ពន្យល់យ៉ាងម៉េចទៅមានចាំទេ?

យុត៖ ពន្យល់ថាឲ្យយើងចេះស្រឡាញ់គ្នា សាមគ្គីគ្នា កុំឈ្លោះគ្នា យើងចូលមកកន្លែងនេះដូចឪពុកម្ដាយតែមួយអីចឹង ។

ដានី៖ គេនិយាយអីចឹង?

យុត៖ យើងកុំវ៉ៃតប់គ្នា បែកបាក់ ។

ដានី៖ តាម៉ុក គាត់ធ្លាប់ទៅនិយាយប្រាប់?

យុត៖ អត់ទេ គាត់មិនដែលចូល ។

ដានី៖ ពីណាអ្នកនិយាយឲ្យយើងចេះស្រឡាញ់គ្នា?

យុត៖ ហ្នឹងដូចថាមានប្រធានគេនៅហ្នឹងស្រី ឈ្មោះអីទេ គេនៅហ្នឹងគេអប់រំ មានស្រី មានប្រុសគេ ធំៗណាស់ ដូចថាគេខាងអប់រំកុមារចឹង យើងមិនបានចាំឈ្មោះទេ តាំងពីឆ្នាំ៦៥-៦៦ ។

ដានី៖ អ៊ំចូលតាំងពីហ្នឹងមក?

យុត៖ ខ្ញុំមិនចូលតាំងពីហ្នឹងទេ ខ្ញុំទៅនៅហ្នឹងតាំង៦៧ឃើញទេ ៦៨-៦៩ខ្ញុំមកធ្វើកូនក្មេង ។

ដានី: អីចឹងអ៊ំចូលមុន៦០ទៀត ចូលនៅជាមួយកូនក្មេង?

យុត: ចាំ៎ ។

ដានី: គាំងពីហុកប៉ុន្មានទៅ ៦៩?

យុត: មិនដឹងហុបប៉ុន្មានទេ ។

ដានី: ដែលយើងធ្វើការងារដាប់លាប់ពី៧០ ឬក៏យ៉ាងម៉េច?

យុត: ៧០ ដាប់លាប់អាហ្នឹងបានមកនៅកងចល័ត ។

ដានី: ឆ្នាំ៧០ មកនៅកងចល័ត?

យុត: កងចល័ត ។

ដានី: បានន័យថាយើងចូលជាមួយកុមារគាំងពីហុកប៉ុន្មានទៅ?

យុត: ៦៧-៦៨ហ្នឹង ។

ដានី: ដល់ពេលឆ្នាំ៧០ បានន័យថាយើងដាច់ពីផ្ទះហើយយើងមកនៅកងចល័ត?

យុត: ដាច់ហើយ មកនៅកងចល័ត ។

ដានី: មកនៅកងចល័តនៅណា?

យុត: កងចល័តនៅក្នុងព្រៃ ។

ដានី: មុំណា?

យុត: នៅណាទេ ក្មួយ និយាយរួមយើងចេះតែធ្វើ តែការពិត ការចាប់អារម្មណ៍ទុកវាអត់មាន ចេះតែធ្វើៗហែរគេក៏បាន ។

ដានី: ដល់ពេលកងចល័តគ្នាច្រើនទេអ៊ំ?

យុត: ច្រើន កងចល័តលើកទំនប់ កូនក្មេងលើកទំនប់ដែរកាលហ្នឹង ។

ដានី: អីចឹងចាប់ពីឆ្នាំ៧០ មានកងចល័ត មានលើកទំនប់?

យុត: មានតាំ៎ មានដូចថាមិនទាន់ធ្វើខ្លាំងទេ ដូចថាមានអូរនាំគ្នាទប់យកធ្វើស្រែប្រាំងនាយអាយ មិនទាន់ថាទំនប់ធំៗទេ ។

ដានី: ទំនប់ហ្នឹងធ្វើនៅក្នុងខេត្តកំពង់ស្ពឺ ឬយើងផ្លាស់មកតាកែវ ឬកំពត?

យុត: កាលហ្នឹងខ្ញុំនៅកងចល័តត្រឡប់ពីកំពង់ស្ពឺមកវិញហើយ ខ្ញុំមកនៅតាកែវវិញ ។

ដានី: ខាងជីវរមៀល?

យុត៖ ហ្នឹងហើយ មកខាងដីរីរមៀល យើងមកនៅហ្នឹងតែដូចថាយើងមិនទាន់មានអីជាធំដុំទេ គ្រាន់ថាគាត់អ្នកនៅហ្នឹងដឹកនាំឲ្យយើងធ្វើកូនទំនប់តូចតាច ដើម្បីយកទឹកហូបព្រោះយើងនៅអត់មានទឹក វាវីង ។

ដានី៖ កាលហ្នឹងគ្នាច្រើនទេនៅលើភ្នំ?

យុត៖ គ្នាច្រើន ។

ដានី៖ ប្រហែលជាប៉ុន្មានបើតាមអ៊ំចាំ?

យុត៖ ប្រហែលជា១០០នាក់, ៥០នាក់ បើតាមមើល ។

ដានី៖ កាលហ្នឹងដូចថាក្រុមអ៊ំប្រហែលមានគ្នា ៥០-១០០នាក់? តែក្រុមផ្សេងកាលហ្នឹងខ្ញុំជួបអ៊ំថែម ជួបអ្នកផ្សេងថាមានផ្នែកច្រើនៗទៀត មានផ្នែកកងទ័ព ផ្នែកខាងនារី ខាងយុវជនគេនៅហ្នឹងដែរ អីចឹងអ៊ំ?

យុត៖ មានតាំ គ្រប់ផ្នែក តែខ្ញុំនៅកន្លែងកុមារអីចឹង គេឲ្យធ្វើអីធ្វើហ្នឹងហើយ នៅមានកន្លែងគេផ្សេងៗមានហើយ តែមិនដឹងគេឲ្យធ្វើអីៗយើងមិនដឹង ។

ដានី៖ ប៉ុន្តែដល់ពេលយើងមកប្រជុំ ដូចជាយើងរួម ដាក់ផែនការ ដាក់ទិសយើងត្រូវធ្វើនេះលើកនេះ គេមានប្រជុំរួមទេ?

យុត៖ ប្រជុំមេគេទៅដែរ ។

ដានី៖ ពីណាគេ?

យុត៖ ប្រធានគេមិនដឹងឈ្មោះអីខ្ញុំមិនបានចាំ ។

ដានី៖ មិនមែនតាម៉ុកទេ?

យុត៖ អត់ទេ មិនមែនតាម៉ុកទេ នៅវាយរង ។

អ្នកជិតខាង៖ អៀង សារី?

យុត៖ អៀង សារី ណាទៅប្រជុំទេ អៀង សារី នៅបរទេស គេខាងក្រសួងការបរទេស ។

ដានី៖ ពីណាគេ?

យុត៖ អៀង សារី ។

ដានី៖ ហើយនៅខាងដីរីរមៀលដែលគេប្រជុំហ្នឹង ដូចថាខ្ញុំចង់ដឹងហ្នឹង គ្រាន់តែថាការងារជាដូចថាចង្វាក់គេមានគ្រប់ផ្នែកយើងត្រូវធ្វើការងារអីខ្លះ? យុវជនក្មេងយើងត្រូវធ្វើការងារអី? មនុស្សចាស់ ឬក៏យុវជន យុវនារី ខាងអីហ្នឹង ។ ដូចថាពេលគេប្រជុំម្តងៗគេច្រើនតែនិយាយរឿងអី មិនមែនតាម៉ុក ទេគាត់អ្នកដឹកនាំប្រជុំ?

យុគៈ	តាម៉ុក គាត់មិនបានមកទេ តាម៉ុក គាត់ប្រជុំ ដូចថាកន្លែងកុមារគេមានមេគេ៣នាក់អីចឹង ដូចយុទ្ធជនមានមេគេទៀតទៅ អានេះគេឡើងប្រជុំមេៗដែរ ។

ដានី៖	ដូចតាសោម អីគាត់ទៅប្រជុំហ្នឹងដែរ?

យុគៈ	តាសោម អត់ទេ កាលហ្នឹងខ្ញុំមិនបាននៅជាមួយតាសោមផង គ្រាន់ថានៅខាងក្រោម តាសោម គាត់នៅខាងលើយើងមិនបានដែរ ។

ដានី៖	តាសោម កាលហ្នឹងគាត់គណៈតំបន់នៅ?

យុគៈ	គណៈតំបន់តាកែវ ។

ដានី៖	តាំងពីឆ្នាំចិតជាងមក? ៧០មក?

យុគៈ	តាសោម ធ្វើឆ្នាំ៧០ អីម៉េច?

ដានី៖	ឆ្នាំ៧០ គាត់មានទៅជីវិរមៀល? គាត់ដឹកនាំប្រជុំ?

យុគៈ	គាត់នៅហ្នឹងតាំ ឆ្នាំ៧០គាត់នៅតាកែវ តែការដឹកនាំទាំងអស់ហ្នឹងយើងមិនបានជួបគាត់ទេ គេថ្នាក់លើ អីចឹងនៅកន្លែងខ្ញុំ ខ្ញុំដឹងតែមេខ្ញុំ ។

ដានី៖	ពីណាខ្លះ?

យុគៈ	ដូចថាមានឈ្មោះអីៗ ដូចថាអ្នកណាខ្លះ ប្រុស១ ស្រី២ ហើយអីចឹងយើងចេះតែនៅជាមួយគេហ្នឹងទៅ គេនាំយើងធ្វើអីយើងធ្វើហ្នឹង ។

ដានី៖	នៅជីវិរមៀលបានរយៈពេលប៉ុន្មានឆ្នាំដែរ?

យុគៈ	ខ្ញុំនៅមើលឆ្នាំ៧០-៧២ ដូច៣ឆ្នាំដែរខ្ញុំចូលទៅ ។

ដានី៖	ដល់ឆ្នាំ៧២?

យុគៈ	ចាំ ខ្ញុំនៅរហូតហ្នឹង ។

ដានី៖	កាលហ្នឹងមានដូចថាយើងចូលបដិវត្តន៍នៅជីវិរមៀល ហើយខស្សប្ដាហ៍មកលេងផ្ទះ ជួបម្ដាយ ជួបបងប្អូនអីទៀតដែលអត់?

យុគៈ	ខ្ញុំមកម្ដងដែរ ខ្ញុំអត់ដែលមកទេតាំងពីចូល៧០មករហូតដល់៧២-៧៣ខ្ញុំទៅលេងម៉ែខ្ញុំ ទៅតែម្ដងហ្នឹង ។

ដានី៖	កាលហ្នឹងម្ដាយរបស់អ៊ំនៅណាទៅ?

យុគៈ	ម៉ែខ្ញុំនៅតាកែវ នៅកន្លែងភូមិម៉ិញហ្នឹង ។

ដានី៖	ត្រឡប់មកពី?

យុគៈ	គាត់ត្រឡប់មកវិញហើយ គាត់ឃើញសឹកសង្គ្រាមគាត់ខ្លាច ។

ដានី: មកព្រៃក្តួច មកខាងក្បាលអូរវិញ?

យុត: មកក្បាលអូរវិញ គាត់ថានៅនោះខ្លាច វានៅជិតព្រៃ គាត់ខ្លាចខ្មែរក្រហម ។

ដានី: ខ្លាចខ្មែរក្រហមម៉េចបើអ៊ំចូលខាងខ្មែរក្រហម?

យុត: ចូលខ្មែរក្រហមខ្ញុំអ្នកចូលនេះ គាត់មិនមែនអ្នកទាន់ចូលណា គាត់ខ្លាច ។

ដានី: គាត់អត់ខ្លាចខាងលន់ នល់វិញទេ?

យុត: អត់ មិនដឹងម៉េចគាត់ថាអ៊ីចឹង ។ ចុះម៉ែឯងម៉េចមកចោលស្រែ គាត់ថាអញមិនហ៊ាននៅព្រៃច្រើន ហើយយើងនៅអត់មានប្តីប្រពន្ធណាការពារគ្នា គាត់នៅស្រុក ។

ដានី: អ៊ីចឹងឆ្នាំ៧២បានអ៊ំបានជួបទៅលេងម្តាយ?

យុត: ចា៎ ទៅលេងម៉ែ ។

ដានី: ដល់ពេលទៅលេងបានប៉ុន្មានថ្ងៃដែរ?

យុត: ខ្ញុំទៅបានមួយយប់ ។

ដានី: តែមួយយប់ទេ?

យុត: ចា៎!

ដានី: ចុះបែកគ្នាយូរតាំងពី?

យុត: ចុះម៉ែខ្ញុំមិនចង់ហ៊ានឲ្យនៅទេ កាលហ្នឹងយើង៧០មិនទាន់សុខសាន្តទេ នៅវាចលាចល គេនៅរកកូនសួរម៉ែ អ៊ីចឹងគាត់ខ្លាច គាត់ថាមិនបាច់ទៅយូរទេកូនឯងទៅវិញទៅ គេស្រាវជ្រាវយើង គេនៅរករឿងដែលតាំកាលហ្នឹងមិនទាន់នេះណា ហើយខ្ញុំក៏មិនហ៊ានទៅយូរដែរ ហើយទៅរទេះសេះទៀត អត់មានស៊ីជិះ ពីហ្នឹងទៅតាកែវឆ្ងាយដែរ ។ ម៉ែខ្ញុំថាមិនបាច់នៅយូរទេកូន ។

ដានី: គាត់ថាអ៊ីចឹង មិនបាច់នៅយូរឲ្យមកវិញ?

យុត: ហ្នឹងហើយ ។

ដានី: តែគាត់អត់មានព្រួយបារម្ភពីអ៊ំថាទៅឆ្ងាយ សុខទុក្ខអីម៉េចគាត់មានព្រួយបារម្ភអីដែរ?

យុត: គាត់ព្រួយដែរតែមិនដឹងធ្វើម៉េច បើគាត់កូនមកនៅអ៊ីចឹងហើយគាត់មិនដឹងធ្វើម៉េច គាត់ព្រួយដែរ គាត់ថា«អញស្មានតែឯងស្លាប់បាត់ហើយ កូនអើយ» ។

ដានី: គាត់ថាអ៊ីចឹងដែរ?

យុត: ហ្នឹងហើយ ចុះខ្ញុំទៅយប់ កាលហ្នឹងសភាពការណ៍ក៏មិនទាន់ស្អាតដែរ ។

ដានី: សភាពការណ៍នៅយ៉ាងម៉េច?

យុត៖ មិនទាន់ថាគេធ្វើអីយើងទេ តែយើងចេះតែប្រយ័ត្នទៅ ព្រោះយើងចូលឆ្នាំ៧១-៧២ ដូចថាយើងនៅប្រុងប្រយ័ត្នដែរ ។

ដានី៖ អ៊ំពេលចេញពីឆ្នាំ៧២ ចេញមកពីលេងផ្ទះត្រឡប់ទៅណាវិញទៅ?

យុត៖ ខ្ញុំ?

ដានី៖ បាទ ។

យុត៖ នៅហ្នឹងរហូតតា៎!

ដានី៖ អីចឹងពីឆ្នាំ៧២ មកលេងផ្ទះហើយត្រឡប់ទៅខាងណាវិញ?

យុត៖ ដល់ឆ្នាំចិតប៉ុន្មានទេ អត់មានទាប់ត្រឡប់ទេ ខ្ញុំនៅហ្នឹង២-៣ឆ្នាំ ។

ដានី៖ នៅណា?

យុត៖ នៅតាកែវហ្នឹង ៧១, ៧២, ៧៣ ខ្ញុំនៅ៣ឆ្នាំនេះ ។

ដានី៖ នៅដីរីរមៀលហ្នឹង?

យុត៖ អត់ទេនៅតាកែវ ហ្នឹងហើយនៅដីរីរមៀល ។

ដានី៖ នៅតាកែវបានន័យថា នៅកន្លែងផ្សេង ឬនៅដីរីរមៀល?

យុត៖ នៅដីរីរមៀល នៅភ្នំហ្នឹង ។

ដានី៖ នៅលើភ្នំនៅម្តុំណាទៅ?

យុត៖ មិនដឹងនៅម្តុំណាទេ កាលហ្នឹងខ្ញុំមិនស្គាល់ភ្នំហ្នឹងផង ចេះតែនៅជាមួយគេ ។

ដានី៖ នៅដល់៧៣?

យុត៖ ចា៎ ។

ដានី៖ ដល់ពេលពី៧៣ អ៊ំផ្លាស់ទៅនៅណាទៀត?

យុត៖ ខ្ញុំទៅនៅកំពត ។

ដានី៖ ឆ្នាំ៧៣ទៅនៅកំពតវិញ?

យុត៖ ចា៎!

ដានី៖ ខាងយើងរំដោះបានហើយ?

យុត៖ ចា៎! រំដោះបាន ។

ដានី៖ អីចឹងកាលពី៧១-៧២-៧៣ អ៊ំនៅកន្លែងកុមាររហូត?

យុត៖ ចា៎!

ដានី៖ កាលហ្នឹងយើងនៅជាមួយកុមាររៀនសូត្រ ដូចថាអ៊ំបានរៀនអក្សរកាន់តែចេះច្រើន?

យុគៈ ហ្នឹងហើយ ។

ដានីៈ ចេះសរសេរ?

យុគៈ ខ្ញុំនៅហ្នឹងបានចេះ ។

ដានីៈ ហើយមានធ្វើអីទៀតក្រៅពីកុមារ?

យុគៈ អត់ទេ ខ្ញុំអត់មានធ្វើអីទេ ខ្ញុំនៅកន្លែងកុមារ ។

ដានីៈ កុមារមានធ្វើពលកម្មដែលអត់?

យុគៈ ធ្វើតាំ ដូចថាបោសផ្ទះ លាងឆ្នាំង អត់មានធ្វើអីខ្លាំងទេ ធ្វើតែប៉ុណ្ណឹង យើងមិនទាន់បានគេចាត់ចែងឲ្យធ្វើការងារខ្លាំងៗ ព្រោះយើងនៅតូចៗ ហើយដល់ពេលខ្ញុំទៅកំពតខ្ញុំអាយុ១៨ឆ្នាំ ខ្ញុំនៅធ្វើទំនប់នៅស្រុកឈូក ។

ដានីៈ អីចឹងពីឆ្នាំ៧៣អីផ្លាស់ទៅធ្វើទំនប់វិញ?

យុគៈ ខ្ញុំទៅនៅកំពតតែម្តង អាហ្នឹងលែងមកហើយ ។

ដានីៈ ប៉ុន្តែទៅនៅកំពតហ្នឹង ទៅនៅ?

យុគៈ នៅម្តុំស្រុកឈូក គេហៅនៅភូមិតាមុល ខ្ញុំទៅនៅកន្លែងកាត់ដេរ ។

ដានីៈ មិនមែនទៅធ្វើទំនប់ទេ?

យុគៈ អត់ទេ ខ្ញុំច្រលំ កន្លែងកាត់ដេររបស់តំបន់កំពត ។

ដានីៈ កាត់ដេរនៅភូមិ?

យុគៈ ភូមិនិមល ។

ដានីៈ និមល នៅក្នុងស្រុកឈូក?

យុគៈ ស្រុកឈូក ។

ដានីៈ កន្លែងកាត់ដេរតំបន់ ។ អីចឹងកាលហ្នឹងពីឆ្នាំ៧៣ កំពតមានជាតំបន់អីហើយ?

យុគៈ យើងមានហើយ ។

ដានីៈ យើងគ្រប់គ្រង?

យុគៈ ចាំ គេមានកន្លែងគេ ។

ដានីៈ ដំបូងអ៊ំទៅកន្លែងកាត់ដេរហ្នឹង? កាត់ដេរគ្នាច្រើនទេ?

យុគៈ កាត់ដេរប្រហែល៥០នាក់ កាត់ដេរខោអាវកងទ័ព ។

ដានីៈ កាត់ដេរខោអាវកងទ័ព ខោអាវយ៉ាងម៉េច?

យុគៈ ខោអាវខ្មៅ ។

ដានី៖ សាច់អីគេ? គេគារុង, ប្រដីប ឬទេសឯក?

យុត៖ គេគារុង សុទ្ធតែក្រណាត់ខ្មៅ ។

ដានី៖ យើងបានក្រណាត់ពីណាមកកាត់ដេរ? ៣៨ ១៨

យុត៖ ចុះរដ្ឋជួយមក ។

ដានី៖ ហើយកាលហ្នឹងអីរៀនកាត់ដេរមកពីណាមក? ព្រោះអីនៅជាមួយកុមារ?

យុត៖ ខ្ញុំអត់រៀនទេ មេនៅហ្នឹងតែគេបញ្ជូនយើងទៅ តែគេបញ្ចូលកន្លែងកាត់ដេរ គេមានមេគេនៅហ្នឹងហើយស្រេចហើយ ។

ដានី៖ ដល់ពេលអីចូលទៅចេះកាត់ដេរទេ?

យុត៖ អត់ទេ ខ្ញុំអត់ចេះទេ គ្រាន់តែនៅហ្នឹងសិន យើងអត់ទាន់ចេះអីទាំងអស់ គ្រាន់តែយើងថាមានប្រធានគេនៅហ្នឹង ប្រធានឈ្មោះសារឿន (ស្រី) គេអ្នកណែនាំចេះកាត់ដេរ ហើយជាងប្រុស(ធឹម) ។

ដានី៖ ហើយប្រុសឈ្មោះ ធឹម ហើយស្រីឈ្មោះ សារឿន គាត់ចេះកាត់ដេរច្បាស់លាស់?

យុត៖ គាត់ចេះច្បាស់លាស់តែម្តង ។

ដានី៖ គាត់បង្រៀនកូនចៅ?

យុត៖ ៥០នាក់ហ្នឹងគេអ្នកបង្រៀន ។

ដានី៖ ដល់អីចេះដែលគេអ្នកបង្រៀន?

យុត៖ ខ្ញុំអត់ទេ កាលហ្នឹងខ្ញុំខាងដាំបាយ ខ្ញុំអត់ទៅទេ ។

ដានី៖ អត់ចូលចិត្តកាត់ដេរទេ?

យុត៖ អត់ទេ ។

ដានី៖ នៅដាំបាយឲ្យគេ?

យុត៖ ដាំបាយគេហូប ។

ដានី៖ ឈ្មោះធឹម ឈ្មោះសារឿន ហ្នឹងដំណាល១អីដែរ?

យុត៖ អត់ទេ ក្មេងតែគេធ្លាប់រៀនកាត់ដេរ ស៊ីឈ្នួលពីឆ្នាំ៧០-៧១អីចឹង គេនៅមិនទាន់បែកគេនៅកន្លែងរកស៊ី ដល់គេចេះអីចឹង អង្គការរើសគេមកឲ្យបង្រៀនយើង ។

ដានី៖ ប៉ុន្តែគាត់អាយុដំណាល១អីដែរទេ?

យុត៖ អត់ទេ វាប្រហែលជា១៧ ឬ១៨?

ដានី៖ ក្មេងជាងអីទេ?

យុត៖ ក្មេងទេ ។

ដានី៖ ក្មេងទេ សារឿន, ធីម ហ្នឹង?

យុត៖ ចាំ! តែខ្ញុំកាលហ្នឹងធំដែរហើយ ។

ដានី៖ គាត់នៅរស់ទេឥឡូវ?

យុត៖ មិនដឹងរស់អត់ បើខ្ញុំមិនដែលជួប ។

ដានី៖ អ៊ំទៅនៅកន្លែងគាត់ដេរហ្នឹងបានយូរទេ?

យុត៖ នៅយូរ ៧៣-៧៤ ខ្ញុំនៅបានយូរដែរ ។

ដានី៖ ពី៧៣ដល់ចិតប៉ុន្មានទៅ?

យុត៖ ៧៣-៧៤ ខ្ញុំចេញពីកាត់ដេរទៅនៅធ្វើទំនប់ គេឲ្យធ្វើទំនប់មួគ ។

ដានី៖ ធ្វើទំនប់នៅណាវិញ?

យុត៖ ធ្វើទំនប់នៅស្ទឹងប្រាំងនោះ ។

ដានី៖ ស្ទឹងប្រាំង? ស្ទឹងប្រាំងនៅណា?

យុត៖ នៅនរាយណ៍ ស្រុកឈូក ស្ទឹងប្រាំងតាមថ្នល់ស្រុកលេខ៣ហ្នឹង ។

ដានី៖ កាលហ្នឹងពី៧៣មកអត់មាន លន់ នល់នៅទេខាងកំពត?

យុត៖ អត់ទេ យើងរំដោះអស់ ទាហានខ្មែរយើងរំដោះ ។

ដានី៖ កាលហ្នឹងតំបន់គេនៅណាទៅ?

យុត៖ តំបន់កាលហ្នឹងនៅស្រុកឈូកហ្នឹង តែនៅក្រោយ នៅខាងស្រែក្នុង មុំភ្នំ.. កន្លែងធ្វើទំនប់ ។

ដានី៖ ឥឡូវគេហៅស្រុកជុំគិរី?

យុត៖ ហ្នឹងហើយជុំគិរី កាលហ្នឹងយើងអត់ទាន់ឡើងទៅនៅណាទេ នៅព្រៃទាំងអស់ ។

ដានី៖ ប៉ុន្តែកាលហ្នឹងមន្ទីរ តំបន់គេនៅក្នុង គេហៅភូមិអីគេ?

យុត៖ ភូមិព្រៃវែង ។

ដានី៖ ជិតស្នាយអញ្ចិត?

យុត៖ ហ្នឹងហើយ ស្នាយអញ្ចិត ភូមិហ្នឹងគេហៅភូមិខ្មែរក្រហម ។

ដានី៖ ភូមិព្រៃវែង គេហៅភូមិខ្មែរក្រហម ។

យុត៖ សមមិត្តសួន, តាណល់ នៅហ្នឹង

ដានី៖ អីចឹង ។ ខ្ញុំធ្លាប់ជួបអ៊ំដែន?

យុត៖ អ៊ំដែន ស្រុកគាត់នៅហ្នឹង គាត់នៅព្រៃវែង ។

ដានី៖ គាត់ឈ្មោះ ប៉ែ ផែន ឥឡូវគាត់ធ្វើអាចារ្យវត្ត ។

យុត៖ មិនមែនតាផែន ហ្នឹងទេដឹង ។

ដានី៖ តាផែន គាត់អ្នកស្រុកនៅហ្នឹង តែគាត់ធ្លាប់ធ្វើការតួនាទីត្រឹមឃុំ-ស្រុកអីចឹង ខ្ញុំធ្លាប់ជួបគាត់ដែរ នៅខាងហ្នឹង ចាស់ៗនៅហ្នឹង ។ កាលហ្នឹងមន្ទីរតំបន់គេនៅខាងភូមិព្រៃវែងតែម្តង?

យុត៖ ហ្នឹងហើយ ។

ដានី៖ មន្ទីរគេធ្វើជាផ្ទះអីត្រឹមត្រូវដែរ?

យុត៖ អត់ទេ ធ្វើតង់មុនដំបូង ។

ដានី៖ កាលហ្នឹងពីណាគេគណៈតំបន់?

យុត៖ កាលហ្នឹងតាចាប ។

ដានី៖ តាចាប គាត់ធ្វើហ្នឹងតាំងពី៧៣មក?

យុត៖ ៧៣មករហូត តែធ្វើមិនទាន់ថាយើងធ្វើនៅក្រុងទេ យើងលាក់ៗធ្វើនៅព្រៃនៅឡើយ ហើយខ្ញុំវិញធ្វើកាត់ដេរមែនសម័យនោះតែនៅព្រៃដែរ ។

ដានី៖ កាត់ដេរដែលអ៊ំថានៅភូមិនិមល ភូមិហ្នឹងនៅព្រៃដែរ?

យុត៖ ព្រៃតាំ ។

ដានី៖ យើងធ្វើមានជាម៉ាស៊ីនដេរនៅក្នុងហ្នឹង?

យុត៖ មានតែយើងលាក់ការណ៍ ។

ដានី៖ តែមានយន្តហោះទៅទម្លាក់គ្រាប់បែកដែរ?

យុត៖ អត់ទេ ។

ដានី៖ អត់ដឹងទេ?

យុត៖ យើងអត់ដែលឃើញ ។

ដានី៖ អត់ដែលឃើញយន្តហោះទៅទម្លាក់តាំងពី៧១-៧២?

យុត៖ ទម្លាក់ តែទម្លាក់ជុំវិញ កន្លែងកាត់ដេរហ្នឹងគិញយកការណ៍អត់ច្បាស់ វាទម្លាក់អត់ចំ ។

ដានី៖ ចុះកាលនៅដីរមៀលអីមានដែលទេ?

យុត៖ ដីរមៀលទម្លាក់ជុំវិញដែរ ទម្លាក់លើភ្នំ ទម្លាក់ខាងៗអីចឹងដែរ និយាយទៅខ្ញុំដូចមានទេពកោសលដែរ កំរមានយន្តហោះទម្លាក់ណាស់ ។

ដានី៖ យើងចេះលាក់ការណ៍ខ្ពស់?

យុគៈ ហ្នឹងហើយឲ្យតែលាក់ការណ៍ខ្ពស់គឺជីវិតយើងក៏ខ្ពស់ដែរ ។

ដានីៈ មានពាក្យស្លោកមួយខាងអ៊ំ ពូ មីងគាត់ធ្លាប់និយាយ គាត់ថាលាក់ការណ៍ខ្ពស់ រស់បានយូរ អាហ្នឹងវាមានពាក្យស្លោកអីចឹងដែរ ឬអត់ទេ?

យុគៈ បើមិនមានអីចឹង ម៉េចយកបានមកនេះ ។

ដានីៈ អីចឹងមានន័យថាបើយើងចេះលាក់ការណ៍បានខ្ពស់ យើងរស់បានយូរ?

យុគៈ កន្លែងមន្ទីរតំបន់ហ្នឹងមូលហេតុអីបានទៅនៅកន្លែងហ្នឹង? កន្លែងហ្នឹងប្រជាជនលាក់ការណ៍ យើងរស់នៅមានប្រជាជនមិនអីចឹង បើអត់មានប្រជជនដែលរស់នៅ ឧទាហរណ៍យើងនៅហ្នឹងក៏ដោយ ប្រជាជនអត់ប្រាប់ប្អូនឯងរកផ្ទះខ្ញុំឃើញ រកមិនឃើញទេងាប់អើយ បើយើងបញ្ឆេះថាអ្នកណាសួរឯង ឯងមិនបាច់និយាយទេ វានិយាយតែមួយម៉ាត់ហ្នឹងក៏គេមិនប្រាប់អូនឯងដែរ ប៉ុន្តែយើងលាក់ការណ៍ធ្វើអី យើងឡើងតុលាការប្រប៉ុណ្ណាណី ខ្ញុំមិនខ្លាចទេ យកខ្ញុំទៅណា ខ្ញុំគិតហើយអស់ អីចឹងបានគេថាស៊ីសងលើប្រជាជនហ្នឹងហើយ ។

ដានីៈ អីចឹងតាចាប គាត់អ្នកស្រុកកំណើតនៅកំពតហ្នឹងតែម្តង?

យុគៈ មិនដឹងនៅណាទេ ខ្ញុំមិនបានស្គាល់ដែរ មិនដឹងស្រុកកំណើតគាត់នៅណា ។

ដានីៈ តែឃើញពេលអ៊ំទៅនៅកំពត?

យុគៈ ដល់ពេលគាត់មកនៅហ្នឹងស្គាល់គាត់បណ្តោយ ។

ដានីៈ កាលហ្នឹងគាត់ចំណាស់ណាស់? គាត់ដំណាលអ៊ំ?

យុគៈ គាត់នៅក្មេងដែរ អត់ទេ គាត់បងខ្ញុំច្រើនដែរ ។

ដានីៈ គ្នាប៉ុន្មាននាក់គាត់គណៈតំបន់ គ្នាគាត់?

យុគៈ មិនដឹងតំបន់គាត់ប៉ុន្មាននាក់ទេ ខ្ញុំមិនបានគិតដែរ មិនដឹងប៉ុន្មាននាក់ មិនដឹងអ្នកណាខ្លះ ។

ដានីៈ ខ្ញុំអានចំលើយសារភាពរបស់តារិន មួយគាត់ គាត់នៅហ្នឹងដែរ?

យុគៈ តារិន ស្លាប់បាត់ហើយហ្នឹង គាត់កើតអេដស៍ ស្លាប់ហើយហ្នឹង ។

ដានីៈ តារិន ហ្នឹងគាត់នៅកំពតដែរ?

យុគៈ នៅកំពត ។

ដានីៈ គាត់នៅក្នុងជួរក្នុងគណៈតំបន់ដែរអត់ទេ?

យុគៈ គណៈតំបន់ ។

ដានីៈ ហើយកាលហ្នឹងនៅកំពត តាអាន គាត់នៅក្នុងគណៈតំបន់?

យុគៈ តាអាន នៅកំពត ។

ដានី៖ នៅកំពត នៅក្នុងគណៈតំបន់ហ្នឹងដែរ?

យុគៈ តំបន់កំពត ។

ដានី៖ ពីព្រោះខ្ញុំអាន ខ្ញុំធ្លាប់ជួបគាត់ដែរតា៎ ធ្លាប់ជួបគាត់ ។

យុគៈ គាត់នៅកំពត ។

ដានី៖ គាត់ធ្វើទំនប់កោះស្លា ។

យុគៈ ទំនប់ត្រីលោត ។

ដានី៖ ត្រីលោតខាងកោះស្លា ទំនប់រំលេច គាត់ថាគាត់អ្នកធ្វើដែរ ។

យុគៈ ខ្ញុំអត់បានធ្វើនឹងគេទេ ។

ដានី៖ អ៊ំមានប្រសាសន៍ថាលើកទំនប់ ក្រែងលោលើកទំនប់ជាមួយពួកគាត់ដែរ?

យុគៈ ខ្ញុំធ្វើទំនប់ស្រុកទេ គាត់ធ្វើទំនប់តំបន់ ទំនប់ត្រីលោត ទំនប់កោះស្លា សុទ្ធតែទំនប់តំបន់ ខ្ញុំធ្វើទំនប់ស្រុកឈូកមួយគេហៅស៊ឹងប្រាំង ។

ដានី៖ អ៊ីចឹងអ៊ំកាលនៅគាត់ដេរនៅក្នុងស្រុកឈូក យើងគាត់ដេរខោអាវសំលៀកបំពាក់សំរាប់ផ្គត់ផ្គង់ឲ្យតែកងទ័ពនៅក្នុងតំបន់កំពត?

យុគៈ ជំនាញការទាំងអស់ គេហៅជំនាញការតំបន់ អ្នកធ្វើអីៗ ដូចថាយើងមានអ្នកសេដ្ឋកិច្ច អ្នកសង្គមកិច្ច សុខាភិបាលយើងឲ្យ ព្រោះយើងចែកឲ្យគ្រប់ស្ថាប័ន ព្រោះក្រណាត់វាគរតែមួយកន្លែងហ្នឹង គ្មានអ្នកណាគេកាត់មានតែយើង ។ ឧទាហរណ៍ថាប្អូនឯងត្រូវការ២ឈុតកាត់ឲ្យ ។

ដានី៖ ត្រូវការ២ឈុតអ៊ីចឹង យើងកាត់ បានន័យថាគេស្នើរមកយើងកាត់ ។

យុគៈ យើងកាត់ ។

ដានី៖ ប៉ុន្តែអ៊ំនៅតែដាំបាយទេ អត់បានរៀនចេះកាត់ដេរនឹងគេទេ?

យុគៈ អត់ទេ ខ្ញុំអត់ចេះ ខ្ញុំដាំបាយ ។

ដានី៖ ឈ្មោះសារឿន ហើយឈ្មោះធីម គាត់ចេះស្ទាត់?

យុគៈ ជាងកាត់ដេរ ។

ដានី៖ កាលហ្នឹងនៅក្នុងស្រុកឈូក ពីណាគេគណៈស្រុកនៅឈូក?

យុគៈ ឈ្មោះទី, តាចេន ឥឡូវមិនដឹងគាត់ស្លាប់អស់ ។

ដានី៖ ២នាក់ហ្នឹងស្លាប់អស់?

យុគៈ ២នាក់ហ្នឹងដឹងស្លាប់នៅ បើខ្ញុំមិនដែលបានជួបផង ។

ដានីៈ អ្នកស្រុកណា?

យុតៈ អត់ដឹងអ្នកស្រុកណាទេ គ្រាន់តែស្គាល់គាត់ យើងមិនបានសួរនាំ ។

ដានីៈ សុទ្ធតែប្រុសៗ អត់មានស្រីក្នុងហ្នឹង?

យុតៈ អត់ ។

ដានីៈ គណៈស្រុកហ្នឹង?

យុតៈ តាចេន, តាទី, តាមុត ៣នាក់ ។

ដានីៈ តាមុត?

យុតៈ តាមុតហ្នឹងស្លាប់ហើយ ។

ដានីៈ តាមុត គាត់ស្លាប់ហើយ ។

យុតៈ តាមុតនៅនេះ បានឃើញគាត់នៅ?

ដានីៈ តាមុត នៅណា?

យុតៈ គាត់នៅណាទេ គាត់នៅស្រុកឈូកដែរ តែមិនដឹងស្រុកភូមិគាត់នៅណា គាត់នៅស្រុកឈូកដែរ តាមុត ក៏ស្រុកឈូក តាចេន ក៏ស្រុកឈូក តាទី ក៏ស្រុកឈូក ។ តាទី ក៏ស្លាប់តាមខ្ញុំដឹង ។ តាចេន មិនដឹងគាត់ស្លាប់ ឬរស់ខ្ញុំអត់ដឹង តែតាមុត ហ្នឹងគាត់ស្លាប់ហើយ ។

ដានីៈ ខ្ញុំច្រលំអ៊ំប្រាប់ថាតាមុត ហ្នឹងស្មានតាមុត កងទ័ពជើងទឹក?

យុតៈ មិនមែនទេ តាមុត ឡើងតុលាការទេ ។

ដានីៈ តាមុត ឡើងដែរ?

យុតៈ តាមុត ឡើងដែរតាំ! តាមុត កងទ័ពឡើងទៅម្តង ។

ដានីៈ ព្រោះតាមុត ស្រុកកំណើតគាត់នៅហ្នឹងដែរ?

យុតៈ តាមុត ក៏នៅហ្នឹង តែគាត់នៅម្តុំស្រែក្នុង ហើយតានៅម្តុំខាងកើតស្រែក្នុង តែមិនដឹងភូមិអីតែគាត់ស្លាប់ហើយតាមុត ។

ដានីៈ ឈ្មោះទី ក៏គាត់ស្លាប់ ។ ឈ្មោះចេន អត់ដឹងទេ?

យុតៈ អត់ដឹង ។

ដានីៈ អ៊ំកាលពីឆ្នាំ៧៨ អ៊ំនៅលើកទំនប់ កំលាំងដែលយើងត្រូវលើកច្រើនទេ?

យុតៈ កំលាំងអ្នកស្រុកតិចទេ ប្រហែលជា២០០-៣០០ទំនប់ស្រុក ។

ដានីៈ ទំនប់ស្រុក២០០-៣០០ទេ?

យុតៈ ចាំ!

ដានី: ហ្នឹងកំលាំងហ្នឹងសុទ្ធជាកំលាំងយុវជន យុវនារី ឬកំលាំងទូទៅ?

យុត: កំលាំងហ្នឹងកំលាំងសល់ពីទំនប់តំបន់ ដូចថាទំនប់ហ្នឹងមនុស្សកំលាំងទី១ និយាយអីចឹង កំលាំងវាទី៣-៤ទៅណា៎ ដល់អីចឹងយើងទុកហ្នឹងលើកក្នុងស្រុកទៅកុំឲ្យវាខាត អីចឹងយើងយកកំលាំងទី១-២យើងយកទៅទំនប់ ។

ដានី: កាលហ្នឹងអ៊ំតួនាទីអីទៅ កាលយើងលើកទំនប់?

យុត: ខ្ញុំតួនាទីខាងនារីស្រុក ។

ដានី: ប្រធានកងនារីស្រុកអីចឹង?

យុត: ស្រុកឈូកហ្នឹង ។

ដានី: ដល់យើងគ្រប់គ្រងខាងនារីអីចឹង យើងមានភារកិច្ចលើកទំនប់?

យុត: លើកទំនប់ ។

ដានី: មានអីទៀត ដូចខាងការពារ?

យុត: យើងលើកទំនប់ យើងការពារ ព្រោះយើងកិច្ចការនារីស្រុក យើងធ្វើគ្រប់ សង្គមកិច្ច, សុខាភិបាលទាំងអស់ដែរហ្នឹង តែផ្នែកខាងនារី គេនិយាយអីចេះទៅ ។

ដានី: អីចឹងតួនាទីអ៊ំចូលក្នុងគណៈស្រុកជាមួយពួកគាត់?

យុត: ចា៎! ជាមួយគាចេន អីដែរ គ្រាន់ខ្ញុំជំនួយទេ មិនមែនជាពេញសិទ្ធិ ។

ដានី: យើងលើកតែទំនប់នៅក្នុងបរិវេណក្នុងស្រុកឈូកទេ?

យុត: ស្រុកឈូកទេ ។

ដានី: ដល់ពេលខាងទំនប់តំបន់?

យុត: ហ្នឹងខាងតំបន់ ។

ដានី: ខាងតំបន់ក្រែងមានទំនប់ខ្លះវាចូលក្នុងស្រុកដែរ?

យុត: នៅខ្លះអត់ចូលទេ គេលើកកំលាំងទៅតំបន់តែម្តង កំលាំងស្រុកគេទុកឲ្យយើងធ្វើផ្សេង ។

ដានី: ហ្នឹងគ្នាច្រើនទេលើកទំនប់តំបន់?

យុត: ទំនប់តំបន់ខ្ញុំមិនដែលសួរទៅជិតដែរ ព្រោះហ្នឹងភារកិច្ចរបស់គេអ្នកធ្វើផ្សេង ខ្ញុំធ្វើផ្សេង អាចច្រើនហើយព្រោះទំនប់វាធំ ខ្ពស់លើដល់១៥០នោះ ។

ដានី: ខ្ពស់លើបានន័យថា អាខ្ពស់ទទឹងហ្នឹង១៥០ម៉ែត្រ?

យុត: ឬក៏៩០, ៨០ បើមិនធ្វើធំទំហំទឹកវាំបាក់ អីចឹងគេដាក់ឲ្យធំទៅដើម្បីធ្វើទ្វារទឹក ។

ដានី: អីចឹងទាល់តែកំលាំងរាប់ពាន់នាក់?

យុគៈ	រាប់រយ រាប់ពាន់ដែរ ។

ដានីៈ	កំលាំងហ្នឹងដូចថាយុវជន យុវនារីក្នុងតំបន់ទាំងអស់ យើងប្រមូល យើងជ្រើសរើសមក ។

យុគៈ	យើងប្រមូលជ្រើសរើសដូចថានៅសល់ខ្វះអីចឹង យើងនៅធ្វើ ។

ដានីៈ	ដូចថាយើងលើកទំនប់ស្រុកអីចឹង យើងធ្លាប់ទទួលផែនការ យើងប្រជុំ យើងបែងចែកយ៉ាងម៉េច ទំនប់នេះត្រូវខាងតំបន់ធ្វើ ហើយទំនប់ខាងស្រុកយើងត្រូវខាងតំបន់ណែនាំមកថាយើងធ្វើយ៉ាងម៉េចៗដែរ?

យុគៈ	ឲ្យយើងធ្វើតាម ឧទាហរណ៍ថាទំនប់យើងចែកច្បាស់ហើយណា៎ ខាងនោះកំលាំងទី១ យើងមកនេះយើងនិយាយថា ឥឡូវទំនប់យើងគឺកំលាំងយើងអ្នកធ្វើ អត់មានអ្នកណាមកចូលរួមប្រជាជននៅស្រុកឈូកទាំងមូល យើងហៅមកធ្វើ ដូចថាគ្នានៅសល់កំលាំងខ្វះយើងហៅគ្នាមកធ្វើទៅ មិនមែនធ្វើទាំងអស់ចូលគ្នាទេ ។

ដានីៈ	តាអាន គាត់ចាត់ចែងឲ្យធ្វើទំនប់ព្រោះគាត់ធ្លាប់?

យុគៈ	កាលហ្នឹងមានតារិន មួយទៀត ។

ដានីៈ	តារិន?

យុគៈ	ចា៎!

ដានីៈ	តារិន ង៉ែវ?

យុគៈ	តារិន ង៉ែវ ។ តារិន ស្លាប់បាត់ហើយ ។

ដានីៈ	តារិន ង៉ែវ គាត់ស្លាប់បាត់ហើយ ។ គាត់អ្នកស្រុកកំណើតនៅណា?

យុគៈ	គាត់អ្នកស្រុកកំណើតនៅស្រុកឈូកដែរ ប៉ុន្តែគាត់នៅខាងម្តុំណាទេ ។

ដានីៈ	កាលមុនបន្ទាប់ពីហ្នឹងគាត់ផ្លាស់ទៅនៅណា?

យុគៈ	គាត់ផ្លាស់មកនៅព្រះនេត្រព្រះ ដល់ហើយគេវ៉ៃចោលនៅហ្នឹង ។

ដានីៈ	អ៎! តារិន ង៉ែវ ហ្នឹងផ្លាស់មកនៅព្រះនេត្រព្រះ?

យុគៈ	មកពីកំពត មកនៅហ្នឹង ។

ដានីៈ	មកនៅព្រះនេត្រព្រះហ្នឹងគាត់ស្លាប់ហើយ?

យុគៈ	ស្លាប់ហើយគេចាប់ ។

ដានីៈ	ខ្ញុំមានចម្លើយសារភាពរបស់គាត់ គាត់ឈ្មោះ ហេង រិន ។

យុគៈ	សារភាពម៉េចបើគាត់ស្លាប់យូរហើយ ។

ដានីៈ	គាត់ស្លាប់ជិតនាំ៧៨ ។

យុត៖ ស្លាប់ជំនាន់យើងនេះ ៧៦-៧៧ ។

ដានី៖ បាទ! មាននៅភ្នំពេញ ចម្លើយគេចាប់គាត់ទៅដល់ភ្នំពេញ គេចាប់ទៅភ្នំពេញហើយគេសរសេរចម្លើយនៅក្នុងគុកទួលស្លែង ។ កាលហ្នឹងគាត់ដាក់ថាគាត់ ។

យុត៖ តំបន់កំពត?

ដានី៖ កំពត តែគាត់ផ្លាស់មកខាងស្វាយ ។

យុត៖ ព្រះនេត្រព្រះ ត្រឹមត្រូវហើយ គាត់មកនៅហ្នឹង ។

ដានី៖ តែយើងហៅ រិន ង៉ើវ?

យុត៖ រិន ង៉ើវ ខ្ញុំហៅ រិន ង៉ើវ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអីដែលកាលហ្នឹង?

យុត៖ ប្រពន្ធគាត់មិនដឹងឈ្មោះអីទេ ប្រពន្ធគាត់ ឥឡូវស្លាប់ហើយ ។

ដានី៖ ប្រពន្ធគាត់គេចាប់ដែរ?

យុត៖ គេចាប់ ។

ដានី៖ ចុះ រិន ការ?

យុត៖ រិន ហ្នឹងវេចមាត់ ។ រិន ហ្នឹងងាប់ដែរ ។

ដានី៖ គាត់ស្លាប់នៅណា?

យុត៖ គាត់កងទ័ពមិនដឹងស្លាប់នៅណាទេ ខ្ញុំចេញផុតទៅងាប់ ខ្ញុំមិនបានសួរគេ មិនដឹងគាត់ស្លាប់នៅណា តារិន ។

ដានី៖ ប៉ុន្តែគេថាស្លាប់ៗ?

យុត៖ ស្លាប់ដែរ ។

ដានី៖ ពីព្រោះនៅខាងកំពតឈ្មោះ រិន ច្រើន ដល់អីចឹងវា?

យុត៖ រិន ង៉ើវ ហ្នឹងមួយ, រិន ផែកហ្នឹងមួយវេចមាត់ ហ្នឹងរិន ដែរ តែរិន ង៉ើវ អត់និយាយលីទេ គាត់និយាយសំដីដូចស្រីអីចឹង ហើយដល់គាត់នៅកំពតខាងលើដកគាត់មកព្រះនេត្រព្រះដល់ហើយគេចាប់ ។

ដានី៖ គេចាប់គាត់ដែរ?

យុត៖ ចាប់ទាំងប្តី ទាំងប្រពន្ធ ។

ដានី៖ អីចឹងកាលធ្វើទំនប់ហ្នឹង តាអាន, តារិន គាត់នៅជាមួយគ្នា?

យុគៈ នៅ ដល់ក្រោយគារិន គាត់ធ្វើហ្នឹងដែរដល់ក្រោយមកបានដកគាត់ តែតាមពិតគាត់ប្រឡូក ចលនាខ្លាំងណាស់ ពូកែធ្វើតែម្តង ។

ដានីៈ គារិន?

យុគៈ ហើយលះបង់អ៊ីៗទាំងអស់ សូម្បីតែប្រពន្ធមិនដែលមកជួបផង គាត់លះបង់ប៉ុណ្ណឹងហើយ នៅតែចាប់ទៀតអូនឯងគិតទៅ ខ្ញុំអាណិតចង់ងាប់ហើយរាល់ថ្ងៃខ្ញុំអាណិតណាស់ គ្មានអ្នក ណាដល់ទេ បើគិតកម្មសិទ្ធិ គ្មានសម្ភាជីវៅ ដាក់ខ្លួនចូលដល់ប្រជាជន ស្ទូងស្រូវក៏ស្ទូង ធ្វើ អីក៏ធ្វើដែរ ហេតុអីបានមកនៅហ្នឹងគេចាប់ ឆ្ងល់ដែរហើយដើងខោត្រឹមៗនេះសុទ្ធតែភក់ គាត់ចុះប្រឡូក ។

ដានីៈ ក្រែងគេចាប់គាត់ដោយសារគាត់ខ្សែជាមួយ កង ចាប? ព្រោះកង ចាប គេចាប់គាត់ ដែរ?

យុគៈ ទេ ដូចជាចាប់មុន កង ចាប ។ មិនមើលអាគារាងនេះដឹងហើយ ។

ដានីៈ បាទ ព្រោះគេចាប់គាត់ចុង៧/៨ហើយ ជិតយួនចូលហើយ ខ្ញុំឃើញអីចឹង កង ចាប ក៏គេ ចាប់ដំណាលៗគ្នា ខុសគ្នា១-២ខែ ។

យុគៈ កង ចាប ដូចជាចាប់ក្នុងខែ៨?

ដានីៈ បាទ! ដូចចាប់អីចឹងទៅ និយាយរួមក្នុងឆ្នាំតែមួយ ប៉ុន្តែខុសខែ ខុស១-២ខែ ។ តាមពិត ដូចអឹធ្លាប់ស្គាល់ស្និតស្នាល គេចាប់អីចឹងអឹមានអារម្មណ៍អាណិតគាត់ ។

យុគៈ អាណិតមនុស្សស្លូតបូត ។

ដានីៈ តាមមើលគេថាគាត់ក្បត់ គាត់ក្បត់មែនដែលអត់?

យុគៈ ខ្ញុំដូចមិនជឿ តែខ្ញុំមិនហ៊ាននិយាយ ខ្ញុំឆ្ងល់ម៉េចបានក្បត់ បើធ្វើនៅកំពតខ្លាំងណាស់ ហើយនិយាយពីកម្មាជីវូបនីយកម្មគ្មានអ្នកណាដល់ ។

ដានីៈ គារិន?

យុគៈ ខោមិនខោ អាវមិនអាវ ស៊ីចុកអ្នកណាឲ្យស៊ីអីស៊ីហ្នឹង ស៊ីបាយតាមសហករណ៍ ។ ខ្ញុំថា អ៊ូ! តស៊ូដូចគារិន ឯងមិនកើតទេ អញមិនធ្វើបានទេ អញខ្ជិលណាស់ ចុះគាត់ប្អូនខ្ញុំតិចតួច ។

ដានីៈ គាត់មានឈ្មោះអីក្រៅពី គារិន?

យុគៈ អត់ទេ គាត់ឈ្មោះគារិន ។

ដានីៈ ស្រុកកំណើតគាត់?

យុគៈ ស្រុកកំណើតនៅស្រុកឈូកដែរ តែមិនដឹងឃុំណា ភូមិណា ។

ដានី: តែនៅម្តុំៗហ្នឹងដែរ ឬអត់ទេនៅឆ្ងាយ?

យុត: មិនមែននៅជិតៗមេស្រុកអស់ហ្នឹងទេ នៅឆ្ងាយពីគាត់ដែរ តែក្នុងស្រុកហ្នឹង តែមិនដឹងថា នៅឃុំណា ខ្ញុំវាអត់ច្បាស់ ។

ដានី: កាលហ្នឹងគាត់ធ្វើធំជាងតាអាន ឬតាអាន ធំជាងកាលពេលស្រុកឈូក?

យុត: កាលហ្នឹងតាចាប ហើយគាត់, គាត់ហើយតាអាន ។

ដានី: កាលហ្នឹងតាចាប គាត់ធ្វើប្រធានធំ បន្ទាប់មកតារិន ហើយបានតាអាន ។ ប៉ុន្តែតារិន ហើយតាអាន គាត់ទទួលខាងទំនប់ គាត់នៅជាមួយគ្នា ឬអត់ទេ?

យុត: អត់ទេ មិនដែលជួបជុំគ្នាទេ ។ តារិន គាត់ធ្វើទំនប់ណា គាត់ដេកទំនប់ហ្នឹង គាត់លះបង់ ជាមួយសមាជិក ហើយគាត់ដូចថា និយាយរួមគាត់មានទស្សនៈជាមួយប្រជាពលរដ្ឋណាស់ គាត់មិនចេះដើរចោលទេ ដូចថាអត់ឃ្លានអីយ៉ាងណាក៏ស៊ីជាមួយគេទៅ គិតអីចឹង ។ តែដល់ពេលស្លាប់ខ្ញុំអាណិតគាត់ ខ្ញុំនិយាយត្រង់ មិនគួរណាចាប់តារិន សោះ មនុស្សកម្មាជីវូបនីយកម្មដាក់ខ្លួនឡើងទាប គ្មានអ្នកណាដល់ទេ បើនិយាយពីអ្នកដឹកនាំទាំងអស់មិនស្មើរ តារិនទេ សូម្បីតែខ្ញុំហ្នឹងក៏ដោយ ខ្ញុំមិនស្មើរគាត់ទេ ខ្ញុំគិតខ្លួនឯងអីចឹង ។

ដានី: តែក្នុងជំនាន់មេដឹកនាំ៣នាក់អីចឹង ទាំង៣នាក់ហ្នឹងអ៊ំស្និតស្នាលជាមួយពីណាជាងគេ? តាចាប, តារិន, តាអាន?

យុត: កាលហ្នឹង?

ដានី: បាទ!

យុត: ស្និតស្នាលអី បើជួបក៏និយាយគ្នា បើអត់ក៏ហីទៅ ។

ដានី: តែយើងហ៊ានលេងសើច យើងហ៊ានថា?

យុត: ជាមួយតារិន ព្រោះគាត់ ជួនកាលគាត់ធ្វើទំនប់តំបន់មែន ជួនកាលគាត់មកមើលយើង គាត់ថា «អេ៎! លើកទំនប់អីណាក៏យូរម្ល៉េះ» ។ ចុះខ្លាំងហើយឯង អ្នកឯងមានមនុស្សច្រើន ខ្ញុំកំលាំងកាច់កើច ទី៣-៤ ។

ដានី: យើងហ៊ានលេងសើច?

យុត: ហ៊ានលេងសើច អត់អីទេ ហើយដូចថាមនុស្សវាមិនប្រកាន់ឋានៈ មិនប្រកាន់បុក ដូចថា ស្មើរភាព ។

ដានី: ដូចថាតាចាប គាត់មានដែលទៅមើល?

យុត: តាចាប គាត់ទៅតែគាត់ចូលទំនប់ធំៗ ។

ដានី៖ គាត់អត់ដែលទៅមើលទំនប់?

យុត៖ តាចាប វៃឫកណាស់ ។

ដានី៖ តាចាប វៃឫក?

យុត៖ ស៊ីរកតែឆ្ងាញ់ និយាយទៅគេហៅថាគេនិស្សិត ។

ដានី៖ គាត់នៅកម្មសិទ្ធិក្រាស់?

យុត៖ អត់ទេ ដូចនិស្សិត ឬបញ្ញាវ័ន្តទេនេះ តាចាប គេហៅថាចរិតអ្នកធំ មិនមែនចរិតអ្នកកសិករ អីចឹងយើងមិនត្រូវធាតុទេ ។

ដានី៖ វាយតម្លៃមើលខ្ពស់ទាប?

យុត៖ មើលខ្ពស់ទាប ហើយគាត់ដូចថានិយាយអីទៅ គាត់ច្រើនតែមើលៗទៅដូចថាយើងទាបជាងគាត់រហូត ហើយខ្ញុំអត់សូវចូលចិត្ត ។

ដានី៖ ចុះតាអាន?

យុត៖ តាអាន គាត់អត់ចេះមាត់ អ្នកណាធ្វើអីធ្វើទៅ គាត់ធ្វើមិនដឹង ធ្វើមិនលឺ គាត់ស្ងួត ។

ដានី៖ បានន័យថាគាត់អត់សូវចេះមាត់ អត់មានភាពស្និតស្នាលជាមួយ?

យុត៖ អត់ទេៗ គាត់មិនសូវចេះមាត់ អ្នកលេងមិនសូវហ៊ានលេងជាមួយគាត់ ។

ដានី៖ គាត់កាចដែរ?

យុត៖ អត់កាចទេ តែចរិតគាត់មិនសូវចេះនិយាយស្តី តែការងារគាត់មាន គ្រាន់តែចរិតគាត់មិនសូវនិយាយ ។

ដានី៖ គាត់អ្នកស្រុកនៅកំពតដែរ?

យុត៖ អត់ទេ មិនដឹងស្រុកគាត់នៅណាទេ តាអាន ។

ដានី៖ ប៉ុន្តែគាត់ផ្លាស់ការងារទៅធ្វើនៅហ្នឹង?

យុត៖ ដល់ហើយខាងលើឲ្យគាត់មកខាងហ្នឹង មិនដឹងគាត់នៅណា ។

ដានី៖ អ៊ីពី៧៨ អ៊ីនៅលើកទំនប់អី នៅស្រុកឈូក ដូចស្ទឹងប្រាំង នៅជិតនរាយណ៍ នៅលើកទំនប់ ហើយទទួលខាងនារីនៅស្រុកឈូក នៅហ្នឹងបានយូរទេ?

យុត៖ ណា៎ មុិញ៧៨?

ដានី៖ ៧៨ ។

យុត៖ ៧៨-៧៧ ខ្ញុំនៅ៣ឆ្នាំ ។

ដានី៖ អ៊ីមានអនុស្សាវរីយ៍យ៉ាងម៉េចខ្លះពេលយើងនៅធ្វើការងារហ្នឹងបាន៣ឆ្នាំ?

យុគះ អត់មានអនុស្សាវរីយ៍អី មានតែប្រជាជនហ្នឹង អនុស្សាវរីយ៍ ។

ដានីះ ប្រជាជនយ៉ាងម៉េច អ៊ំអាច?

យុគះ គាត់ស្រឡាញ់ ខ្ញុំធ្វើការ ។

ដានីះ គាត់ស្រឡាញ់អ៊ំបានធ្វើការងារស្អីខ្លះ ដែលអ៊ំនៅចងចាំថាដែលធ្វើឲ្យប្រជាជនស្រឡាញ់ក្នុងរយះពេលពី៧៤-៧៧ហ្នឹង? ដូចថាយើងធ្វើស្អីដែលអ៊ំគិតថាបានពេញចិត្តធ្វើឲ្យប្រជាជនហើយយើងសប្បាយចិត្តខ្លួនឯង ។

យុគះ ខ្ញុំនៅហ្នឹងដែលពេញចិត្តហើយ មកពីខ្ញុំប្រឡូក ខ្ញុំដើរ ខ្ញុំអត់ចេះខ្លាច ។ ឧទាហរណ៍បាយផ្ទះប្រជាជនណាមួយក៏ខ្ញុំហូបដែរខ្ញុំអត់ប្រកាន់ ខ្ញុំដូចថាតារិនអីចឹង ខ្ញុំធ្វើដូចតារិន គេហៅថាយើងរួមសុខ រួមទុក្ខ រួមសន្ទនា រួមធ្វើការ ហើយខ្ញុំយកពាក្យហ្នឹង ខ្ញុំអត់មានចេះរើសអើងអីទេ សម័យនេះក៏អីចឹង សម័យនោះក៏អីចឹង ផ្ទះណាក៏ដោយឲ្យខ្ញុំហៅ ខ្ញុំចូលហូបខ្ញុំអត់ថាកូនអាចម៍ សំបោរអីអត់និយាយទេ ។ ដល់អីចឹងរាល់ថ្ងៃប្រជាជនគាត់មកឃើញខ្ញុំគាត់មកឃើញខ្ញុំ បងអើយ បងឯងរស់បានយូរខ្ញុំនឹកបងឯងណាស់ ខ្ញុំនឹកឃើញតែបងឯងលើកទំនប់ បងឯងហូបបាយអត់ចេះរើសទេ ឲ្យតែកងចល័តហូបអីហូបហ្នឹង អនុស្សាវរីយ៍ខ្ញុំអាហ្នឹង ។

ដានីះ នៅដល់ឥឡូវ?

យុគះ នៅទល់ឥឡូវ អ្នកណាជួបខ្ញុំក៏និយាយដែរ ។

ដានីះ ដល់ពេលហ្នឹងអ៊ំមានអារម្មណ៍សប្បាយចិត្តខ្លួនឯង?

យុគះ សប្បាយចិត្ត ខ្ញុំនៅជាមួយប្រជាជន នៅហ្នឹងក៏ខ្ញុំអីចឹង ។

ដានីះ ប៉ុន្តែមួយទៀត អ៊ំមានឃើញថាប្រជាជនកាលហ្នឹងសុខទុក្ខប្រជាជន គាត់មើលទៅគាត់សប្បាយចិត្ត គាត់មានជីវភាពស្រួលបួល ល្អដែលឬយ៉ាងម៉េច ពេលដែលអ៊ំនៅពីចិត?

យុគះ កាលខ្ញុំនៅហ្នឹង ជីវភាពប្រជាជននៅស្រុកឈូក និយាយរួមនៅខេត្តកំពតទាំងមូល ដែលមានការដឹកនាំល្អ យើងនិយាយមិនមែនថាមកនិយាយហើយ និយាយដើម្បីលើកជើងទេបាយគឺហូបរហូត ។

ដានីះ ហូបបាយ?

យុគះ ចា៎! ហើយនិយាយពីអ្នកដឹកនាំនៅកំពតគឺគ្មានកម្មសិទ្ធិទេ កម្មាភិបាលទាំងអស់ហើយមិនដែលអត់ឃ្លានទេ ប្រជាជនគាត់សរសើរណាស់ ទី១ កម្មាភិបាលគេហៅថាចុះទៅដល់ស្រែចុះទាំងអស់គ្មានអ្នកណាមួយហ៊ាននៅទេ មិនហ៊ាននៅលើការិយាល័យអីចឹងទេ តែនៅគឺ

គារិន ហ្នឹងខ្លាំងណាស់ កសាងយើង ជួយមតិយើងអាណាចុះទៅដល់ឃុំ មិនដល់ឃុំអី គាត់ដើរសួរប្រជាជននៅតាមស្រែទៀត ។

ដានី: អីចឹងបានន័យថាគារិន គាត់លះបង់ខ្ពស់ ហើយគាត់ធ្វើអីយុត្តិធម៌ បានន័យថាត្រឹមត្រូវស្មើរភាព?

យុគៈ: និយាយរួមគាត់យុត្តិធម៌ នេះយើងនិយាយដោយពិត មិនមែនចេះតែយកមកបញ្ចេញបញ្ចូលទេ និយាយរឿងពិត និយាយទៅគាត់យុត្តិធម៌ និយាយរួមគាត់អ្នកបំរើឥតលក្ខខណ្ឌ និយាយអីចឹង ។

ដានី: ប៉ុន្តែកាលហ្នឹងអ៊ំអត់មានមើលឃើញប្រជាជនគាត់អត់សប្បាយចិត្ត អ៊ំមានមើលឃើញទេ?

យុគៈ: មើលឃើញ ។

ដានី: ឃើញយ៉ាងម៉េចខ្លះអ៊ំ?

យុគៈ: មើលឃើញត្រង់ថាខ្លះគេពេញចិត្តយើងធ្វើសហករណ៍ ខ្លះក៏មិនពេញចិត្ត អាហ្នឹងវាខុសយើងធ្វើវាមានខុស មានត្រូវ តែកន្លែងក៏គេពេញចិត្ត គេថាធ្វើអីចឹង ឧទាហរណ៍ដូច្នេះយើងនិយាយអីចឹងវាល្អម្យ៉ាង កសិករអ្នកក្រកាលណាធ្វើអីចឹងគ្នាស៊ីគ្រប់គ្រាន់ តែកន្លែងខ្លះគេអត់ពេញចិត្តមកពីគេអ្នកមាន ដូចឧទាហរណ៍ភូមិ«ក» គេមានយើងទៅធ្វើអីចឹងគេអន់ចិត្តតែភូមិ«ខ»គ្នាអត់ អាហ្នឹងយើងធ្វើទៅមានការខុសត្រូវ អានេះយើងនិយាយឲ្យឃើញដល់អីចឹងប្រជាជនខ្លះទោសទ្បូ ។

ដានី: អ៊ំប្រជាជននៅភ្នំពេញអី អ្នក១៧មេសា មានទៅខាងស្រុកឈូក មានជម្លៀសទៅហ្នឹងអត់?

យុគៈ: មានតា ។

ដានី: ជម្លៀសទៅតាំងពីឆ្នាំណា?

យុគៈ: ឆ្នាំ៧៥ ។

ដានី: ពេលដែលយើងវ៉ៃបែកភ្នំពេញហើយ?

យុគៈ: ចា៎!

ដានី: ទៅច្រើនទេនៅស្រុកភូមិអ៊ំ?

យុគៈ: ទៅខេត្តកំពត តែតាមច្រកដែរ ច្រកស្រុកឈូក, ច្រកស្រុកទូកមាស, ច្រកស្រុកកំពង់ត្រាច, ច្រកស្រុកកំពតអីចឹង ។

ដានី: អំពេលហ្នឹងមានតួនាទីជាអ្នកគ្រប់គ្រងមួយដែលនៅក្នុងស្រុកហ្នឹង យើងបែងចែកប្រជាជនឲ្យរស់នៅយ៉ាងម៉េច? លក្ខណៈគាត់ទៅរស់នៅយ៉ាងម៉េច? ការងាររស់នៅយ៉ាងម៉េចដែរ?

យុគៈ ផ្ញើរតាមភូមិ ។ ឧទាហរណ៍ថាចេញមក១០០នាក់ យើងផ្ញើរមួយភូមិ១០គ្រួសារផ្ញើរតាមភូមិ ។

ដានី: អីចឹងទៅស្រុកឈូកហ្នឹងតិចទេមើលទៅ ឬច្រើន?

យុគៈ ដូចតិចដែរ អត់សូវច្រើន តែនិយាយទៅប្រជាជននៅខេត្តកំពតដល់យើងនិយាយទៅមានស្រុកកោះស្លា មានស្រុកកំពត មានស្រុកទូកមាស ស្រុកកំពង់ត្រាច ឥឡូវប្រជាជនភាគច្រើនគាត់នៅណាច្រើនគាត់ទៅហ្នឹងហើយ ។ ឧទាហរណ៍អ្នកនៅខេត្តមែន អ្នកនៅស្រុកកំពង់ត្រាចច្រើនគេទៅច្រើនហ្នឹង ។

ដានី: អីចឹងតំបន់កំពត គេហៅតំបន់លេខប៉ុន្មាន?

យុគៈ តំបន់លេខ៣៥ ។

ដានី: តំបន់៣៥ មានស្រុក?

យុគៈ ស្រុកឈូក, ស្រុកកោះស្លា, ស្រុកកំពត, ស្រុកទូកមាស, ស្រុកកំពង់ត្រាច, ស្រុកកោះតូច ។

ដានី: មានស្រុកកោះតូចដែលកាលហ្នឹង?

យុគៈ ចា៎! នៅកំពតមួយស្រុកហ្នឹងទេ តែប៉ុណ្ណឹងអស់ហើយ ។

ដានី: ចាំមើលមានឈូក, មានកំពត, កោះស្លា, ទូកមាស, កំពង់ត្រាច, កោះតូច ។ ស្រុកទឹកឈូរមានទេកាលហ្នឹង?

យុគៈ អត់ទាន់បង្កើត ។

ដានី: ស្រុកបន្ទាយមាសមានទេ?

យុគៈ ចុះទូកមាសហ្នឹង ។

ដានី: ទូកមាស និងបន្ទាយមាសតែមួយទេ?

យុគៈ ហ្នឹងហើយ ។

ដានី: អង្គរជ័យមានទេកាលហ្នឹង?

យុគៈ អត់ទេ ទៅខាងស្រុកតាកែវ ។

ដានី: កាលហ្នឹងមានឈូក១, កំពត២, កោះស្លា៣, ទូកមាស៤, កំពង់ត្រាច៥, កោះតូច៦ ។

យុត៖ កោះតូចបង្កើតក្រោយទេ ។

ដានី៖ បង្កើតឆ្នាំណា?

យុត៖ ស្រុកវាលវេញអត់យក គេបញ្ជូនមកកំពតវិញ ដល់ហើយបានកើតក្រោយគេ ។

ដានី៖ កើតឆ្នាំណាកោះតូច?

យុត៖ មិនដឹងកើតឆ្នាំណាទេ ប៉ុន្តែកាលហ្នឹងខ្ញុំលឺថាឲ្យមកវិញ ថាឲ្យមកនៅព្រោះវានៅជិតទីផ្សារកំពត ខាងនោះវាឆ្ងាយ ។

ដានី៖ បែកភ្នំពេញឆ្នាំ៧៥ហើយ ឬតាំងពីពេលអ៊ំទៅឆ្នាំ៧៨?

យុត៖ បែកភ្នំពេញ ។

ដានី៖ បែកភ្នំពេញហើយបានមានស្រុកកោះតូច?

យុត៖ ខ្ញុំអត់ច្បាស់ដែរ ។

ដានី៖ តែដឹងប្រាកដថានៅតំបន់៣៥ហ្នឹងមានស្រុកកោះតូចមួយទៀត?

យុត៖ ហ្នឹងមួយ បង្កើតក្រោយ ។

ដានី៖ ជាតួនាទីជាគណៈស្រុក?

យុត៖ មានតា៎ ឈ្មោះតាអីទេ មានស្រុកគេដែរ ។

ដានី៖ ស្រុកឈូកមាន តាទី!

យុត៖ ហ្នឹងហើយ ។

ដានី៖ តាចេន, តាមុត ហើយអ៊ំ ដល់ពេលកំពតគណៈស្រុកគេឈ្មោះអីទៅ?

យុត៖ តាណយ ហើយអនុប្រធានឈ្មោះអីទេនេះ ភ្លេចហើយ ។

ដានី៖ ចុះស្រុកកោះស្លា?

យុត៖ ស្រុកកោះស្លាមានឈុំ ។

ដានី៖ តាឈុំ គាត់ផ្លាស់មកកំពង់ធំហ្នឹង?

យុត៖ ញឹប ។

ដានី៖ តាញឹប គាត់នៅណាឥឡូវ?

យុត៖ មិនដឹងនៅណាទេ ។

ដានី៖ តែគាត់នៅរស់តា៎?

យុត៖ មិនដឹងនៅរស់ ឬស្លាប់បើខ្ញុំបែកគ្នាយូរ ។

ដានី៖ តែតាឈុំ គាត់ស្លាប់បាត់ហើយ?

យុគៈ	តាឈុំ ស្លាប់ហើយតាំ ។

ដានីៈ	តាឈុំ ស្លាប់ជំនាន់ហ្នឹងដែរ?

យុគៈ	តាឈុំ ហ្នឹងខ្ញុំអត់ច្បាស់ទេ មិនដឹងជាស្លាប់ ឬនៅខ្ញុំអត់ដឹងទេ ព្រោះខ្ញុំបែកទៅ ខ្ញុំមិនដែលបានសួរគាត់ ។

ដានីៈ	តែគាត់ផ្លាស់មកកំពង់ធំឬអត់?

យុគៈ	គាត់ទៅកំពង់ធំ តែត្រឡប់មកវិញមិនដឹងម៉េចខ្ញុំមិនបានដឹង ។

ដានីៈ	តាញឹប គាត់ផ្លាស់ទៅណាដែលកាលហ្នឹង?

យុគៈ	តាញឹប ដូចនៅហ្នឹងអត់មានចេញ ។

ដានីៈ	ដល់ពេលតាឈុំ ផ្លាស់ទៅគាត់អាចធ្វើប្រធាន ។ ចុះទូកមាសពីណាគេ?

យុគៈ	ទូកមាស តាផន តែស្លាប់ហើយ ។

ដានីៈ	តាផន?

យុគៈ	តែអនុគាត់មិនដឹងឈ្មោះអីទេខ្ញុំអត់ចាំ ។ ហើយស្រុកកំពង់ត្រាច តាសៀន ។

ដានីៈ	តាសៀន ដែលគាត់មកខាងបាត់ដំបងហ្នឹង ឬមិនមែនទេ?

យុគៈ	មិនដឹងម៉េច ។

ដានីៈ	តាសៀន អនុគាត់ឈ្មោះអីទៅ?

យុគៈ	អនុគាត់ខ្ញុំអត់ស្គាល់ ។

ដានីៈ	ស្រុកកោះតូច?

យុគៈ	កោះតូចឈ្មោះតាអីទេ ភ្លេចហើយ តាហ្នឹងចាស់ដែរហើយ ឈ្មោះអី ខ្ញុំភ្លេចឈ្មោះគាត់ខ្ញុំវាមិនបានចាំ ។

ដានីៈ	ប៉ុន្តែកាលជំនាន់ហ្នឹងគេមានដាក់ឈ្មោះស្រុកជាលេខដែលអត់អ៊ី? ដូចថាលេខប៉ុន្មាន ដូចខាងតាកែវ ស្រុកត្រាំកក់(១០៥), ស្រុកខាងអង្គរជ័យ(១០៦), កោះអណ្តែត(១០៧) គិរីវង្ស(១០៩) ។ នៅនោះមានដាក់លេខអីចឹងដែលអត់ទេ?

យុគៈ	កាលហ្នឹងមិនដឹងជាមានដាក់លេខ ឬអត់ទេ ខ្ញុំមិនបានចាំទុកដែរ ភ្លេចហើយមានតែស្រុកៗ មិនដឹងដាក់លេខឬអត់ ខ្ញុំមិនដឹងដែរ ។

ដានីៈ	អ៊ីកាលហ្នឹងតាម៉ុក គាត់ខស្សាហ៍ចុះមកមើល តាមខ្ញុំជួបអ៊ី ពូ មីងច្រើន ដូចថាតាម៉ុកគាត់ចូលចិត្តដើរទៅ ចូលចិត្តប្រជាជន ចូលចិត្តមើលចេះចុះ សួរនាំសុខទុក្ខប្រជាជន ។

យុគៈ	កំពតគាត់អត់សូវទៅ ។ ដូចថាមិនដឹងម៉េច គាត់មិនសូវទៅ បើគាត់ចុះខាងស្រែអំបិល ។

ដានី៖ គាត់ចុះទៅស្រែអំបិល?

យុត៖ តែស្រែអំបិលរបស់រដ្ឋ ។

ដានី៖ ស្រែអំបិលរបស់ភូមិភាគ មានស្រែអំបិលផ្សេងទៀត គាត់ខស្សាហ៍ចុះទៅមើល ។

យុត៖ បើខេត្តកំពតគាត់មិនសូវទៅទេ ។

ដានី៖ គាត់អត់ចូលចិត្តមេដឹកនាំកំពត?

យុត៖ ប្រហែលជាអ៊ីចឹងក៏មិនដឹង បើគាត់អត់សូវទៅទេ បើគាត់ចង់ជួបអ្នកណាគាត់ហៅអ្នកហ្នឹងជួប បើថាទៅធម្មតាអត់ដែលទៅ ។

ដានី៖ ប៉ុន្តែអ៊ំដែលទៅជួបគាត់ទេ? ទៅប្រជុំ?

យុត៖ ខ្ញុំអត់ដែលទៅទេ ដល់គាត់ ដូចថាគាត់មកអ៊ីចឹងជួបតាមផ្លូវ គាត់បើកឡាន Jeep ចិនជួបគាត់ម្តងអីទៅ ។

ដានី៖ គាត់បើកកាត់អ៊ីចឹង គាត់ឃើញអ៊ំ គាត់ស្គាល់អ៊ំ?

យុត៖ ស្គាល់ ។

ដានី៖ ស្គាល់តាំងពីពេលតស៊ូ ឬពេលអ៊ំមកកាន់?

យុត៖ ស្គាល់តាំងពីខ្ញុំនៅតាកែវ ។

ដានី៖ គាត់ដូចថាអ៊ំចូលបដិវត្តន៍ទំនាក់ទំនងតាមគាត់ដែរ?

យុត៖ តាមគាត់ដែលហ្នឹង ។

ដានី៖ អ៊ីចឹងបានគាត់ស្គាល់ ។ ហើយអ៊ំទៅគ្រប់គ្រងនៅខាងស្រុកកំពតហ្នឹង គាត់បញ្ជូនអ៊ំទៅដែរ?

យុត៖ អត់ទេ កាលហ្នឹងខ្ញុំឡើងតាមស្គាល់ គាត់អត់បានដឹងថាខ្ញុំទៅកំពតទេ ។

ដានី៖ គាត់មានភ្ញាក់ផ្អើល មានសួរថា អ៎! អ៊ំមកកំពតអី?

យុត៖ អត់ទេ ម៉េចជួបគាត់បាន ។

ដានី៖ អ៊ំឡើងតាមខាងណាវិញ?

យុត៖ ឡើងតាមខ្សែរយៈដូចថានៅស្រុកភូមិខ្ញុំ ដូចថាគេធ្លាប់ស្គាល់ខ្ញុំ គេហៅខ្ញុំទៅចូល ប៉ុន្តែឲ្យខាងលើបញ្ជូនខ្ញុំទៅអត់ទេ ។

ដានី៖ ពេលធ្វើការងាររបស់ឯងខស្សាហ៍ប្រជុំផ្លាស់ប្តូរយោបល់គ្នាដែរ ឬទៅតាមស្រុកមួយអ្នកណាចង់ធ្វើអីស្រេចតែយើង ឬគេមានប្រជុំផ្លាស់ប្តូរយោបល់? ហ៎! ផែនការយើងត្រូវធ្វើចេះ យើងដាក់ទិសដៅចេះចុះ យើងមានប្រជុំផ្លាស់ប្តូរគ្នា ឬអត្តនោម័ត?

យុតៈ អត់ទេ ប្រជុំតាំ ។ ឧទាហរណ៍អ្នកណាទទួលអី គេដាក់ឲ្យយើង ។

ដានីៈ គេដាក់អីចឹងទទួលខាងអី ។ រយៈពេលប៉ុន្មានគេប្រជុំម្តង?

យុតៈ ៣ថ្ងៃ ។

ដានីៈ ហ្នឹងក្នុងស្រុកមួយ?

យុតៈ ក្នុងស្រុកមួយ ។

ដានីៈ ចុះតំបន់ស្រុកទាំងអស់មកប្រជុំជួបគ្នាផ្លាស់ប្តូរការងារ រយៈពេលប៉ុន្មានគេប្រជុំម្តង?

យុតៈ តំបន់គេប្រជុំ ការងារចាំបាច់គេហៅប្រជុំតែម្តង បើអត់ទេ ១ខែ, កន្លះខែប្រជុំ បើចាំបាច់គាត់ហៅទៅប្រជុំ ។

ដានីៈ ឆ្នាំ៧៥ ដែលយើងបែកទីក្រុងភ្នំពេញហើយ តំបន់យើងផ្លាស់ទៅនៅត្រង់ណាទៀត ឬនៅកន្លែងតែមួយ?

យុតៈ ដល់៧៥រំដោះហើយ លើកទៅនៅក្រុង ។

ដានីៈ ទៅនៅក្រុង នៅកំពតហ្នឹងតែម្តង?

យុតៈ នៅកំពត ។

ដានីៈ ស្រុកឈូកអ៊ឹមកនៅណាវិញទៅ?

យុតៈ ស្រុកឈូកនៅកន្លែងតាមជនបទទៅ មន្ទីរស្រុកនៅតាមជនបទ ។

ដានីៈ មិនមែននៅតាមថ្នល់ជាតិទេ?

យុតៈ អត់ទេ ។

ដានីៈ នៅកន្លែងណា នៅជនបទ ។

យុតៈ កន្លែងណាយើងទំនងនៅ យើងទៅនៅហ្នឹង ។

ដានីៈ អត់មានចល័តទេ មន្ទីរស្រុកឈូកហ្នឹងអត់នៅកន្លែងជាសាលាស្រុក?

យុតៈ មានសាលាស្រុក ដូចថាកន្លែងស្នាក់ការរបស់ស្រុកឈូកហ្នឹងមួយ ដូចថាយើងនៅកន្លែងណា យើងធ្វើផ្ទះខ្ទមឯងនៅទៅ ។

ដានីៈ ស្នាក់ការរបស់ស្រុកឈូកនៅណាទៅ?

យុតៈ នៅខាងណាទេកាលហ្នឹង នៅខាងបៀតក្រហូង ឬខាងជើងផ្សារឈូកអីចឹង មានផ្ទះគេស្រួលនៅយើងនៅទៅ មានបោះទីតាំងអី ។

ដានីៈ ទីតាំងគ្រាន់តែប្រជុំគ្នាទេ?

យុតៈ ប្រជុំ មានការអីយើងហៅប្រជុំ ផ្ទះណាធំៗគេអត់នៅអីចឹង យើងទៅនៅ ។

ដានី៖ យើងធ្វើការនៅក្នុងស្រុកឈូក មានអ្នកគ្រប់គ្រងតាទី, តាចេន, តាមុត, អ៊ំ កាលហ្នឹង យើងប្រជុំ យើងដោះស្រាយ យើងដាក់ផែនការការងារ យើងរលូនជាមួយគ្នាដែរ ឬមិន សូវទេ?

យុត៖ រលូនជាមួយគ្នាបានធ្វើទៅ ។

ដានី៖ ពួកគាត់យ៉ាងម៉េចដែរ ចរិតពួកគាត់ មិញអ៊ំមានប្រសាសន៍ដូចតារិន គាត់លះបង់ គាត់ធ្វើ ការ, តាចាប គាត់អ្នករៀនសូត្រគាត់វៃឬក, តាអាន គាត់អត់សូវនិយាយ ។ ចុះពួកគាត់ ប៉ុន្មាននាក់នេះយ៉ាងម៉េចដែរ?

យុត៖ អត់អីទេ តាទី ស្លូតទៀត, តាចេន សុទ្ធតែស្លូត, តាណយ ស្រុកកំពតដែលចេះនិយាយអី ឃើញកាចជាងគេ តាសៀន ហើយតាផន ។ កាចមិនមែនថាកាចទៅធ្វើអីយើងទេ គ្រាន់ តែថាសំដី អាកប្បកិរិយា ចេញមកវាកាច ។ សំដីមិនទន់ភ្លន់ សុភាពរាបសារ វាមិនមែន ជាប្រចាំទេ ប៉ុន្តែដូចថាមានកន្លែងខ្លះគាត់មានការខឹង ។

ដានី៖ ហើយពួកគាត់ដល់ពេលឆ្នាំ៧៧ គាត់ផ្លាស់មកទាំងអស់គ្នា ឬអត់ទេ?

យុត៖ ៧៧?

ដានី៖ ៧៧ ដែលអ៊ំមានប្រសាសន៍ថាអ៊ំផ្លាស់?

យុត៖ ខ្ញុំផ្លាស់ទៅនៅកំពង់ចាម ។

ដានី៖ អ៊ំកាលពីឆ្នាំ៧៧មានផែនការយ៉ាងម៉េច យើងពីកំពតសោះ យើងផ្លោះទៅដល់កំពង់ចាម?

យុត៖ ហ្នឹងមិនដឹងខាងលើខ្ញុំមិនដឹងដែរ ។

ដានី៖ ប៉ុន្តែមុននឹងផ្លាស់ គេមានមកប្រជុំ គេមានមកប្រាប់អ៊ំថាម៉េច ឲ្យអ៊ំត្រៀមខ្លួន?

យុត៖ ប្រាប់តា៎ ឥឡូវយើងជិតដកយកទៅកំពង់ចាម ។

ដានី៖ អ្នកណាអ្នកប្រាប់ហ្នឹង?

យុត៖ តាចាប ។

ដានី៖ គាត់ថាទាំងគាត់ ជិតផ្លាស់ទៅកំពង់ចាម ឬគាត់តែអ៊ំមួយ?

យុត៖ អត់ទេ អ្នកណាត្រូវទៅបានគេប្រាប់យើង អ្នកអត់ទៅគេប្រាប់ធ្វើអី ។

ដានី៖ ខែប៉ុន្មានដែលអ៊ំផ្លាស់ទៅកំពង់ចាម?

យុត៖ ខែ១ ឆ្នាំ៧៧ ។

ដានី៖ កាលហ្នឹងតាចាប គាត់មកប្រាប់អ៊ំថា មានមូលហេតុអីដែលត្រូវផ្លាស់ទៅយ៉ាងម៉េច ឬអ៊ំ មានប្រាប់ថាអត់ចង់ទៅ ចង់នៅហ្នឹងទៀត ឬក៏យ៉ាងម៉េចដែល?

យុតៈ	អត់មានប្រាប់ផង តែខ្ញុំដឹងដែរ ខ្ញុំដឹងថា កាលហ្នឹងបើសិនជាដកខ្ញុំមានតែប្ដីខ្ញុំដកការកិច្ចមកយូរ ដកមកនៅកន្លែងកងទ័ព ដកមកនៅក្រោមហ្នឹង ។ ខ្ញុំដឹងដែរ ខ្ញុំដឹងថាប្រហែលជាខ្ញុំមានការងារអីដែលគេត្រូវដក ព្រោះប្ដីដកដែរ ។

ដានី៖	អ៊ីចឹងអ៊ំរៀបការឆ្នាំណា?

យុតៈ	ខ្ញុំការ៧៥ ។

ដានី៖	៧៥ពេលដែលយើងបែកភ្នំពេញរំដោះបានហើយ?

យុតៈ	ចាំ!

ដានី៖	ការខែប៉ុន្មានអ៊ំមានចាំទេ?

យុតៈ	អត់ចាំទេ ការសម័យហ្នឹងមិនចាំទេ មិនបានគិតទេ ។

ដានី៖	ការហ្នឹងអ៊ំការតែម្នាក់ឯង ឬក៏?

យុតៈ	កងទ័ពគេទៅរៀនសូត្រ យើងការកន្លែងហ្នឹង ចប់រៀនគេការឲ្យ ។

ដានី៖	ការនៅណាទៅ?

យុតៈ	ការនៅណាទេមិនបានចាំទេអូនអើយ វែងឆ្ងាយ ។

ដានី៖	កាលហ្នឹងអ៊ំហើយនិងប្ដីអ៊ំបានស្គាល់គ្នាពីមុន បានយើងបានការជាមួយគ្នា?

យុតៈ	ស្គាល់គ្នាជំនាន់ដែរ ជំនាន់ហ្នឹងយើងនៅកន្លែងកំពត ។

ដានី៖	កន្លែងនៅណា?

យុតៈ	កន្លែងកំពតហ្នឹង នៅជាមួយគ្នា គ្រាន់តែគេនៅកងទ័ព ខ្ញុំនៅកន្លែងស្រុកស្រែ ដូចកន្លែងស្រុកឈូកឆ្ងាយពីកំពតអ៊ីចឹង គេនៅកងទ័ព ។

ដានី៖	គាត់កងទ័ពរបស់ស្រុកឈូកដែរ?

យុតៈ	កងទ័ពរបស់តំបន់កំពត ។

ដានី៖	តំបន់៣៥ហ្នឹង?

យុតៈ	ចាំ!

ដានី៖	គាត់ជាកងទ័ពតំបន់៣៥ ហើយអ៊ំជាអ្នកគ្រប់គ្រងនារីនៅស្រុកឈូក?

យុតៈ	ចាំ!

ដានី៖	ដល់ពេលនេះអន្តភាពនៅជិតគ្នា?

យុតៈ	មិនជិតទេ មកពីកំពត មកឈូកមិនតិចគីឡូណា ។

ដានី៖	ម៉េចបានយើងស្គាល់គ្នា?

យុគៈ ចុះយើងទៅជួបគ្នាម្ដងមួយយាមអីទៅ ។

ដានីៈ កាលហ្នឹងគាត់ពេញចិត្តអ៊ំ អ៊ំស្គាល់គាត់?

យុគៈ ខានលើ ។

ដានីៈ ពីណាគេអ្នកណែនាំឲ្យ?

យុគៈ តាចាប គាត់អ្នកការឲ្យនិយាយមួយមាត់ឲ្យខ្ញុំអីចឹងទៅ យើងមិនមែនអ្នកស្រឡាញ់ទេ គាត់ចេះតែការឲ្យទៅ កាលហ្នឹងខ្ញុំអាយុ១៨-១៩ គាត់ថាយកប្ដីអត់? ខ្ញុំថាអេ៎ ខ្ញុំមិនចង់បានទេ ខ្ញុំចង់ធ្វើ ចង់នៅខ្លួនឯងទទេ ដើម្បីស្រណុកធ្វើការ ។ គាត់ថាមិនដែលអាណានៅទទេរមួយអាយុ៉សទេ ថាឲ្យអីចឹង ។ គាត់ថាចែងការ គាត់ហៅខ្ញុំចែ ចែងការទៅ ការជាមួយខ្ញុំមានឃើញម្នាក់នៅកន្ទែព ។ ខ្ញុំថាខ្ញុំមិនចង់បានទេ ដល់ហើយគាត់ការឲ្យ៧៥ ។

ដានីៈ អ៊ំប្រកែកថាអត់ចង់បានៗ គាត់នៅតែការឲ្យ?

យុគៈ ការឲ្យ ។

ដានីៈ ក្រែងអ៊ំចេះតែនិយាយអត់ចង់បាន តែក្នុងចិត្តអ៊ំ?

យុគៈ អត់ទេ នៅសម័យហ្នឹងយើងមិនអាចប្រកែកតឹងរឹងបានទេ អូនឯងត្រូវជឿទៅ បើយើងប្រកែកគេថាយើងប្រឆាំង អីចឹងចេះតែយកទៅ ខុសត្រូវអីយកសិន ។

ដានីៈ កាលហ្នឹងគ្រួសារអ៊ំគាត់ឈ្មោះអីទៅ?

យុគៈ ឈ្មោះអាំ ។

ដានីៈ ត្រកូលគាត់ឈ្មោះអីអាំ?

យុគៈ សង់ ដាំ ស្រុកគាត់នៅព្រៃវែង ។

ដានីៈ ឈ្មោះ សង់ ដាំ តែហៅអាំ វិញ ។ ជំនាន់ហ្នឹងឈ្មោះបដិវត្តន៍គាត់ឈ្មោះអាំ?

យុគៈ ឈ្មោះអាំ ឈ្មោះបដិវត្តន៍ ឈ្មោះដាំ ឈ្មោះសង់ ដាំ ។

ដានីៈ សង់ ដាំ ហ្នឹងឈ្មោះដើម?

យុគៈ ចា៎!

ដានីៈ គាត់អាយុប៉ុន្មានដែរ?

យុគៈ កាលការជាមួយខ្ញុំសាមជាងដឹង គាត់ចាស់ដែរ ។

ដានីៈ គាត់អាយុច្រើនជាអ៊ំប៉ុន្មានឆ្នាំ?

យុគៈ ច្រើនជាងខ្ញុំប្រហែលជា២-៣ឆ្នាំដឹង គាត់ចាស់ដែរ មិនមែនចាស់ពេកទេ តែចាស់ល្មមគាត់អាយុ ។

ដានី៖ តែអត់ដឹងថាគាត់កើតឆ្នាំអី? ឆ្នាំខ្មែរ?

យុត៖ អត់ដឹងទេ។

ដានី៖ ដូចអ៊ំកើតឆ្នាំច។

យុត៖ អត់ដែលសួរប្រវត្តិរូបប្ដីផង។

ដានី៖ អត់ដែលសួរទេ?

យុត៖ អត់ទេ។

ដានី៖ ដឹងតែគាត់អាយុច្រើនជាង?

យុត៖ ដឹងតែអាយុ៣៥កាលហ្នឹង។

ដានី៖ អាយុ៣៥កាលហ្នឹង អ៊ំទើបតែអាយុ១៨-១៩ហ្នឹង ហើយគាត់៣៥ហើយ គាត់ចាស់ច្រើនជាង?

យុត៖ គាត់ចាស់ជាង ចាស់ជាងខ្ញុំ។

ដានី៖ ស្រុកកំណើតនៅភូមិអីទៅនៅស្រុកព្រៃវែង?

យុត៖ មិនដឹងនៅភូមិអី លឺគាត់ថានៅស្រុកព្រៃវែង ខ្ញុំមិនដែលស្គាល់ណា។

ដានី៖ អត់ដែលទៅលេងស្រុកកំណើត?

យុត៖ អត់សោះ។

ដានី៖ ដែលស្គាល់បងប្អូន ម្ដាយក្មេកអី ប្អូនថ្លៃ បងថ្លៃ អត់ដែលស្គាល់?

យុត៖ អត់ដែលទៅ។

ដានី៖ អត់ដែលទៅលេងស្រុកនៅព្រៃវែងហ្នឹងសោះ?

យុត៖ អត់សោះ។

ដានី៖ គាត់មានប្រាប់ថាស្រុកគាត់នៅព្រៃវែង នៅម្ដុំណា?

យុត៖ គ្រាន់តែប្រាប់នៅព្រៃវែង តែមិនដឹងនៅត្រង់ណា បើខ្ញុំមិនដែលសួរគាត់ផង។

ដានី៖ កាលការហ្នឹងគាត់ធ្វើកងទ័ពនៅតំបន់៣៥ គាត់យ៉ាងម៉េច?

យុត៖ វរសេនាតូច។

ដានី៖ កាលហ្នឹងកងទ័ពនៅកំពតជាកងពល ឬអត់ទេ?

យុត៖ មិនដឹង ខ្ញុំមិនដឹងដែរ។

ដានី៖ គាត់ប្រធានវរសេនាតូចលេខប៉ុន្មានទៅកាលហ្នឹង?

យុត៖ អត់ស្គាល់។

ដានី:		ហើយប្រធានគាត់ ប្រធានធំជាងគេឈ្មោះអីទៅ?

យុត:		ប្រធានធំជាងគេមិនដឹងឈ្មោះអីបើខ្ញុំមិនដែលសួរនាំពីរឿងទ័ពផង និយាយទៅខ្ញុំមិនបានគិតរឿងទ័ព ខ្ញុំគិតតែការងារខ្ញុំដែរ ។

ដានី:		ពីណាគេគណៈតំបន់ដែលទទួលខាងកងទ័ព?

យុត:		មិនដឹងពីណាគេ គណៈតំបន់ទទួលកងទ័ព ។

ដានី:		កាលហ្នឹង តាចាប ។

យុត:		មិនដឹងពីណាគេទទួលខាងកងទ័ពនេះ មិនដឹងពីណាគេ ខ្ញុំមិនបានសួរតាចាប ។

ដានី:		តែដឹងថាប្ដីអ៊ំវរសេនាតូចទេកាលហ្នឹង?

យុត:		ចា៎!

ដានី:		ដល់ពេលការហើយអ៊ំនៅជាមួយគ្នា ឬអត់ទេ?

យុត:		អត់ទេ គាត់នៅកងទ័ពលិចកំពតទៅ ខ្ញុំនៅស្រុកឈូក នៅជិតផ្សារឈូកនេះ នៅកន្លែងនារីលើកទំនប់ នៅកន្លែងគាត់ដេរ ខ្ញុំមិនដែលបាននៅជាមួយគ្នាទេ ។

ដានី:		ប៉ុន្មានថ្ងៃបានយើងជួបគ្នាម្ដង?

យុត:		ខ្ញុំបានជួបតែថ្ងៃណាគាត់មកផ្ទះ ថ្ងៃណាគាត់មក គាត់មកលេងជាមួយខ្ញុំ ។

ដានី:		គាត់ស្នាក់នៅជាមួយអ៊ំប៉ុន្មានថ្ងៃ ប៉ុន្មានយប់ទៅ?

យុត:		មក១-២ថ្ងៃអីគាត់ទៅវិញ ថាឲ្យទៅជួបជុំគ្នាអត់ទេ ។

ដានី:		អីចឹងអ៊ំអត់សូវបានស្គាល់ប្រវត្តិគាត់ច្បាស់ទេ?

យុត:		អត់ទេ ។

ដានី:		ប៉ុន្តែដល់អ៊ំយើងការហើយ យើងមានមនោសញ្ចេតនា យើងស្រឡាញ់គ្នា?

យុត:		អត់ទេ ខ្ញុំអត់អីផង ដល់មកឆ្នាំ៧៦គេដកការកិច្ចខ្ញុំអន់ចិត្ត ខ្ញុំស្ដាយខ្លួន ហើយគាត់ជាសាស្ត្រាចារ្យមួយរូប ។

ដានី:		គាត់ជាសាស្ត្រាចារ្យ?

យុត:		គាត់មិនមែនអ្នកអត់ចេះណា៎ គាត់អ្នកចេះ ។

ដានី:		ដល់ឆ្នាំ៧៦ គេដកការកិច្ចគាត់?

យុត:		ដកចេញពីទ័ពតែម្ដង ។

ដានី:		ឲ្យទៅនៅធ្វើអីវិញ?

យុត:		ឲ្យមកនៅកាន់ធនាគារនៅកន្លែងតំបន់ នៅកន្លែងមន្ទីរខេត្ត ។

ដានីៈ	មន្ទីរខេត្តនៅណា?

យុតៈ	ខេត្តកំពតហ្នឹង ។

ដានីៈ	នៅតំបន់៣៥ហ្នឹង?

យុតៈ	ហ្នឹងហើយ តែគេដកគាត់មកដាក់ហ្នឹង ដាក់ធនាគារ មិនទាន់បានចាយលុយណា ។

ដានីៈ	អត់មានចាយលុយ តែម៉េចឲ្យគាត់ទៅ?

យុតៈ	អត់មានលុយខាងលើចេះតែឲ្យមក អត់ទាន់មានចាយណាំ ។

ដានីៈ	គេប្រុងឲ្យលុយមកចាយ?

យុតៈ	គេឲ្យលុយតាំ កាលហ្នឹងបង្កើតលុយហើយ មានធនគារគ្រប់ខេត្តហើយ ។

ដានីៈ	គេប្រុងចាយលុយពីឆ្នាំណា?

យុតៈ	ពីឆ្នាំ៧៦ហ្នឹងប្ដីខ្ញុំកាន់លុយហ្នឹង ។

ដានីៈ	តែលុយហ្នឹងអត់បានចាយដល់ប្រជាជនទេ?

យុតៈ	អត់ទាន់បានចាយទេ ។

ដានីៈ	ម៉េចបានអត់ទាន់បានចាយ?

យុតៈ	មិនដឹងម៉េច ខ្ញុំមិនដឹងដែរខាងលើ មិនដឹងគេរៀបរយយ៉ាងម៉េច គ្រាន់តែសួរថា ឥឡូវធ្វើកង់ទ័ពហេតុអីមកនៅកាន់ធនាគារ? គេថាអញបេសេអេអីម៉េច ។

ដានីៈ	អ៊ំសួរប្ដីអ៊ំ?

យុតៈ	ចាំ!

ដានីៈ	គេថា "កា-សេ-បេ"?

យុតៈ	កា-សេ-បេ បន្ទប់ម៉េចទេ ។ ការហើយដកភារកិច្ចភ្លាម ការ៧៥, ៧៦ដក ។

ដានីៈ	អ៊ំអន់ចិត្ត ការរួចអន់ចិត្តដែរ?

យុតៈ	អន់ចិត្តក៏ខ្ញុំមិននិយាយ យើងមិននិយាយ បើខុសហើយ ។

ដានីៈ	អ៊ំដល់គេដកភារកិច្ចគាត់អីចឹង អ៊ំមានអារម្មណ៍ចង់ឈប់ស្រឡាញ់គាត់?

យុតៈ	អត់ទេ ខ្ញុំអត់មានចង់ឈប់ទេ ខ្ញុំអាណិតគាត់ គាត់ខំធ្វើចង់ងាប់ហើយមកដល់កណ្ដាលទីខ្ញុំមិននិយាយ និយាយធ្វើអីបើការងារសកម្មប្រយុទ្ធ ដូចតារិន អីចឹងអត់ចេះចង់បានអីដូចគ្នាពីដើមធ្លាប់អ្នកមាន និស្សិតដែរ ដល់មកកម្មាជីវូអីចឹងយ៉ាប់ដែរ ខ្ញុំចេះតែអន្ដុយអាណិតប្ដីដែរ នឹកឃើញអាណិត តែខ្ញុំមិននិយាយទេ និយាយទៅខាងលើថាខ្ញុំចេះចុះ ។

| | |
|---|---|
| ដានី៖ | ដល់ពេលអ៊ីចឹងគ្រាន់តែអ៊ំអន់ចិត្តក្នុងខ្លួនឯង ពេលជួបតាម៉ុក អត់មាននិយាយប្រាប់គាត់ថាប្ដីខ្ញុំ! |
| យុត៖ | ទៅនិយាយយ៉ាងម៉េច ខ្ញុំមិននិយាយទេ ។ |
| ដានី៖ | ព្រោះអ៊ំក្រែងស្គាល់គាត់ជិតដិតដែរ! |
| យុត៖ | ស្គាល់ក៏យើងមិនអាចទៅនិយាយរឿងអ៊ីចឹងបាន ។ |
| ដានី៖ | យើងមានទុក្ខផ្ទាល់ខ្លួនអ៊ីចឹង យើងអាចប្រាប់គាត់ថា តា គ្រួសារខ្ញុំវាចេះចុះ ឲ្យគាត់ជួយដោះស្រាយឲ្យអត់ទេ? |
| យុត៖ | ខ្ញុំអត់មាន និយាយទេ ។ |
| ដានី៖ | កាលនោះដោយសារវិន័យយើងធ្លាប់រៀនសូត្រមកអ៊ីចឹង ឬក៏អ៊ំដូចថាចិត្តខ្លួនឯង រឿងផ្ទាល់ខ្លួនមិនចង់និយាយប្រាប់គាត់ រឿងផ្ទាល់ខ្លួន? |
| យុត៖ | វិន័យគេដាក់ហើយតាំ ។ |
| ដានី៖ | គេថាម៉េច? |
| យុត៖ | ប្ដី-ប្រពន្ធតែការហើយៗ អត់មានរឿងអីទាក់ទិនទៀត គេមានច្បាប់គេ ។ |
| ដានី៖ | គេមានច្បាប់របស់គេ? |
| យុត៖ | ច្បាប់មិនមែនថាគាបសង្កត់ទេ គ្រាន់តែប្ដី-ប្រពន្ធតែយើងការហើយ យើងគ្មានរឿងអីលែងលះ ខ្ញុំគ្រាន់តែការហើយដកការកិច្ចរហូត ។ |
| ដានី៖ | ៧៦ គេដកគាត់ឲ្យទៅខាងធនាគារនៅតំបន់នៅកំពតវិញ ហើយយ៉ាងម៉េចទៀតទៅ? យើងដូចថា អ៊ំហើយនិងគាត់នៅតែ? |
| យុត៖ | សាមគ្គីគ្នាដដែល ខ្ញុំអត់មានបញ្ហា ។ |
| ដានី៖ | រយៈពេលប៉ុន្មានទៅវាកាន់តែឆ្ងាយពីគ្នា គាត់នៅកំពត អ៊ំនៅឈូក? |
| យុត៖ | ហ្នឹងដឹងធ្វើម៉េចការងាររៀងខ្លួន ។ |
| ដានី៖ | ប៉ុន្មានខែ ប៉ុន្មានអាទិត្យ? |
| យុត៖ | គាត់អត់សូវមកទេ កាលហ្នឹងគាត់ឈប់ភារកិច្ច គាត់អត់សូវមកផ្ទះទេ ខ្ញុំដូចថាខាងកិច្ចការនារីស្រុក អ៊ីចឹងគេហៅទៅកំពតជួបគ្នាម្ដងអីទៅ ។ |
| ដានី៖ | ជួបគ្នាម្ដងអីចឹង? |
| យុត៖ | គេទៅប្រជុំខេត្ត ។ |
| ដានី៖ | កាលហ្នឹងដូចថាជីវិតយើងជាគ្រួសារដូចលំបាកដែរ អត់ស្រួល? |

យុត៖ លំបាក បើយើងនិយាយឲ្យវែងឆ្ងាយដកប្ដីនេះ៧៦-៧៧-៧៨បានចាប់ ។

ដានី៖ ៧៨បានចាប់?

យុត៖ ដកទៅកំពង់ចាម ទៅជាមួយខ្ញុំដែរ តែអត់មានការកិច្ចអីទេ និយាយខ្ញុំមានការឈឺចាប់ជាមួយប្ដីតាំងពី៧៦មករហូត ។ និយាយរួមគេដកការកិច្ចតាំងពី៧៦-៧៧-៧៨ ។

ដានី៖ ដល់ពេល៧៦គេដកគាត់ឲ្យទៅនៅខាង!

យុត៖ ដកទៅជាមួយខ្ញុំ ។

ដានី៖ ៧៦គេដកគាត់ហើយឲ្យទៅនៅកំពតសិន ។

យុត៖ ទៅកំពតម៉េចឲ្យទៅកំពង់ចាមជាមួយខ្ញុំដែរ ។

ដានី៖ ហ្នឹងឆ្នាំ៧៧អី?

យុត៖ ៧៧ ។

ដានី៖ ៧៧ ខែមករា ដែលអ៊ំទៅកំពង់ចាម ។

យុត៖ គាត់ទៅដែរ ។

ដានី៖ ពេលដែលទៅកំពង់ចាម ជំនាន់ដែលអ៊ំទៅតែអ៊ំទេ?

យុត៖ ខ្ញុំទៅជាមួយបងប្អូនខ្ញុំ សាច់ឈាមខ្ញុំ ម៉ែឪខ្ញុំ ។

ដានី៖ បងប្អូនអ៊ំ, ម្ដាយអ៊ំ, ប្ដីអីទៅទាំងអស់?

យុត៖ ទៅទាំងអស់ ។

ដានី៖ តែអ្នកផ្សេងៗទៀត អ្នកដែលកម្មាភិបាលធ្វើការនៅក្នុងស្រុក?

យុត៖ អត់ទេ អត់មានទៅជាមួយទេ ខ្ញុំទៅជាមួយបងប្អូនខ្ញុំ កាលហ្នឹងខ្ញុំទៅមុនគេ ។

ដានី៖ កាលហ្នឹងតាអាន គាត់ទៅនៅ?

យុត៖ ទៅក្រោយទាំងអស់ ខ្ញុំទៅមុនគេបង្អស់

ដានី៖ អ៊ំទៅមុនគេទាំងអស់?

យុត៖ ចា៎ ។

ដានី៖ ដល់ពេលអ៊ំទៅ ចេញពីកំពតអ៊ំ?

យុត៖ ចេញពីកំពត ទៅដេកភ្នំពេញ ។

ដានី៖ អត់មានចូលតាកែវទេ?

យុត៖ អត់ទេ ។

ដានី៖ ចេញពីកំពតជិះអី?

យុត៖ ជិះឡានអាសែងសង់អាធំ គេហៅអាឡានកង់១០ ។

ដានី៖ អាកង់១០ អាសែងសង់ហ្នឹង?

យុត៖ ហ្នឹងហើយអាសែងសង់ ។

ដានី៖ អាសែងសង់ជិះឡានទៅ តែទៅតែមួយគ្រួសារអ៊ំ?

យុត៖ ទៅមួយគ្រួសារហើយមាននារី៤-៥នាក់ខ្ញុំយកទៅតាម ។

ដានី៖ ដូចថាអ្នកដែលធ្លាប់នៅជាមួយអ៊ំ?

យុត៖ អ្នកធ្លាប់ស្គាល់បងប្អូនសាច់ញាតិខ្ញុំទៅដែរ ។

ដានី៖ ដូចតាចាប, តារិន ឬតាអាន គាត់អត់មានជូនដំណើរអ៊ំទេ?

យុត៖ អត់ទេ ជូនដំណើរម៉េច អាហ្នឹងភារកិច្ចគេទៅណាផ្សេង ទៅជាមួយគ្នាតែគេជូនដំណើរ ផ្សេងៗពីគ្នា ។

ដានី៖ ព្រោះឥឡូវឃើញអ្នកធ្វើការធំអី គេទៅណាមានឃើញអ្នកធំជូនដំណើរ?

យុត៖ អត់ទេ ។

ដានី៖ កាលជំនាន់ហ្នឹងអ៊ំទៅតែឯងអីចឹងទៅ?

យុត៖ ទៅជាមួយកូនចៅខ្ញុំ បងប្អូនខ្ញុំ ។

ដានី៖ តាចាប គាត់គ្រាន់តែមកជួបអ៊ំ មកប្រាប់អ៊ំថាថ្ងៃនេះៗទៅ ។ មកប្រជុំប្រាប់អីចឹង គាត់ អត់មានមក ។ មានធ្វើពិធីជប់លាងអីជូនដំណើរយើងចេញទៅនៅភារកិច្ចថ្មី?

យុត៖ អត់ទេ ។

ដានី៖ អត់មានជប់លាងអីទេ?

យុត៖ អត់ទេ ។

ដានី៖ អីចឹងអ៊ំដល់ពេលចេញពី ជិះឡានពីកំពតទៅសំរាកនៅភ្នំពេញ២យប់?

យុត៖ ២យប់ ។

ដានី៖ អ៊ំទៅសំរាកនៅកន្លែងណាទៅភ្នំពេញ?

យុត៖ អត់ស្គាល់ មិនដែលស្គាល់ទេ តាំងពីរំដោះហើយ៧៥មិនដឹងដែរ ។

ដានី៖ ម្តុំណាដែរ?

យុត៖ អត់ដឹងម្តុំណាទៀត ។

ដានី៖ កាលពីមុនហ្នឹងអ៊ំអត់ដែលទៅភ្នំពេញសោះ?

យុគៈ ខ្ញុំទៅ តែទៅកន្លែងណាវៀនៗហ្នឹងតែម្តង ខ្ញុំមិនដែលដើរ ។ ដូចថាកិច្ចការនារីត្រូវហៅម្តងមួយយាមយើងទៅ តែវៀនកន្លែងណាកន្លែងហ្នឹងហើយ ។

ដានីៈ កន្លែងណា?

យុគៈ មិនដឹងកន្លែងណាបើខ្ញុំមិនដែលស្គាល់ភ្នំពេញផង ។

ដានីៈ ស្ពានអូឡាំពិក?

យុគៈ អត់ដឹង ។

ដានីៈ បូរីកីឡាអីអឺដែលស្គាល់ទេ?

យុគៈ មិនដឹងម៉េច ។

ដានីៈ ដល់ពេលទៅស្នាក់នៅគេឲ្យយើងដើរទស្សនកិច្ចកន្លែងនេះវាំង?

យុគៈ អត់ទេ ខ្ញុំមិនដែលដើរទៅដល់យប់ មើលចេញម៉ោង៣មកដល់ភ្នំពេញយប់ ។

ដានីៈ ក្រែងលោប្តីអឺស្គាល់ភ្នំពេញអី គាត់ដឹង?

យុគៈ នៅភ្នំពេញក៏គាត់អត់មាត់ ។

ដានីៈ គាត់អត់ប្រាប់ថានេះស្នាក់នៅម្តុំណា?

យុគៈ គាត់មិននិយាយជាមួយខ្ញុំទេ ។

ដានីៈ ពីណាមកទទួលអឺដែលអត់ ពេលស្នាក់នៅ?

យុគៈ ទទួលអីគេដឹកយើងទៅដល់កំពង់ចាមតែម្តង ។

ដានីៈ ពេលយើងស្នាក់នៅភ្នំពេញ២យប់នោះ?

យុគៈ អាហ្នឹងដូចថាកន្លែងផ្ទះគេស្នាក់ គេសំរាប់ស្នាក់ គេទទួលអ្នកផ្ទះស្នាក់ហ្នឹង យើងស្នាក់ផ្ទះគេ

ដានីៈ គេមានប្រាប់ពីរបៀបរបប ដូចថាយើងធ្លាប់នៅកំពត យើងផ្លាស់ទៅនៅកំពង់ចាមថ្មី គេប្រាប់របៀបរបបថ្មី អ្នកនៅកំពង់ចាមការងារ សភាពការណ៍យ៉ាងម៉េច ពេលដែលយើងទៅយើងត្រូវធ្វើការងារអីយ៉ាងម៉េច គេមានប្រាប់ ណែនាំពីបទពិសោធន៍ឲ្យយើងទៅ?

យុគៈ អត់ទេ គ្រាន់តែប្រាប់ទៅដល់នោះ អត់មានប្រាប់អីទេ គ្រាន់តែយើងចេញពីកំពតទៅដេកភ្នំពេញ ចាំទៅដល់កំពង់ចាម គេប្រគល់ភារកិច្ចហើយគេប្រជុំគណៈភូមិភាគ ។

ដានីៈ គេប្រាប់អីចឹង?

យុគៈ គេនិយាយអីចេះ យើងមិនដឹងរឿងគេទៅនេះ គេមិនប្រាប់តាមដំណើរទេ ថាទៅដល់នេះយើងប្រជុំ ។

ដានីៈ គេប្រាប់ពីនេះទៅ តាចាប អ្នកប្រាប់?

យុត៖ គាចាប គាត់ប្រធានតំបន់ ។

ដានី៖ អីចឹងពេលដែលអ៊ំទៅដល់កំពង់ចាម អ៊ំទៅស្នាក់នៅណា?

យុត៖ ស្នាក់នៅមន្ទីរភូមិភាគគេ ។

ដានី៖ មន្ទីរភូមិភាគនៅកំពង់ចាម ។

យុត៖ ចា៎! នៅក្រុង ។

ដានី៖ ស្នាក់នៅបានយូរទេ?

យុត៖ ស្នាក់ទំរាំជួបជុំគ្នាយូរដែរ ៤-៥ថ្ងៃ ។

ដានី៖ ទៅដល់គេរាក់ទាក់អ៊ំទេ?

យុត៖ អត់អីទេ គេរាក់ទាក់ព្រោះគេដឹងថាសំបុត្រខ្មែរទេសនាមយើងទៅដល់ហើយ ។

ដានី៖ យើងកាន់សំបុត្រ?

យុត៖ យី! មិនមែនចេះតែទៅទេ មានសំបុត្រខ្មែរទេសនាមពីតំបន់នេះចេញទៅតំបន់នោះ យើងមានសំបុត្រហ្នឹង ។

ដានី៖ យើងកាន់សំបុត្រខ្មែរទេសនាមទៅ ខាងនោះមានសំបុត្រ ។

យុត៖ គេផ្ញើរទៅហួសបាត់ហើយ ។

ដានី៖ គ្រាន់តែយើងកាន់ទៅសំគាល់ថាយើងចេញពីនេះទៅ?

យុត៖ យើងពីនេះទៅ ដឹងថាទៅដល់នោះហើយ គេយកបាយ ដាំបាយទុកឲ្យយើង ។

ដានី៖ អ៊ំបានអានទេសំបុត្រខ្មែរទេសនាម?

យុត៖ អត់ទេ ខ្ញុំមិនបានអាន ខាងលើគេអ្នកបញ្ជូនឲ្យខាងលើ ។

ដានី៖ តែយើងទៅយើងមានកាន់សំបុត្រខ្មែរទេសនាមទៅទេ?

យុត៖ អត់ទេ សំបុត្រគេផ្ញើរទៅមុនបាត់ហើយ ។

ដានី៖ គាចាប ផ្ញើរទៅ ឬចេញពីភ្នំពេញ?

យុត៖ គាចាប ។

ដានី៖ មិនមែនសំបុត្រចេញពីភ្នំពេញ?

យុត៖ យើងវាមិនដឹងរឿង ខាងលើគេគាក់គុបម៉េចយើងអត់ដឹងទេ ឧទាហរណ៍គាចាប ទាក់ទងជាមួយខាងលើ ភ្នំពេញយ៉ាងម៉េចយើងអត់ដឹងទេ យើងដឹងតែធ្វើដំណើរទៅកំពង់ចាមទេ និយាយឲ្យខ្លីអីចឹងតែម្តង ព្រោះខាងលើគេមិនអាច ខេត្តក៏គេមិនអាចប្រាប់យើង ស្អីៗគេ

អត់ប្រាប់ទេ អីចឹងខាងភ្នំពេញគេដឹងតែខទ្មេសនាមទៅឲ្យកំពង់ចាម យើងចេះតែទៅតាមសេចក្ដីត្រូវការរបស់ខាងលើទៅ មិនអីចឹង យើងអត់ទៅស្រាវជ្រាវរឿងសំបុត្រស្នាមអី ។

ដានី: តែទៅដល់កន្លែងកំពង់ចាម អ៊ំនៅកន្លែងមន្ទីរភូមិភាគ៤-៥ថ្ងៃដែរ?

យុត: នៅចាំគេទំរាំទៅមូលអស់រៀបរយ ។

ដានី: គេប្រជុំថាម៉េចខ្លះទៅ?

យុត: គេប្រជុំរៀបរយចាត់តាំងតាមស្រុក អ្នកណានៅភូមិណា អ្នកណានៅឃុំណា អ្នកណានៅស្រុកណា ។

ដានី: ក្នុងចំណោមអ៊ំទៅមួយឡានអ៊ំហ្នឹងគេប្រជុំ!

យុត: អត់ទេ ខ្ញុំមានអ្នកធ្វើការតិច មានតែខ្ញុំធ្វើការ ។

ដានី: ក្រៅពីហ្នឹង សូម្បីតែប្ដីអ៊ំក៏គេអត់មានឲ្យតួនាទីអី?

យុត: ប្ដីខ្ញុំអត់មាននាទីអីទេ ទៅដល់ហ្នឹងសិយ ដេកអត់ប្រយោជន៍ ។

ដានី: បានន័យថាគាត់ទៅអត់មានទៅធ្វើការអីនៅក្នុងមន្ទីរ ឬសហករណ៍ ទៅធ្វើស្រែ ធ្វើចំការអីគេ?

យុត: គេឲ្យនៅប្រធានមន្ទីរ ។

ដានី: ស្រុក?

យុត: ប្រធានមន្ទីរស្រុក ។

ដានី: មន្ទីរតំបន់ ឬនៅស្រុក?

យុត: នៅតំបន់ គ្រាន់តែគេប្រកាសថាឲ្យយើងនៅតំបន់ហ្នឹង យើងធ្វើអីធ្វើ អត់សូវដឹង ។

ដានី: គ្រាន់តែគេប្រកាសឲ្យទេ?

យុត: អ៊ឺ!

ដានី: កាលហ្នឹងទៅដល់កំពង់ចាម តាពក?

យុត: តាពក ។

ដានី: តាពក គាត់ធ្វើធំជាងគេ អ្នកក្ដាប់រួម?

យុត: តាពក ប្រធានភាគកណ្ដាល ។

ដានី: កាលហ្នឹងមានតែតាពក ម្នាក់ឬមានពីណាទៀត?

យុត: អត់ដឹងប៉ុន្មាននាក់ទេ ខ្ញុំទៅដល់ដំបូងឃើញតាពក ប្រកាស ។

ដានី: តាពក គាត់ប្រកាស គាត់ប្រជុំ?

យុត:	គេអ្នកប្រជុំ គេអ្នកភាគ ។

ដានី:	ប្រជុំគ្នាច្រើនទេកាលហ្នឹង?

យុត:	ពួកអ្នកទៅហ្នឹង ។

ដានី:	អ្នកទៅពីកំពត?

យុត:	ពីកំពត ពីណា ពីណីខ្លះខ្ញុំមិនសូវដឹង ។

ដានី:	អ៊ំមានដឹងថាតាំងពីកំពតទៅ ថាអ៊ំត្រូវទៅហ្នឹង ទៅនៅត្រង់ណា ទៅនៅស្រុកកំពង់សៀម អ៊ំដឹងពីនេះទៅដែលអត់?

យុត:	អត់ដឹង ។

ដានី:	អត់ដឹងទាល់តែតាពក គាត់អ្នកប្រកាសទេ?

យុត:	ដល់គណៈតំបន់គេប្រកាសវិញ ពីកំពតគេចាត់តាំងហើយ តែគណៈតំបន់ថាអ្នកណាកំពង់សៀម, ណាកងមាស គេប្រកាសឲ្យយើង ។

ដានី:	កាលហ្នឹងគណៈតំបន់ពីណាគេ? កាលហ្នឹងតាអាន អត់ទាន់ទៅទេ?

យុត:	តាអាន ទៅហើយគាត់ធ្វើគណៈតំបន់៤១ហ្នឹង ។

ដានី:	គាត់ទៅមុនអ៊ំទេ?

យុត:	គាត់ទៅក្រោយខ្ញុំមែន តែគាត់ទៅជុំគ្នា ថ្ងៃគេប្រកាសគាត់ទៅដល់អស់ហើយ ។

ដានី:	ពេលប្រជុំនៅកន្លែងភូមិភាគតាពក គាត់ប្រជុំ គាត់ប្រកាសថា!

យុត:	ទោះបីគេទៅដេកដាច់ៗគ្នា មិនដឹងគេដេកណាខ្លះយើងមិនដឹង គេយកយើងទៅដាក់កន្លែងផ្សេង នោះផ្សេងៗ មួយភូមិភាគ បានគេថាព្រឹកហ្នឹងប្រជុំបានជុំគ្នាទៅ ប្រជុំគ្នាគេប្រកាស ។

ដានី:	ដល់ពេលតាពក គាត់ធ្វើប្រជុំអីចឹង ដល់ពេលគណៈតំបន់ តាអាន ទេគាត់អ្នកប្រកាសថា អ៎! អ៊ំទៅកំពង់សៀម ។

យុត:	ហ្នឹងដល់យើងមកប្រជុំតំបន់វិញទៀត ។

ដានី:	មកប្រជុំនៅតំបន់វិញ?

យុត:	យើងមកពីភូមិភាគ យើងប្រជុំនៅតំបន់គ្នាយើងទៅ ។

ដានី:	តំបន់នៅណាកាលហ្នឹង?

យុត:	តំបន់នៅស្រុកព្រៃឈរ ។

ដានី:	ហ្នឹងតំបន់៤១?

យុត៖ តំបន់៤១ ។

ដានី៖ ស្រុកព្រៃឈរ ។ កាលហ្នឹងអ៊ំស្គាល់ព្រៃឈរច្បាស់ទេ?

យុត៖ អត់ច្បាស់ទេ តែគេហៅព្រៃឈរ ចេះតែថាព្រៃឈរ យើងមិនដែលស្គាល់ដី ។

ដានី៖ ឆ្ងាយទេជិះពីកំពង់ចាមមក?

យុត៖ ប្រហែល១៥គីឡូ ។

ដានី៖ កាលហ្នឹងគេឲ្យយើងជិះខ្លួនឯង ឬគេជូនឡាន?

យុត៖ ភូមិភាគគេជូនដាក់ ។

ដានី៖ ឡានយើងជិះពីកំពតទៅ ឬឡានផ្សេង?

យុត៖ ឡានភូមិភាគគេ ឡានគេនោះ ឡានយើងមកពីនិរតីទៅវិញអស់ហើយ មានតែឡាន ភូមិភាគទេជូនដើរដាក់ ។

ដានី៖ ឡានគេ ឡានម៉ាកអីទៅអ៊ំ?

យុត៖ ទេ មិនដឹងម៉ាកអីទេ ខ្ញុំមិនបានមើល ។

ដានី៖ ឡានគេតូចៗដូចឡានយើងជិះ?

យុត៖ អត់ទេ មិនមែនឡានតូចទេ សុទ្ធតែឡាន Jeepចិន ។ កាលហ្នឹងមិនទាន់មានចេះសុទ្ធតែ Jeepចិន ។

ដានី៖ ដល់ពេលដែលអ៊ំមក ក្រុមគ្រួសារដែលអ៊ំទៅជាមួយ ដូចឪពុកម្ដាយ បងប្អូន ប្ដីយើងជិះ ឡានមកប្រជុំនៅព្រៃឈរទាំងអស់គ្នា?

យុត៖ ទេ បងប្អូនខ្ញុំគ្មាននាទីអីត្រូវមកប្រជុំ ។

ដានី៖ គាត់ស្នាក់នៅកំពង់ចាមនោះទេ?

យុត៖ ហ្នឹងហើយ ដល់គេថានៅស្រុកណា ខ្ញុំមានទីតាំងខ្ញុំហៅមក ។

ដានី៖ អីចឹងអ៊ំទៅប្រជុំនៅព្រៃឈរសិនទេ ។ កាលហ្នឹងទៅប្រជុំនៅព្រៃឈរ តាអាន គាត់ទៅ ហើយ?

យុត៖ តាអាន ទៅហើយគាត់ប្រធានតំបន់ ។

ដានី៖ ប៉ុន្មាននាក់ទៅកាលប្រជុំនៅព្រៃឈរ?

យុត៖ មិនដឹងប៉ុន្មាននាក់ទេ ។

ដានី៖ កាលហ្នឹងតំបន់៤១ មានស្រុកប៉ុន្មានទៅ?

យុត៖ កងមាស, កំពង់សៀម, ជើងព្រៃ, បាធាយ តែប៉ុណ្ណឹង ។

ដានី៖ កងមាស ស្រុកព្រៃឈរ ដែរ?

យុត៖ ស្រុកព្រៃឈរ ។

ដានី៖ ស្រុកព្រៃឈរ, ស្រុកបាធាយ, ស្រុកជើងព្រៃ, ស្រុកកំពង់សៀម ។

យុត៖ ៥ស្រុក ។

ដានី៖ កាលហ្នឹងមានតែ៥ស្រុកទេ កំពង់ចាមកាលហ្នឹង?

យុត៖ តំបន់៤១ ។

ដានី៖ ដល់ពេលទៅប្រជុំគេបែងចែកអ្នកណានៅស្រុកណា?

យុត៖ ចា៎!

ដានី៖ កាលហ្នឹងគេប្រកាសតែម្តង ខាងគណៈតំបន់គេប្រកាសថាអ៊ំត្រូវទៅទទួលខាងកំពង់សៀម ហើយគេមានប្រាប់ថាកំពង់សៀមភូមិសាស្ត្រអីយ៉ាងម៉េចៗ គេមានប្រាប់អត់?

យុត៖ គេប្រកាសហើយ គេគ្រាន់តែប្រាប់ថាយើងនៅស្រុកកំពង់សៀម ។

ដានី៖ ប៉ុន្មាននាក់ទៅនៅកំពង់សៀមជាមួយអ៊ំ?

យុត៖ ខ្ញុំកាលហ្នឹងទៅដល់មានស្រុកគេចាស់នៅហ្នឹងទៀត មានតាស៊ី ហើយខ្ញុំស្គាល់តែមួយហ្នឹងទៀត ឃើញស្រុកហ្នឹងចាស់ ក្រៅពីហ្នឹងខ្ញុំអត់ដឹង ។

ដានី៖ តាស៊ី ហើយនិងអ៊ំ ។

យុត៖ ខ្ញុំមិនបាន មិនដឹងអ្នកណាប្រធាន អ្នកណាអនុទៀត ។

ដានី៖ ដល់ពេលអ៊ំទៅគេប្រកាសអីចឹង ចុះនៅខាងកងមាស?

យុត៖ កងមាសអត់ដឹងដែរ ខ្ញុំដឹងតែស្រុកខ្ញុំ ។ ខ្ញុំមិនបានចូលរួមទេគ្រាន់តែចែកភារកិច្ចគ្នាហើយបែកគ្នា មិនដឹងណានៅស្រុកណា ប្រកាសខ្លួនឯងទៅ ខាងតំបន់ហ្នឹងទៅជួយធ្វើទៅបើស្រុកណាមិនចេះ តែស្រុកខ្ញុំ ពេលខ្ញុំទៅដល់មានតាស៊ី ប្រធានអីចឹង ខ្ញុំដឹងតែតាស៊ី ស្រុកក្រៅពីហ្នឹងមានតាអាន អ្នកទៅប្រាប់ប្រធានស្រុកទៀតទៅ មិនសូវដឹង មិនសូវយល់ដែរខ្ញុំទៅមុនដំបូង ។

ដានី៖ តាអាន គាត់នៅតំបន់៤១ តាអាន ពីណាខ្លះទៅ? កាលហ្នឹងអ៊ំមានប្រសាសន៍ថាអ៊ំទី៤នៅក្នុងតំបន់៤១ហ្នឹងដែរ ។ តាអាន គាត់ទី១ហើយអីចឹង ចុះទី២?

យុត៖ មិនដឹងអ្នកណាទេ ខ្ញុំមិនចាំដែរ ។

ដានី៖ ខ្ញុំធ្លាប់អានក្នុងចម្លើយសារភាព ក្នុងហ្នឹងមានឈ្មោះតាស៊ឹម អ៊ំស្គាល់ឈ្មោះតាស៊ឹម?

យុត៖ តាស៊ឹម មួយទៀតអនុប្រធានតាអាន ។

ដានី៖ ចុះតាភីម?

យុគៈ តាភីម សមាជិកទី២ ។

ដានី៖ តាភីម គាត់ទី២ ឬទី៣?

យុគៈ ខ្ញុំអត់ច្បាស់លាស់ដែរ រឿងតាភីម តែទាំងអស់ហ្នឹងសុទ្ធតែឈ្មោះសមាជិកហើយ តែមិនដឹងទី១, ទី២ ។ តាភីម មិនដឹងទីប៉ុន្មាន ។

ដានី៖ តាម៉ុន?

យុគៈ តាម៉ុន មិនដឹងទីប៉ុន្មានខ្ញុំមិនបានកត់ទុក ។

ដានី៖ តែសុទ្ធតែសមាជិកក្នុងហ្នឹង?

យុគៈ អ៊ឺ!

ដានី៖ តាកាន?

យុគៈ តាកាន អត់ទេ ។ អូនឯងមើលដឹងអស់ហើយមកសួរខ្ញុំ ។

ដានី៖ អត់ទេ ខ្ញុំអានពីចំលើយសារភាពរបស់គាឈុំ ដល់រូចទៅខ្ញុំចង់សួរអ៊ីបន្ថែមទៀត ។

យុគៈ មិនហួសហ្នឹងទេ ។

ដានី៖ ក្នុងចំលើយសារភាពហ្នឹងគាត់ថាតាកាន នៅកងមាស?

យុគៈ ហ្នឹងហើយ ត្រូវហើយ ។

ដានី៖ ហើយតាស៊ីម គាត់នៅព្រៃឈរ?

យុគៈ ហ្នឹង ។

ដានី៖ តាភីម គាត់នៅបាធាយ?

យុគៈ ចា៎!

ដានី៖ តាម៉ុន នៅជើងព្រៃ?

យុគៈ ជើងព្រៃ ។

ដានី៖ កាលហ្នឹងពួកគាត់សុទ្ធតែចេញពីកំពត អ៊ីធ្លាប់ស្គាល់គ្នាពីកំពតទៅដែលអត់ទេ?

យុគៈ អត់ទេ ស្គាលនៅនោះ ។

ដានី៖ ពីកំពតទៅអ៊ីស្គាល់ពីណាខ្លះទៅ?

យុគៈ អត់មានទេ ខ្ញុំស្គាល់ពូអាន មួយ ។

ដានី៖ ស្គាល់តែតាអាន មួយទេ?

យុគៈ ចា៎!

ដានី៖ អីចឹងចេញពីខាងកំពត មានតែតាអាន មួយទេ?

យុត៖ ចា៎!

ដានី៖ តាស៊ីម, តាភីម?

យុត៖ អត់ស្គាល់ ខាងលើបញ្ជូន ខ្ញុំអត់ដឹង ។

ដានី៖ តាម៉ុន នេះគាត់មិនមែនមកពីខាងកំពតទេ?

យុត៖ អត់ដឹង ។

ដានី៖ តាកាន, តាភីម, តាស៊ីម, តាម៉ុន?

យុត៖ ទៅពីខាងណាខ្ញុំអត់ដឹងទេ ព្រោះខាងលើគេយកទៅដាក់ ។

ដានី៖ តែមិនមែនពីខាងកំពតទៅទេ?

យុត៖ អត់ទេ អត់ស្គាល់ ។

ដានី៖ តែបើខាងកំពតអ៊ីស្គាល់ហើយ?

យុត៖ ចា៎!

ដានី៖ ទីតាំងស្រុកគេឆ្ងាយៗពីគ្នាទេ?

យុត៖ ឆ្ងាយ ១០-១៥គីឡូ ។

ដានី៖ កំពង់សៀមអ៊ីនៅម្តុំណាទៅ?

យុត៖ ខ្ញុំកើតកំពង់ចាម ។

ដានី៖ ឆ្ងាយពីកំពង់ចាមមកឆ្ងាយទេ? នៅជាប់ថ្នល់ជាតិដែលឬអត់ទេ?

យុត៖ ជាប់ថ្នល់ជាតិ ប្រហែល៥-៦គីឡូ ។

ដានី៖ កំពង់សៀមមានឃុំប៉ុន្មានទៅអ៊ីកាលហ្នឹង?

យុត៖ មិនដឹងមានឃុំប៉ុន្មាន មិនបានចាំអស់ ព្រោះឃុំច្រើនដែរ ប៉ុន្តែមិនដឹងប៉ុន្មានឃុំ ។

ដានី៖ ដូចអ៊ីនៅកំពតមិញ កោះតូច ទាល់តែអ៊ីប្រាប់បានដឹង ។

យុត៖ ខ្ញុំវាក្មេងមិនដឹងឃុំណាខ្លះ វាច្រើនដែរឃុំនៅកំពង់សៀម ក្មេងអស់ ។

ដានី៖ ឥឡូវមានឃុំក្រឡា, កំពង់សៀម ដែលអត់ទេ?

យុត៖ ឃុំក្រឡា កំពង់សៀម ។

ដានី៖ ហ្នឹងឃុំគេដែរកាលពីជំនាន់ហ្នឹង?

យុត៖ ទេជំនាន់មុនមិនដឹងឃុំគេអត់ ខ្ញុំទៅលឺគេហៅក្រឡាៗដែរ ខ្ញុំមិនបានចាំដែរ ព្រោះខ្ញុំទៅថ្មី ។

ដានី៖ ខាងស្រុក?

យុត៖ ខាងស្រុក ហ្នឹងឃុំគេដែលម៉េចទេ ខ្ញុំមិនសូវច្បាស់ដែរ ។

ដានី៖ ទីតាំងព្រំដែនរបស់កំពង់សៀម ពីត្រឹមណាដល់ត្រឹមណាទៅ?

យុត៖ ត្រឹមទ្រើង ។

ដានី៖ ចាប់ពីទ្រើងដល់?

យុត៖ ថ្នល់ស្គន់ ។

ដានី៖ ពីទ្រើងទៅដល់ថ្នល់ស្គន់?

យុត៖ ត្រឹមថ្នល់ស្គន់ហ្នឹងតែម្ដងទៅទល់នឹងកំពង់ចាម ។ តែមួយកំណាត់យោធានៅ យើងបានមួយកំណាត់ ។

ដានី៖ យោធានៅកន្លែងណា?

យុត៖ នៅមួយកំណាត់ភ្នំស្រី ភ្នំប្រុសទៅចេះ ។

ដានី៖ លើភ្នំស្រី ភ្នំប្រុស យោធានៅទេ?

យុត៖ យោធាភាគ ។

ដានី៖ នៅលើភ្នំស្រី ភ្នំប្រុសហ្នឹងតែម្ដង?

យុត៖ នៅទាំងអស់ ត្រឹមភ្នំស្រី ភ្នំប្រុសទៅចឹង សុទ្ធតែយោធាភាគហើយ ។

ដានី៖ បើយើងនៅតាមភូមិយើងធ្វើស្រែ ធ្វើចំការ ធ្វើទំនប់ ចាប់ពីត្រង់ណាទៅខ្វះ?

យុត៖ ចាប់ពីភ្នំស្រី ភ្នំប្រុសមកហ្នឹង ចាប់ពីកន្លែងកងទ័ពមក ។

ដានី៖ អ៊ំមានទៅកំពង់ចាម-កំពង់សៀមហ្នឹងមានធ្វើទំនប់អត់?

យុត៖ ខ្ញុំធ្វើទំនប់ត្រួយចេក ។

ដានី៖ ខ្ញុំធ្លាប់ទៅទំនប់ត្រួយចេកកាលហ្នឹង?

យុត៖ សុទ្ធតែធ្លាប់ហើយបានសួរខ្ញុំ ។

ដានី៖ ទំនប់ត្រួយចេកហ្នឹងធំណាស់អ៊ំ?

យុត៖ មិនធំប៉ុន្មានទេ ។

ដានី៖ ដូចទឹកគេល្ងឹងល្ងើយដល់ឥឡូវហ្នឹង ។

យុត៖ ទំនប់ត្រួយចេកគេទប់ទឹកក្រោម ។

ដានី៖ ធ្វើយូរទេទំនប់ត្រួយចេកហ្នឹង?

យុត៖ ធ្វើឆ្នាំ៧៧ហ្នឹង ។

ដានី៖ ដល់ពេលឆ្នាំណាបានហើយ?

យុត៖ ៧៧ហើយតែម្តង។

ដានី៖ ធ្វើតែ៧៧ ដល់៧៧ហ្នឹងហើយតែម្តង?

យុត៖ បើទំនប់ស្រុក ស្រុកតូច។

ដានី៖ តូចណា៎ខ្ញុំឃើញធំ។

យុត៖ អត់ទេ តាមភ្នំ អានេះភ្នំ អានេះភ្នំ នៅកណ្តាល ខាងក្រោមខ្ញុំមិនបានធ្វើទេ។

ដានី៖ ប៉ុន្មានទៅ?

យុត៖ មិនដឹងប៉ុន្មានម៉ែត្រទេ។

ដានី៖ ដូចយុវជនប៉ុន្មាន?

យុត៖ មិនដឹងប៉ុន្មាន ខ្ញុំមិនបានកត់ទុក។

ដានី៖ ប្រហែលជារយ ឬពាន់ទៅ?

យុត៖ កំលាំងទី១ ទី២។

ដានី៖ ដល់ពេលយើងទៅអីចឹង ស្ថានភាពប្រជាជនរស់នៅ ហូបចុក យ៉ាងម៉េចទៅ?

យុត៖ ខ្ញុំទៅដល់?

ដានី៖ បាទ!

យុត៖ លំបាកដែរ ទៅដល់ស្រុកគេនៅចាស់ខ្ញុំមិនបានដឹង។

ដានី៖ យ៉ាងម៉េចទៅជីវភាពលំបាកយ៉ាងម៉េចខ្វះទៅអ៊ំនៅចាំ?

យុត៖ លំបាកអត់បាយ អត់ទឹក ខ្ញុំទៅឃើញប្រជាជនលំបាកហើយ មិនដឹងថាស្រុកហ្នឹងយ៉ាងម៉េចអត់អីហូប ខ្លួនខ្ញុំអត់អីហូបដែរ ស៊ីបាយពោតដូចតែគ្នា។

ដានី៖ ដល់ពេលអ៊ំទៅរៀបចំ ហើយបង្កបង្កើនផលអីយ៉ាងម៉េចដែរ? ជីវភាពមានការប្រសើរឡើងវិញឬអត់ទេ?

យុត៖ នៅស្រុកហ្នឹងខ្ញុំមើលទៅដីតែ៦ពាន់ហិចតា មនុស្សដល់៦ម៉ឺននាក់នោះ ធ្វើម៉េចក៏មិនបានហូបគ្រប់ដែរ ដីតែ៦ពាន់ហិចតា។

ដានី៖ ដី៦ពាន់ហិចតា!

យុត៖ ដី៦ពាន់ហិចតា ហើយមនុស្ស៦ម៉ឺន គិតទៅ ចែកទៅបែងគ្រឡា។

ដានី៖ មួយហិចតា១០នាក់?

យុត៖ គិតទៅ អីចឹងទៅដោះស្រាយម៉េចចេញ ហើយដីលើភ្នំ លំបាកណាស់ស្រុកហ្នឹង ហើយស្រុកហ្នឹងសុទ្ធតែភ្នំ។ ភ្នំថ្មទៀត ធ្វើក្រឡិកក្រឡុកៗ ដីស្រែ។

ដានី៖ យើងមានវិធី យើងរាយការណ៍ទៅខាងតំបន់ ទៅខាងភាគគេដោះស្រាយ?

យុគ៖ បើយើងមិនរាយការណ៍ម៉េចបានប្រជាជនគ្រប់ គេចោទថាយើងក្បត់ ។

ដានី៖ យើងធ្វើវិធីយ៉ាងម៉េចដើម្បីឲ្យប្រជាជនហូបគ្រប់គ្រាន់?

យុគ៖ ធ្វើម៉េចបើដីតែប៉ុណ្ណឹង ។

ដានី៖ ឬក៏នៅតែទុកអីចឹងឲ្យប្រជាជនហូបអត់គ្រាន់?

យុគ៖ អត់គ្រាន់ហ្នឹងហើយ ខ្ញុំមកវិញក៏នៅតែប៉ុណ្ណឹង ។

ដានី៖ កាលហ្នឹងខាងតំបន់ ខាងភូមិភាគគេដឹងដែលអត់?

យុគ៖ ដឹងតាមស្រុកគេចាស់ ដឹងថាអត់គ្រប់ ។

ដានី៖ តែគេអត់មានវិធានការណ៍អីចាត់ចែងទេ?

យុគ៖ មិនដឹងម៉េចបើខ្ញុំនៅបានប៉ុន្មានខែ ខ្ញុំមកវិញ ដកភារកិច្ចមកវិញ ប្តីចាប់ មក៧៨វិញ ដល៧៩-៨០នេះ ។

ដានី៖ ខែប៉ុន្មាន ៧៨ ដែលអ៊ំផ្លាស់ចេញពីកំពង់ចាម?

យុគ៖ ខ្ញុំចេញមកថ្ងៃប៉ុន្មានទេ ខ្ញុំទៅខែ១ ៧៧, ខែប៉ុន្មានទេ៧៨ខ្ញុំមកវិញ គេដកប្តីខ្ញុំ ។

ដានី៖ ប្តីអ៊ំគេចាប់ខែប៉ុន្មានទៅ?

យុគ៖ ចាប់ខែ៨ ៧៨ហ្នឹង ។

ដានី៖ ចាប់ខែ៨ ឆ្នាំ៧៨?

យុគ៖ ថ្ងៃ៨ ឆ្នាំ៧៨ ។

ដានី៖ ឆ្នាំ៧៨ តែក្នុងខែណា?

យុគ៖ អត់ដឹងខែណាទេ ស្រាប់តែដក ។

ដានី៖ ដូចថាចុងខែហើយ ឬនៅដើមខែ?

យុគ៖ ចុងខែដែរ ។

ដានី៖ ចុងឆ្នាំហើយដែរ?

យុគ៖ ចាំ!

ដានី៖ ចុងឆ្នាំ៧៨ហើយអីចឹង?

យុគ៖ គេដកហើយ គេដកខ្ញុំមកដែរ ។

ដានី៖ អីចឹងពេលដែលគេចាប់ប្តីអ៊ំ ពេលហ្នឹងគាត់មកធ្វើជាប្រធានមន្ទីរនៅតំបន់៤១ ជាមួយតាអាន?

យុត៖ ប្រធានមន្ទីរក៏អត់មានធ្វើអី ។

ដានី៖ តែគាត់មកនៅជាមួយ តាអាន?

យុត៖ នៅជាមួយតាអាន តែអត់ប្រយោជន៍ដែលហ្នឹង គ្មានធ្វើអី គ្រាន់តែទុកជាខែល ។

ដានី៖ ដល់ពេលចុងឆ្នាំ៧៨ គេចាប់គាត់ទៅ?

យុត៖ ៧៨ ។

ដានី៖ គេចាប់ហ្នឹងគេមានមកប្រាប់អ៊ំ ឬអ៊ំបានដឹង?

យុត៖ ប្រាប់ថាចាប់ប្តី ។

ដានី៖ ពីណាអ្នកប្រាប់?

យុត៖ តាម៉ុក ហ្នឹង ។

ដានី៖ តាម៉ុក អ្នកប្រាប់អ៊ំតែម្តង?

យុត៖ ហ្នឹងហើយ ។

ដានី៖ តែអ៊ំអត់មានតវ៉ាជាមួយគាត់ទេ?

យុត៖ តវ៉ាម៉េច យើងសម័យហ្នឹងតែនិយាយម៉េចគឺអីចឹង អ្នកណាទៅតវ៉ាចាប់ប្តី សម័យអារក ។

ដានី៖ ដោយសារយើងស្គាល់គ្នាក្រែងលោះយើងហ៊ាននិយាយ?

យុត៖ អត់ទេ ស្គាល់ម៉េចក៏គេមិននិយាយកើតដែរ អីចឹងគេហៅវ៉ាស៊ីសផ្តាច់ការ និយាយពាក្យហ្នឹងបានចប់ វ៉ាស៊ីសផ្តាច់ការមិនមែនចេះតែនិយាយបានទេ ខ្ញុំសុំជំរាប នេះខ្ញុំនិយាយត្រង់ហើយ ព្រោះមួយម៉ាត់ណាក៏ត្រូវគិតដែរ អីចឹងបានគេថាអ្នកប្រល័យពូជសាសន៍ មិនឃើញទេ តែយើងក្នុងឋានៈយើងដឹកនាំ តែយើងមិនអាចទៅនិយាយអីចឹងបាន និយាយម៉េចបាន ព្រោះគេចាប់ទូទាំងប្រទេស ហើយប្តីយើងម្នាក់ហ្នឹង ទោះបីយើងមានគំនិតខ្ពស់ប៉ុណ្ណឹងក៏យើងមិនតវ៉ាថាឲ្យប្តីរួចបានដែរ ហើយខ្លះគេចោទខ្ញុំចេះទៀត ចោទថាខ្ញុំចាប់ប្តីសម្លាប់ផង មិនមែនធម្មតាទេ ។

ដានី៖ ពីណាគេចោទអ៊ំអីចឹង?

យុត៖ អត់ទេ ពាក្យចចាមអារ៉ាម ។

ដានី៖ ដល់ពេលគេចោទអីចឹងអ៊ំមានអារម្មណ៍ក្នុងចិត្តយ៉ាងម៉េច?

យុត៖ ខ្ញុំអត់មានអារម្មណ៍អី ចោទម៉េចចោទទៅ ខ្ញុំមិនដឹងផង ។

ដានី៖ អត់ខឹង?

យុត៖ ទីងតាំងពីថ្ងៃចាប់ហើយ ចោទអីចោទទៅ ខ្ញុំធ្វើមិនដឹងរហូតដល់ថ្ងៃហ្នឹង ខ្ញុំនិយាយទៅ យើងទៅទីងធ្វើអី ។

ដានី៖ អ៊ំមានកូនប៉ុន្មាននាក់ដែរ?

យុត៖ ខ្ញុំអត់មាន ។

ដានី៖ អត់មានកូន?

យុត៖ កូនខ្ញុំរាល់ថ្ងៃយកប្ដីក្រោយបានកូនមួយស្រីការហើយ ។

ដានី៖ អីចឹងកាលទៅជាមួយអត់មានកូនចៅជាមួយគាត់ទេ?

យុត៖ អត់ ។

ដានី៖ តាអាន មានដែលប្រាប់ថាគេមកចាប់គ្រួសារអ៊ំ?

យុត៖ គាត់មិនមែនដែលនិយាយទេ ព្រោះខាងលើចាប់ គាត់មិនដឹង និយាយរួមរឿងនេះពីកំពត ទៅ មិនមែនរឿងនៅតំបន់៤១ទេ ខាងលើគេអ្នកដឹង គេដឹងថាឈ្មោះណាចាប់ គេចាប់ ហ្នឹង គេមិនប្រាប់ទេ ។ តែខ្ញុំគេប្រាប់ ខាងលើប្រាប់ខ្ញុំ តាម៉ុក ហ្នឹងប្រាប់តែម្ដងថាប្ដីត្រូវ ចាប់ នេះខ្ញុំនិយាយមើលឲ្យឃើញ កុំតែតាម៉ុក ប្រាប់ក៏ខ្ញុំអត់ដឹងដែរ ។ រឿងចាប់ប្ដីហ្នឹង ហើយបានខ្ញុំទីណាត់ទីណែងមកដល់ពាយ័ព្យ សួរនីរសាខ្ញុំ៤-១០នាក់ មកធ្វើអត់បាយ-ទឹក ដោយសារអី ដោយសារប្ដីចាប់ ។ ខ្ញុំគិតជាជនរងគ្រោះធ្ងន់ណាស់ មិនសមណា សម្ដាសន៍ខ្ញុំទេ ខ្ញុំនិយាយអីចឹងតែម្ដង លំបាកមិនមែនទើបតែឥឡូវតាំងពី៧៦មក ប្ដីហ្នឹង ដកភារកិច្ចរហូតតែម្ដង ។ យើងទៅនៅកំពង់ចាមប្ដីអត់មានធ្វើស្អី គេដកទុកជាខែល ខ្ញុំនឹក ឃើញថាការតស៊ូរបស់បក្ស ធ្វើឲ្យចប់ចុង ចប់ដើម ព្រោះយើងគោរពបក្សដឹកនាំ ហ្នឹង និយាយមួយម៉ាត់ ហើយបើយើងអត់គោរពគេចាប់យើងបាត់ហើយ ។ នេះបក្សខាងលើ គេប្រាប់ថាខ្ញុំប្ដីចាប់ អ្នកឯងគ្រប់គ្នាដែលគេប្រាប់ទេ គេចាប់ទាំងអស់ៗតែម្ដង ។

ដានី៖ ដោយសារយើងជាកម្មាភិបាលរបស់បក្ស បានគេប្រាប់អ៊ំឲ្យដឹង?

យុត៖ មិនមែនទេ កម្មាភិបាលរបស់បក្សច្រើនណាស់ តែមិនដឹងថាគេយល់ថាម៉េច អីចឹងបានខ្ញុំ មានជីវិតរស់នៅដល់ថ្ងៃនេះ គេសរសើរខ្ញុំ ប្ដីចាប់ហើយរស់ខ្លួនឯង អ្នកស្រុកមកពីកំពង់ សៀម កំពង់ចាម នៅសាស្ដាមកដល់ឃើញខ្ញុំ អ៊ំ! ខ្ញុំស្មានគេចាប់អស់ហើយ ។ អ៊ំអត់មាន អី ខ្ញុំថាអត់មានអីផង ខ្ញុំស្មានអ៊ំឯងចាប់ជាមួយអ៊ំបាត់ហើយ ខ្ញុំថាអត់ទេ ។ ហ្នឹងមកពី យើងហៅថា ទស្សនៈរបស់យើង យើងវិភាគទៅថាមានមនោសញ្ចេតនាទៅលើបក្សដែរ បើអត់ក៏យើងត្រូវបាត់ខ្លួនដែរ យើងបើនិយាយទៅ ខ្ញុំនិយាយឲ្យឃើញថាការដឹកនាំនេះ

បើយើងគិតទៅថាយើងគ្មានករិតកម្មសិទ្ធិឯកជន និយាយទៅថាលះបង់ឃើញក្រខ្វួនទេ បើសិនជាខ្ញុំមានកម្មសិទ្ធិ ខ្ញុំមិនមែនក្រទេ ខ្ញុំទៅនៅកំពង់ចាមមាសទាំងគីឡូៗ សុទ្ធតែទឹកដប់ទៀត សួរថាខ្ញុំដែលយកមួយខ្សែមកផ្ទះទេ អត់ប៉ះពាល់ទេ ។

ដានី: អ៊ំឃើញមាសនៅណា?

យុត: គេចាប់មនុស្ស អ្នកណាគេដកពីខាងសហករណ៍ គេយកមកឲ្យយើង យើងទៅគិតអីមាសហ្នឹង បើប្រទេសជាតិទាំងមូល ខ្ញុំមិនគិតទេរឿងកំប៉ិកកំប៉ុក ។

វណ្ណៈ : មាសបញ្ជូនឡើងទៅលើ?

យុត: ចា៎! បញ្ជូនត អ្នកណាយកទៅណាយកទៅ ។ ខ្ញុំនិយាយមួយទៅនៅកំពង់ចាមមាសសំបូរណាស់សុទ្ធតែត្រាមេដាយ សុទ្ធតែសន្ទឹក តែខ្ញុំមិនដែលគិត ។

ដានី: មាសហ្នឹងដូចគេប្រមូលពីសហករណ៍ អ្នកដែលគេចាប់?

យុត: មិនដឹងគេយកពីណា ពីណី យើងចេះតែទទួលទុក ។

ដានី: ដូចគេចាប់យើងយកមកទុកកន្លែងណាទៅកាលហ្នឹង?

យុត: គេយកមកឲ្យយើងស្រុក ស្រុកបញ្ជូនទៅខេត្ត ខេត្តបញ្ជូនទៅណាបាត់ មិនដឹងយកទៅណា

វណ្ណៈ : បញ្ជូនតគ្នាទៅ?

យុត: តគ្នាទៅ ព្រោះយើងរាល់ថ្ងៃអីចឹងមានខ្សែពីក្រោមរហូតដល់លើ មានអ្នកណាហ៊ានទុក ។

ដានី: គេបញ្ជូនមកលើទៀតដល់ណាទៅ?

យុត: អត់ដឹង ។

វណ្ណៈ : បើតាមខ្ញុំគិត អ៊ំប្រហែលជាគេយល់យោគដែរ?

យុត: យល់យោគដែរ ។

វណ្ណៈ : អ៊ំនៅខាងតាកែវ បើនៅស្រុកជាមួយប្ដីខាងព្រៃវែង ប្រហែលជាមិនអាចទេ ។

យុត: ម្យ៉ាងចេះខ្ញុំគិត បើខាងលើទាំងអស់នេះខ្ញុំមិនអួតទេ អ្នកណាក៏ស្គាល់ខ្ញុំដែរ រាល់ថ្ងៃក៏ដោយណាក៏ស្គាល់ខ្ញុំដែរ ឈ្មោះខ្ញុំប្រាក់ យុត ម្នាក់នេះគឺស្គាល់ទាំងអស់តែម្ដង អីចឹងគេយល់ថាយើងអ្នកនយោបាយជាន់ខ្ពស់ ខ្ញុំស្រីមែន ខ្ញុំក៏នយោបាយខ្ពស់ដែរ ហើយខ្ញុំក៏បានជួបប្រទះធំៗច្រើនដែរ ។ ធំៗត្រង់ថាយើងធ្វើការ អីចឹងគេយល់យោគយើង ឧទាហរណ៍អ្នកធំ អ្នកតូចក៏យកចិត្តទុកដាក់ខ្ញុំច្រើនដែរ ព្រោះខ្ញុំអ្នកនយោបាយដើងឆើតដែរ ដល់ប្រទេសអីចឹងទៅខ្ញុំក៏និយាយមិនកើត ដូចថាឥឡូវប្ដីអីចឹងតាំងពី៧៦ អូនឯងមើល ផ្ញើកង់ទ័ពៗគេ

ដកកុច ខ្ញុំសួរថាហេតុអីបានយកមកនៅមន្ទីរឥឡូវ ម៉ែអាទូចអើយ បើយើងអត់មានខុស ដែលគេដក ថាចេះ ខ្ញុំក៏អត់និយាយដែរ ។

ដានី: អ៊ំមានកូន បានគាត់ហៅអ៊ំម៉ែអាទូច?

យុគៈ: ខ្ញុំអត់មានកូនទេ ចេះតែហៅទៅព្រោះយើងអត់កូន ។ ខ្ញុំថាបើដកក៏ដកទៅ ដល់ពេលទៅកំពង់ចាមយកទៅទៀត ចំហរឈ្មោះចោលដដែល ដល់ហើយខ្ញុំជួប ខ្ញុំនិយាយឲ្យលោកអ៊ីចឹងចុះ ជួបប្ដីដោយស្ងាត់ទៀត ថាមិនបាច់ឈឺចាប់អីទេ បើសិនខ្ញុំត្រឹមណាក៏ដោយក៏ខ្ញុំមិនបោះបង់ចោលដែរ ខ្ញុំនិយាយអ៊ីចឹង មិនបាច់ឈឺចាប់ទេ ។ អត់ធ្វើអីក៏អត់ចុះ ឲ្យតែជីវិតនៅ ៧៨ចាប់ហ្នឹងបណ្ដោយ ឃើញទេ? ការងារខ្ញុំមិនសំខាន់ទេ សំខាន់ឲ្យតែរស់នៅ ព្រោះឋានៈខ្ញុំដឹកនាំមែន តែខ្ញុំមិនមែនមើលងាយអ្នកឯងដែរ ព្រោះអ្នកឯងជាប្រុស ឋានៈខ្ញុំវាខ្ពស់មែន តែខ្ញុំមិនមានចិត្តអីទៅមើលងាយអ្នកឯង មើលងាយ មើលថោក ខ្ញុំអត់មើលងាយទេ យើងបាននិយាយគ្នាស្ងាត់ ខ្ញុំថាមិនបាច់ឈឺចាប់ទេ អត់អីក៏អត់ទៅឲ្យតែជីវិតរស់នៅ ។ ដល់ហើយ៧៨ ខាងលើប្រាប់ខ្ញុំថាត្រូវចាប់ប្ដី ខ្ញុំក៏និយាយមិនកើត ឥឡូវយើងតវ៉ាវាខុសខ្លួនយើង មិនបាច់ដេញដោលទេ យើងមើលតែតារាងខ្ញុំនិយាយជាមួយអង្គការអស់ហើយ ខ្ញុំថាខ្ញុំបើគិតទៅខ្ញុំជាជនរងគ្រោះ សង្កាត់សង្កែងខ្លាំងណាស់ នោះប្អូនៗខ្ញុំទៅសម្ភាសន៍ដល់ប្អូនៗខ្ញុំទៀត ប្អូនខ្ញុំគេមកដែរ ។ សម្ភាសន៍សួរតែរឿងឈ្មោះខ្ញុំ ប្រវត្តិខ្ញុំតែម្ដង តែសាក្សីហ្នឹងដាក់ជាឋានៈតុលាការ ឋានៈជាសាក្សីរបស់តុលាការមិនអាចចាប់ចង់ខ្ញុំឃើញសំបុត្រនៅហ្នឹង ។ ចាប់ចងយ៉ាងម៉េចបើខ្ញុំរងគ្រោះដល់ហើយ ដល់អាមួយនិយាយជាមួយខ្ញុំទៀត រងគ្រោះតែម្នាក់ឯង ប្ដីខ្លួនឯង តែចំពោះប្រជាជនទូទាំងប្រទេសចុះប្ដីខ្ញុំក៏ប្រជាជនខ្ញុំដែល មិនមែនអ្នកដទៃណា៎ ម៉េចក៏ខ្ញុំមកលះបង់ខ្ពស់ម៉្លេះ នេះខ្ញុំនិយាយជាមួយអូនឯងដោយត្រង់ ។ ខ្ញុំរាល់ថ្ងៃខ្ញុំនឹកប្ដី មិនមែនខ្ញុំមិននឹកទេ ប្ដីខ្ញុំស្លូត ខ្ញុំប្រាប់អូនឯង កម្មាជីវូបនីយកម្មគ្មានអ្នកណាដល់ កងទ័ពរបស់របរមិនខ្វះទេ មិនដែលយកមកឲ្យប្រពន្ធប៉ុនក្រចកដៃទេ ខ្ញុំប្រាប់អូនឯងត្រង់ ដោយសារអីធាតុលះបង់វាខ្ពស់ ខ្ញុំក៏ធាតុលះបង់ គាត់ក៏ធាតុលះបង់ ទីចុងបញ្ចប់មានតែបាតដៃទទេ ហើយមានរឿងទៀត រឿងរហូតដល់ថ្ងៃហ្នឹងអត់ចប់ ខ្ញុំខឹងខ្លួនឯង មែនតា៎ខ្ញុំនិយាយស្មោះត្រង់ ខឹងខ្លួនឯងចាប់ប្ដីហើយមានរឿងរហូតទៀត ។

ដានី: ដល់ពេលខែប៉ុន្មានគេផ្លាស់អ៊ំចេញពីកំពង់ចាមមកនៅបន្ទាយមានជ័យ?

យុគៈ: ខែ៨ហ្នឹង ដាច់ខែ៨ខ្ញុំចេញមកតែម្ដង ។

ដានី៖ អីចឹងក្រុមគ្រួសារអ៊ំទាំងអស់ចេញមក?

យុត៖ ចេញមកជាមួយខ្ញុំទាំងអស់ នៅធ្វើអី ឲ្យនៅធ្វើអីគេចាប់ ។ នឹកឃើញនៅជាមួយខ្ញុំ ខ្ញុំមានឈ្មោះរងគ្រោះ ក្រែងលោវារួចខ្លះ នៅនោះចាប់ហើយ ។

ដានី៖ កាលហ្នឹងអ្នកណាគេអ្នកផ្លាស់អ៊ំចេញពីកំពង់ចាម?

យុត៖ អត់ដឹង គេថាឲ្យយើងចេញ យើងចេញតែម្តង ។

ដានី៖ តាអាន គាត់ប្រាប់?

យុត៖ តាអាន ឬអ្នកណាខ្ញុំមិនបានចាំ គេឲ្យចេញខ្ញុំចេញ ខ្ជិលលែងសើរើអីទៀត រឿងមិនចេះចប់ មិនចេះហើយ ខ្ញុំមិនសើរើ ។

ដានី៖ ដល់ពេលអ៊ំចេញពីហ្នឹងមកនៅណាទៅ?

យុត៖ ខ្ញុំមកនៅពាយ័ព្យ នៅរងកម្មគ្មានបានបាយស៊ីមួយម៉ាត់ទេ គេធ្វើបាបខ្ញុំខ្លាំងណាស់ ប្រធានមន្ទីរខេត្តបាត់ដំបង ឲ្យខ្ញុំទៅស្ទូងភក់ត្រឹមៗហ្នឹង ខ្ញុំប្រាប់ខ្ញុំទៅនីរសាខ្ញុំ២០នាក់ ទៅជាមួយបងប្អូនខ្ញុំទាំងអស់ ម៉ែខ្ញុំសុំបាយគេប៉ុណ្ណឹងគេមិនឲ្យផង ដោយសារយើងគេដកភារកិច្ច ។

ដានី៖ ផ្លាស់ពីកំពង់ចាមមកត្រង់ពាយ័ព្យតែម្តង ឬចូលភ្នំពេញសិន?

យុត៖ អត់ចូលភ្នំពេញទៀតទេ ហ្នឹងផ្លូវសៀមរាបចូលបាត់ដំបង ។

ដានី៖ តាមផ្លូវសៀមរាប?

យុត៖ ព្រោះគេមានសំបុត្រខ្ទេសនាមចេញទៅណាមកណា គេនិយាយហើយអស់ យើងដឹងតែចេញទេ យើងអត់មានសួរបានទេអាហ្នឹង ។

ដានី៖ ប៉ុន្មានថ្ងៃពីកំពង់ចាមមកដល់?

យុត៖ តែមួយថ្ងៃដល់បាត់ដំបង ពីសៀមរាបមក ។

ដានី៖ ចេញពីសៀមរាបមកដល់បាត់ដំបង! បាត់ដំបងនៅស្រុកណាទៅអ៊ំ?

យុត៖ អត់នៅស្រុកទេ យកដាក់មន្ទីរឃុំឃាំងនៅបាត់ដំបង ។

ដានី៖ នៅទីរួមខេត្តហ្នឹងតែម្តង?

យុត៖ នៅកន្លែងរដ្ឋ មិនដឹងត្រង់ណា ខ្ញុំមិនសូវស្គាល់ ខ្ញុំមិនដែលស្គាល់បាត់ដំបងណា៎ ទើបនឹងមកហ្នឹង មកដល់គេស្ទូងក៏ទៅ ។

ដានី៖ ស្ទូងនៅណា?

យុត៖ ស្ទូងជុំវិញខេត្តហ្នឹង ស្រែរដ្ឋ ។

ដានី៖ ជុំវិញកន្លែងមន្ទីរខេត្ត?

យុត៖ មន្ទីរខេត្តហ្នឹង ។

ដានី៖ មន្ទីរសំបូរទឹករលកហ្នឹង?

យុត៖ សុទ្ធតែទឹក សុទ្ធតែភក់ ។

ដានី៖ មកជួបតាម៉ុក នៅហ្នឹងទៀតអត់?

យុត៖ ជួប តាម៉ុក ថា «អញមិនដឹងធ្វើម៉េចទេ បើខាងលើឲ្យចាប់ អញចាប់ហ្នឹងឯង» ខ្ញុំថាបើយកទៅណាយកទៅឲ្យហើយទៅ ខ្ញុំមិនចង់រស់នៅទេ អាបក្សចុងហ៊ី បើដឹងអីចឹងខ្ញុំអត់ធ្វើ ខ្ញុំស្ដាយណាស់ ខ្ញុំនិយាយអីចឹងមុខតាម៉ុក នៅសាលាសកលវិទ្យាល័យខាងកើតបៀតដំបងក្រញូង ។

ដានី៖ កន្លែងសកលវិទ្យាល័យបាត់ដំបងហ្នឹង?

យុត៖ ខ្ញុំថាបើសិនជាយកខ្ញុំទៅនោះហើយ ហើយយកខ្ញុំមកធ្វើឃាតករអីចឹងខ្ញុំតូចចិត្តប៉ុណ្ណាខ្ញុំសួរខ្ញុំមិនចង់បានមុខមាត់អីទៀត ព្រោះប្ដីចប់ហើយ តែបើយកដាក់ក្នុងប៉ុស្ដិ៍យកឲ្យហើយ ខ្ញុំនិយាយអីចឹង នីរសាខ្ញុំ៥-៦នាក់ ។

ដានី៖ និយាយមុខតាម៉ុក? និយាយប្រាប់ តាម៉ុក អីចឹង?

យុត៖ និយាយតាម៉ុក អីចឹង ។ គាត់ថា «អញមិនមែនចង់ធ្វើឯងទេ តែខាងលើ» គាត់ក៏រត់ខាងលើដែល មិនមែនគាត់ធ្វើចិត្តគាត់ទេ ខាងលើវាតគ្នារហូត ជឿអត់?

ដានី៖ បាទ!

យុត៖ គាត់ប្រាប់ខ្ញុំអីចឹង ។ ខ្ញុំណាំតូ កុំតែដោយសារពូឯងខ្ញុំមិនបានទៅកំពង់ចាមទេ ហើយបើដកខ្ញុំទីណាត់ទីណែងចេះខ្ញុំស្ដាយណាស់ ខ្ញុំខឹងណាស់ ។ ខ្ញុំពូឯងបើសិនជាយកខ្ញុំទៅដាក់គុកក្នុងប៉ុស្ដិ៍យកទៅ មិនបាច់យកទៅណាទៀតទេ ។ ខ្ញុំដឹងថាកន្លែងគុកក្នុងប៉ុស្តិ៍កន្លែងរបស់រដ្ឋ ធំខ្ញុំសុខចិត្តចូលគុកទាំងអស់តែម្ដង ។

ដានី៖ អ៊ំថាបើសិនជាអ៊ំដឹងថា តាម៉ុក ឲ្យអ៊ំធ្វើឃាតករ អ៊ំមិនធ្វើម៉េច?

យុត៖ តាម៉ុក មិនដែលឲ្យខ្ញុំធ្វើឃាតករទេ ខ្ញុំចង់និយាយថាប្រជាជនថាខ្ញុំធ្វើឃាតករប្ដី មិនមែនអ្នកណាមកធ្វើទេ ចាប់ប្ដីហ្នឹងមកពីខ្ញុំហ្នឹង មានអ្នកណាធំជាងគាត់ មានតែគាត់ហ្នឹងឃាតករខ្លួនឯង ។ រាល់ថ្ងៃប្ដីចាប់ហ្នឹងគេមិនមែនថាអ្នកណាចាប់ទេ គឺខ្ញុំទេអ្នកសម្លាប់ គេចោទប្រកាន់មួលបង្កាច់យើង ។

វណ្ណៈ ៖ ព្រោះកាលហ្នឹងគេមើលទៅអ៊ំធំ ប្ដីគាត់តូច?

យុតៈ ព្រោះយើងអ្នកធំ គ្មានអ្នកណាទៅសំរេចបានទេ សំរេចលើខ្ញុំៗ តែតាមការពិតអ្នកណាទៅលើកដៃធ្វើអីចឹង ខ្ញុំអាណិតប្ដីខ្ញុំណាស់ គេចាប់ ជួបជុំគ្នាសុំលាខ្ញុំទៅភ្នំពេញ គេចាប់ដាក់លើឡានហើយលាខ្ញុំទៀត ខ្ញុំលាហើយម៉ែអាទូច អ៊ើ! អញ្ជើញសុខសប្បាយ យំមិនចេញទេ ។

ដានីៈ តែប្ដីអ៊ឹគាត់អត់មានអារម្មណ៍មួយសង្ស័យអី?

យុតៈ អត់ដឹងទេ ចាប់ទៅហើយញ័រទ្រើកទ្រើកអស់ហើយ ។

ដានីៈ ប៉ុន្តែក្រែងលោ?

យុតៈ ដឹងអីអ្នកណាដឹង បើចិត្តគាត់អ្នកណាមើលគាត់ឃើញ សួរអីចឹងក៏មិនត្រូវ ។

ដានីៈ មួយទៀតខ្ញុំឆ្ងល់ត្រង់តាម៉ុក គាត់ថាចាប់ហ្នឹងមិនមែនគាត់ទេ ពីខាងលើ?

យុតៈ ខាងលើគាត់ អ្នកដឹកនាំភូមិភាគ អ្នកមជ្ឈិមបក្សអីទៅ ។ ដូចហ៊ុន សែន បញ្ជាមកហើយអ្នកណាហ៊ានធ្វើអី អាហ្នឹងយើងនិយាយអីចឹង យើងនិយាយឲ្យមើលឃើញទាំងអស់គ្នា ព្រោះគាត់ក្រោមភូមិភាគ ខាងលើមជ្ឈិមបក្ស ។ ហ៊ុនសែន មជ្ឈិមបក្ស គាត់បញ្ជាឲ្យចាប់ អ្នកណាយើងត្រូវតែចាប់ យើងនិយាយអីចឹងចុះ ។

ដានីៈ កាលជំនាន់ហ្នឹងពីណាគេ?

យុតៈ ហ្នឹងខ្ញុំមិននិយាយមើលងាយទេ ខ្ញុំនិយាយស្មោះត្រង់ តិចទៅនិយាយថាខ្ញុំចេះចុះ មានមជ្ឈិមបក្សអ្នកដឹកនាំរួម ។

ដានីៈ ខាងលើគាត់មានពីណា? តានួន ជា, ប៉ុល ពត?

យុតៈ ហ្នឹងហើយមជ្ឈិមបក្ស ខ្ញុំនិយាយមជ្ឈិមបក្ស ហើយមានខាងលើណាទៀត ដូចហ៊ុន សែន អីចឹង មជ្ឈិមបក្សគឺហ៊ុន សែន បញ្ជាឲ្យចាប់អ្នកណា ចង់អ្នកហ្នឹងហើយ កុំច្រលំ ។

ដានីៈ តែដល់ពេលអ៊ឹមកនិយាយទឹងជាមួយគាត់ គាត់អត់ទឹង រករឿងអីដែរ?

យុតៈ រករឿងម៉េច ខ្លួនគាត់មិនហ៊ានអារកាត់ណា៎ គាត់ប្រាប់ខ្ញុំថាគាត់មិនចាប់ទេ គឺខាងលើឥឡូវអញមិនចាប់ទៅវាខុសអញ បើគាត់អត់ចាប់មិនខុសគាត់ គេចាប់គាត់ដែរ អាហ្នឹងវាតគ្នាអីចឹង មិនមែនលេងៗទេ ។

ដានីៈ អ៊ឹមកបាត់ដំបងជួបតាម៉ុក?

យុតៈ តាម៉ុក ខ្ញុំជួបរាល់តែថ្ងៃ ។

ដានីៈ ផ្ទះនៅជាប់គ្នាអត់ទេ?

យុតៈ អត់ទេ យើងមន្ទីរឃុំឃាំង គាត់ដើរមកយើងស្គាត់ជួបគាត់ទៅ គេមកជួបអីយើង ។

ដានី៖ មកហ្នឹងជួប យាយថែម?

យុត៖ អត់ទេ ខ្ញុំមិនដែលបានជួប យាយថែម រហូតដល់ថ្ងៃហ្នឹង បើការងារខុសគ្នា ។

ដានី៖ តាទិត អ៊ីធ្លាប់ឃើញគាត់ទេនៅហ្នឹង?

យុត៖ អត់ទេ ខ្ញុំមិនដែលជួបអ្នកណា ។ នេះខ្ញុំនិយាយ ប្រយ័ត្នអូនឯងទៅនិយាយថាខ្ញុំចេះចុះ!

ដានី៖ អត់អីទេ ។

យុត៖ ខ្ញុំនិយាយដោយស្មោះត្រង់តែម្តង ហើយដែលខ្ញុំក្រនៅព្រំដែនដោយសារអី ដោយសារខ្ញុំបាត់ដៃទទេតាំងពីថ្ងៃនោះមកដល់ថ្ងៃហ្នឹង ឃើញទេគេសុទ្ធតែផ្ទះថ្មសសរឥដ្ឋអស់ ខ្ញុំយល់ថាអ្នកណាលើកអីលើកទៅ ឲ្យតែជីវិតនៅ ខ្ញុំគិតអីចឹង បើជីវិតអត់នៅវាលំបាក ។

ដានី៖ អ៊ំដល់ពេលយួនចូលមកយ៉ាងម៉េចទៀតទៅជីវិតរបស់អ៊ំ?

យុត៖ យួនចូលមកនៅដីថៃធ្វើមិនដឹង ។

ដានី៖ ចេញពីបាត់ដំបងទៅខាងណា?

យុត៖ ខ្ញុំរត់ទៅដល់ដីថៃ ។

ដានី៖ រត់ភ្លាមទៅដល់ភ្លាម?

យុត៖ អត់ទៅដល់ភ្លាមទេ ដើរតាមស្ទឹងមួយខែបានដល់ផ្ទះថៃ ។

ដានី៖ ទៅទាំងអស់?

យុត៖ ទៅទាំងអស់ ។

ដានី៖ ទាំងម្តាយអ៊ំ ទាំងបងប្អូន?

យុត៖ ម៉ែខ្ញុំទៅស្លាប់តាមផ្លូវ ។

ដានី៖ គាត់ស្លាប់តាមផ្លូវ?

យុត៖ លង់ទឹកស្ទឹង ដើរតាមស្ទឹង យើងមិនហ៊ានឡើងលើ ។

ដានី៖ កាលហ្នឹងគាត់ចាស់ហើយនៅ?

យុត៖ ម៉ែខ្ញុំគាត់អាយុចិតជាង ។

ដានី៖ អីចឹងគាត់ខូចពេលដែលអ៊ំរត់ទៅឆ្នាំ៧៩ហ្នឹងតែម្តង?

យុត៖ ចា៎!

ដានី៖ នៅណាទៅ? ម្តុំណាទៅស្ទឹង?

យុត៖ អត់ស្គាល់ ចេះតែរត់ទៅឲ្យរួចខ្លួន ក្នុងព្រៃភ្នំមិនដឹងណា អ្នកណាស្គាល់ ។

ដានី៖ ដល់ពេលអ៊ំរៀបការទៀតឆ្នាំណាទៅ?

យុគៈ ខ្ញុំរៀបប្ដីក្រោយ យកប្រពន្ធចុងបានកូន២-៣ ។

ដានីៈ បាទ?

យុគៈ ខ្ញុំការចិតប៉ុន្មានទេ ភ្លេចហើយ ។

ដានីៈ ៧៩ យើងបែក ។

យុគៈ ការ៨២-៨៣ ហ្នឹងប្ដីខ្ញុំតាំ អង្គុយមិញហ្នឹង តែគេយកប្រពន្ធចុង ។

ដានីៈ អ៊ំនៅរាប់អានគ្នាធម្មតា?

យុគៈ រាប់អានដូចបងប្អូន ខ្ញុំឱ្យលទាស់ អ្នកណាយកណាយកទៅ ។

ដានីៈ អ៊ំមានកូនប៉ុន្មានទៅ?

យុគៈ កូនខ្ញុំមួយស្រីមានប្ដី ការហើយ ។

ដានីៈ អ៊ំទៅដល់ទឹកដីថៃ ហើយប៉ុន្មានទៅបានយើងត្រឡប់មកដីខ្មែរវិញ?

យុគៈ ទាល់តែឈ្នះ ៧៩-៩០ ។

ដានីៈ អ៊ីចឹងអ៊ំនៅដីថៃរហូត? នៅជំរំរហូត?

យុគៈ នៅដីថៃរហូត ទំរាំតែរស់ កុំឲ្យតែយួនបាញ់ត្រូវ ។

ដានីៈ អ៊ំអត់មានធ្វើការងារ តស៊ូអីទៀត?

យុគៈ ធ្វើការងារអីទៀត ខ្លាចយួន ។

ដានីៈ ដូចថាយើងអត់ចូលមកគ្រប់គ្រងប្រជាជនទៀតទេ? ដូចអ៊ំធ្លាប់គ្រប់គ្រងប្រជាជន?

យុគៈ គ្រប់គ្រងអី អត់ទេ ខ្ញុំឱ្យលធ្វើ ឈប់ធ្វើ រាល់ថ្ងៃឆ្អែតឆ្អល់ហើយ ខ្ញុំឈប់ហើយអាយុ៧៩

ដានីៈ អ៊ីចឹងអ៊ំខ្ញុំអរគុណអ៊ំច្រើន ដែលចំណាយពេល ។

ចប់